ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលបានព្រះត្រាស់បង្គាប់តែងតាំង និងផ្តល់ឋានៈជាឯកអគ្គរាជទូតអមព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ មានឋានៈស្មើរដ្ឋមន្ត្រី

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៣១៣ ខែមករា ឆ្នាំ២០២៦

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា



លោក ឆាំង យុ ប្រធានព្រះរាជបណ្ណាល័យ ហ្វូនម៉ែ និងជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## មាតិកា

### សំបុត្រ


- លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលបានព្រះត្រាស់បង្គាប់តែងតាំង និង ....... ១
- យើងត្រូវតែការពារប្រាសាទព្រះវិហារ .......... ៥
- ការទទួលខុសត្រូវ គឺជាមូលដ្ឋានគ្រឹះសម្រាប់ស្វែងរកសន្តិភាព................................. ៧
- ការឈ្លានពានរបស់ប្រទេសថៃមកលើប្រទេសកម្ពុជា ក្នុងឆ្នាំ២០២៥ ........................... ៩
- ប្រទេសថៃត្រូវតែផ្ដល់សំណង.................. ១១
- ស្មារតីប្រជាជនខ្មែរទាំងអស់បានផ្សារភ្ជាប់..... ១៣
- ការផ្ដល់ជំនួយរបស់សហរដ្ឋអាមេរិក.......... ១៥
- រថភ្លើង ........................................... ១៧


### ផ្នែកឯកសារ


- ប្រះ ម៉ាត់ ៖ ការរត់គេចចេញពីរបបខ្មែរ ....... ១៩


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- ទិដ្ឋភាពនៅតំបន់ព្រំដែនលើកំពូលភ្នំដងរែក... ២២
- ប៊ូ សុភាន់ ៖ ដង្ហើយរកយុត្តិធម៌សម្រាប់ប្ដី .... ២៤
- រត់គ្រោះទៅទិសត្បូងសាន ៖ ជម្រោះនិង ........ ២៦
- ទន្លេមេគង្គ អ្នកនាំសារដ៏ស្ងៀមស្ងាត់អំពី..... ២៩
- ប្រាសាទចៅស្រីវិបុល ........................ ៣២
- ខ្មែរក្រហមសម្លាប់ឪពុករបស់ខ្ញុំដោយសារ... ៣៧
- ឡុង វ៉ាន់ ៖ អតីតគ្រូពេទ្យនៅមន្ទីរពេទ្យ....... ៤០
- ប្រាក់ ថា ៖ ខ្ញុំត្រូវបានបញ្ជូនទៅឈរជើង ..... ៤៣
- ឡុង ថន ៖ ប្រធានអនុសេនាតូចលេខ២ ..... ៤៥
- រឿងរ៉ាវរបស់ ឡុង សាកាន់ អ្នករស់រាន ...... ៤៨


### ផ្នែកវេទិកាពិភាក្សាសាធារណៈ


- យុទ្ធសាស្ត្ររបស់ប្រទេសថៃក្នុងការដណ្ដើមយកដែនអធិបតេយ្យភាពដែលបាន................. ៥០
- តើហេតុអ្វីបានជាពិបាកសម្រាប់ប្រទេសថៃដោយគ្រាន់តែនិយាយពាក្យថាសន្តិភាពនិង ........ ៥២
- កម្ពុជាគួរមានលក្ខខណ្ឌចំនួន ៥ សម្រាប់..... ៥៥
- ភាគីថៃដោះលែងវីរកងទ័ពកម្ពុជា៖ ចំណុចពិចារណាបីសំខាន់ៗ សម្រាប់កម្ពុជា... ៥៧
- សិស្សានុសិស្សមកពីវិទ្យាល័យ ឈីនលានហាន់ជ័យ ធ្វើទស្សនកិច្ចសិក្សា ............... ៥៨


### ផ្នែកស្រាវជ្រាវរកគ្រួសារ


- ប្អូនខ្ញុំឈ្មោះ សារ៉េត បានបាត់ខ្លួនពេលអង្គការបញ្ជូនទៅធ្វើព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ....... ៦០



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឱ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ៣៧ ៥ព.មប្រក

ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ ៖** ឆាំង យុ, លី សុខឃាង, មេកវិន, ទាវ សម្ភស្ស, សូ ហ្វារីណា, ស្រេង លីដា, ស៊ាង ចិន្តា, មឿន ស្រីណុច, ចាន់ណារិទ្ធ, សាំង ចាន់ធូ, លី ដេវីត និង វី ស៊ីថា

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លីម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន

**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** អេង រ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលបានព្រះត្រាស់បង្គាប់តែងតាំង និង

## ផ្ដល់ឋានៈជាឯកអគ្គរាជទូតអមព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ មានឋានៈស្មើរដ្ឋមន្ត្រី

**មជ្ឈមណ្ឌលឯកសារកម្ពុជា**



*ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី សព្វព្រះរាជហឫទ័យ ព្រះរាជានុញ្ញាតឱ្យលោក ឆាំង យុ ប្រធានព្រះរាជបណ្ណាល័យហ្វូងម៉ែ និងជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ចូលក្រាបថ្វាយបង្គំគាល់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលការទទួលស្គាល់ពីព្រះមហាក្សត្រ ចំពោះស្នាដៃនៃបេសកកម្មពេញមួយជីវិតរបស់លោកក្នុងការអភិរក្សប្រវត្តិសាស្ត្រ យុត្តិធម៌ និងកេរដំណែលរាជវង្សប្រទេសកម្ពុជា។

ជាអ្នកជំនាញលើប្រធានបទប្រល័យពូជសាសន៍ និងដែលជាអ្នករស់រានមានជីវិតផ្ទាល់ពីឧក្រិដ្ឋកម្មឃោរឃៅរបស់ខ្មែរក្រហម ទទួលបានការត្រាស់បង្គាប់តែងតាំង និងផ្ដល់ឋានៈជាឯកអគ្គរាជទូតអមព្រះរាជខុទ្ទកាល័យ ព្រះមហាក្សត្រ មានឋានៈស្មើរដ្ឋមន្ត្រី ដែលនេះបានឆ្លុះបញ្ចាំងអំពីការចូលរួម

ចំណែករបស់លោកអស់រយៈកាលជាច្រើនឆ្នាំកន្លងមកចំពោះការអប់រំពីប្រវត្តិសាស្ត្រ និងការលើកកម្ពស់របបរាជានិយម។

យោងតាមព្រះរាជក្រឹត្យ ដែលបានចេញផ្សាយកាលពីថ្ងៃចន្ទ ទី១៩ ខែមករា ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះអង្គត្រាស់បង្គាប់តែងតាំង លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងព្រះរាជបណ្ណាល័យហ្វូងម៉ែ ជា «ឯកអគ្គរាជទូតអមព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា» ដែលមានឋានៈស្មើរដ្ឋមន្ត្រី។

លោក ឆាំង យុ នឹងបំពេញភារកិច្ចជាអ្នកទំនាក់ទំនងផ្លូវការរវាងព្រះបរមរាជវាំង និងរាជរដ្ឋាភិបាលកម្ពុជា។ ក្នុងឋានៈនេះ លោកក៏មានតួនាទីនាំព្រះរាជសារសម្របសម្រួលកិច្ចការក្នុងព្រះរាជពិធីនានា និងធានានូវការប្រព្រឹត្តទៅដោយរលូននៃពិធីការរវាងខុទ្ទកាល័យព្រះមហាក្សត្រ ខុទ្ទកាល័យនាយករដ្ឋមន្ត្រី បណ្តាក្រសួង និងស្ថានបេសកកម្មការទូតបរទេស នៅពេលដែលមានព្រះរាជវត្តមានចូលរួមរបស់ព្រះមហាក្សត្រ។

នៅក្នុងកិច្ចសន្ទនាជាមួយកាសែតខ្មែរថាមស៍ កាលពីម្សិលមិញនាថ្ងៃទី២០ ខែមករា លោក ឆាំង យុ បានថ្លែងអំណរព្រះគុណយ៉ាងជ្រាលជ្រៅ និងសេចក្តីរំភើបជាពន់ពេក ចំពោះការជ្រោសព្រះរាជទានតែងតាំងដ៏ខ្ពស់ខ្ពស់ពីព្រះមហាក្សត្រ ហើយលោកថែមទាំងបានបង្ហាញអំពីភក្តីភាព និងការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការបម្រើព្រះរាជវង្សានុវង្សកម្ពុជា។

លោកបានមានប្រសាសន៍ថា៖ «ខ្ញុំពិតជាមានកិត្តិយសក្រៃលែងចំពោះព្រះប្រទាននេះ។ ខ្ញុំពិតជាពិបាកក្នុងការរកពាក្យពេចន៍សមសួនដើម្បីបង្ហាញអំពីការដឹងគុណទទួលស្គាល់ និងតបស្នងចំពោះការជ្រោសព្រះរាជទានតែងតាំងដ៏ខ្ពង់ខ្ពស់នេះ»។ លោកបានបន្តថា៖ «ខ្ញុំមានសេចក្តីរំភើប និងសូមក្រាបលំឱនកាយចំពោះព្រះរាជកាយវិការសន្តោសប្រណីរបស់ព្រះមហាក្សត្រ ដែលព្រះអង្គសព្វព្រះរាជហឫទ័យជ្រោសព្រះរាជទានតែងតាំងខ្ញុំបាទ និងចំពោះព្រះ



សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរនិងព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រាជជំនឿទុកចិត្តរបស់ព្រះអង្គមកលើខ្ញុំបាទ និងមជ្ឈមណ្ឌលឯកសារកម្ពុជា»។

លោក ឆាំង យុ ដែលបច្ចុប្បន្ន មានងារជាវការថា «ឯកអគ្គរាជទូត យុ» បានបង្ហាញការប្តេជ្ញាចិត្ត និងសន្យាថា នឹងបំពេញភារកិច្ចឱ្យស្របតាមការរំពឹងទុកដ៏ខ្ពង់ខ្ពស់របស់ព្រះរាជវង្សានុវង្ស ក្នុងតួនាទីដ៏សំខាន់មួយនេះ។

លោកបានលើកឡើងថា៖ «ខ្ញុំប្តេជ្ញាបំពេញឱ្យបានស្របទៅតាមការរំពឹងទុកដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណា ព្រះមហាក្សត្រ និងសម្តេចព្រះមហាក្សត្រី ជាទីគោរពសក្ការ ក្នុងឋានៈដ៏ខ្ពង់ខ្ពស់នេះ»។

មានទីកន្លែងកំណើតនៅរាជធានីភ្នំពេញ លោក ឆាំង យុ បានរួចរស់ជីវិតពីរបបខ្មែរក្រហម ដែលជាបទពិសោធន៍មួយបានជះឥទ្ធិពលយ៉ាងខ្លាំងក្នុងការកំណត់បេសកកម្មការងារពេញមួយជីវិតរបស់លោក។ ក្នុងរយៈកាលជាច្រើនឆ្នាំបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម លោកបានចូលរួមចំណែកក្នុងគំនិតផ្តួចផ្តើមនានា ដើម្បីចងក្រងឯកសារស្តីពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលនៅពេលនោះមានប្រជាជនកម្ពុជាប្រមាណជាង ១លាន៧សែននាក់ បានបាត់បង់ជីវិតដោយសារការសម្លាប់ ការបង្អត់អាហារ ការធ្វើពលកម្មដោយបង្ខំ និងជំងឺផ្សេងៗ។

ការប្តេជ្ញាចិត្តរបស់លោកក្នុងការស្វែងរកការពិត និងយុត្តិធម៌ បានជំរុញលោកឱ្យចូលរួមពីដំបូងនៅឆ្នាំ១៩៩៥ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលដើមឡើយគឺជាបេសកកម្មមួយរបស់សាកលវិទ្យាល័យ យ៉េលរបស់សហរដ្ឋអាមេរិក នៅមុនពេលដែលស្ថាប័ននេះបានក្លាយជាស្ថាប័នឯករាជ្យរបស់កម្ពុជាស្ថិតក្រោមការដឹកនាំរបស់លោកផ្ទាល់។

ក្រោមការដឹកនាំរបស់លោក មជ្ឈមណ្ឌលឯកសារកម្ពុជា បង្កើតបានជាបណ្ណសារដ្ឋានធំបំផុតមួយនៅក្នុងពិភពលោក ដែលតម្កល់នូវឯកសារស្តីពីរបបខ្មែរក្រហម ដោយបម្រើជាធនធានដ៏មានសារសំខាន់បំផុតសម្រាប់ប្រវត្តិវិទូ អ្នកអប់រំ សិស្ស-និស្សិត អ្នកសារព័ត៌មាន និងអ្នកស៊ើបអង្កេតផ្នែកច្បាប់។

ឯកសារដែលតម្កល់នៅក្នុងបណ្ណសារដ្ឋាននេះបានគាំទ្រដល់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលជាសាលាក្តីមួយ ទទួលបានការគាំទ្រពីអង្គការសហប្រជាជាតិ បង្កើតឡើងដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម។

ក្រៅពីការងារចងក្រងឯកសារ និងការទំនុកបម្រុងគាំទ្រផ្នែកច្បាប់ លោក ឆាំង យុ គឺជាអ្នកអប់រំសាធារណៈឈានមុខ ស្តីពីប្រវត្តិសាស្ត្រកម្ពុជាសម័យទំនើប។ លោកបានដឹកនាំកម្មវិធីផ្សព្វផ្សាយនៅទូទាំងប្រទេស ដោយដាក់បញ្ចូលឯកសារប្រវត្តិសាស្ត្រកម្ពុជានានាទៅក្នុងកម្មវិធីអប់រំនៅតាមសាលារៀន បណ្តុះបណ្តាលគ្រូបង្រៀន រៀបរៀងសៀវភៅសិក្សាស្តីពីរបបខ្មែរក្រហម សៀវភៅណែនាំគ្រូបង្រៀន និងលើកកម្ពស់កិច្ចពិភាក្សាដោយចំហរនៅក្នុងចំណោមមនុស្សជំនាន់ក្រោយ ដែលពុំបានឆ្លងកាត់សម័យកាលនោះ។ កិច្ចខិតខំប្រឹងប្រែងរបស់លោក បានទម្លាយភាពស្ងប់ស្ងាត់ក្នុងសង្គមដែលបានចាក់ស្រេះអស់រយៈកាលជាយូរឆ្នាំ ជុំវិញបញ្ហានៃរបួសផ្លូវចិត្ត ព្រមទាំងបណ្តុះនូវវប្បធម៌នៃការចងចាំ និងការសិក្សារៀនសូត្របែបត្រិះរិះពិចារណា។

លោក ឆាំង យុ បានឈ្នះពានរង្វាន់ រ៉ាម៉ុន ម៉ាក្សសៃសៃ ដែលជាពានរង្វាន់ «ណូបែលអាស៊ី» នៅក្នុងឆ្នាំ២០១៨។

ក្នុងតួនាទីជានាយកនៃព្រះរាជបណ្ណាល័យហ្លួងម៉ែ លោកបានលះបង់កម្លាំងកាយចិត្តក្នុងការថែរក្សាកេរដំណែលរបស់សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ និងព្រះរាជវង្សានុវង្សកម្ពុជា។ បច្ចុប្បន្ន លោក ឆាំង យុ បាននិងកំពុងដឹកនាំការជួសជុលកែលម្អអតីតព្រះរាជដំណាក់ក្នុងខេត្តសៀមរាប ... 



ព្រះរាជក្រឹត្យ

នស/រកត/០១២៦/ ១២៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

តែងតាំង និងផ្តល់ឋានៈ ឯកឧត្តម សាំង យុ

ជា

ឯកអគ្គរាជទូតអមព្រះរាជខុទ្ទកាល័យ ព្រះមហាក្សត្រ
មានឋានៈស្មើ រដ្ឋមន្ត្រី

ពរស. ២៦០១. ១២៦

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៥ ខែមករា ឆ្នាំ២០២៦

*ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ត្រាស់បង្គាប់ តែងតែងលោក សាំង យុ ជាឯកអគ្គរាជទូតអមព្រះរាជខុទ្ទកាល័យ ព្រះមហាក្សត្រ មានឋានៈស្មើ រដ្ឋមន្ត្រី ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# យើងត្រូវតែការពារប្រាសាទព្រះវិហាររបស់យើង

ឆាំង យុ



យោធាថៃបានទម្លាក់គ្រាប់បែក និងបាញ់ផ្លោងបំផ្លាញប្រាសាទព្រះវិហារ អំឡុងពេលឈ្លានពានប្រទេសកម្ពុជា ពីថ្ងៃទី២៤ ដល់២៨ ខែកក្កដា ឆ្នាំ២០២៥ និងពីថ្ងៃទី៧ ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។ (បណ្ដាញសារព័ត៌មានកម្ពុជា)

នៅក្នុងឆ្នាំ១៩៦៣ តុលាការយុត្តិធម៌អន្តរជាតិបានចេញសាលដីកាជាលើកដំបូង ដែលពាក់ព័ន្ធនឹងជម្លោះព្រំដែនដីរុំារ៉ៃរវាងប្រទេសកម្ពុជានិងប្រទេសថៃ ដោយសម្រេចថាប្រាសាទព្រះវិហារនិងតំបន់ជុំវិញគឺជាដែនអធិបតេយ្យភាពស្របច្បាប់របស់ប្រទេសកម្ពុជា។ សេនាប្រមុខ សារិត ថាណារ័ត្ន និងជាអតីតនាយករដ្ឋមន្ត្រីថៃកាលពីសម័យនោះ និយាយដោយខឹងសម្បាចំពោះសាលដីការបស់តុលាការយុត្តិធម៌អន្តរជាតិថា៖ «ទោះបីជាត្រូវស្រក់ឈាម និងត្រូវចំណាយពេលរាប់ឆ្នាំ យើងត្រូវដណ្ដើមយក ប្រាសាទព្រះវិហាន មកវិញនៅថ្ងៃណាមួយ»។

ជាច្រើនទសវត្សរ៍ក្រោយមក តុលាការយុត្តិធម៌អន្តរជាតិបានចេញសាលដីកាឡើងវិញម្ដងទៀតបញ្ជាក់អំពីការសម្រេចចិត្តនេះ។ បន្ថែមទៀត ប្រទេសកម្ពុជា និងប្រទេសថៃបានប៉ះទង្គិចគ្នាដោយប្រដាប់

*អាវុធជាបន្តបន្ទាប់ ហើយជម្លោះនេះនៅតែគ្មានដំណោះស្រាយ។ នាពេលបច្ចុប្បន្នប្រទេសថៃបន្តប្រើប្រាស់កម្លាំងយោធាដើម្បីប្រឆាំងជាមួយប្រទេសកម្ពុជា។ ជម្លោះប្រដាប់អាវុធនេះទំនងជាបន្តអូសបន្លាយទៅមុខរយៈពេលរាប់សិបសតវត្សរ៍ទៀត។ បទឈប់បាញ់ខ្លីរយៈពេល៧២ម៉ោង ប្រទេសកម្ពុជាត្រូវឆ្លើយតបទៅប្រទេសថៃថា៖ «ទោះបីជាត្រូវស្រក់ឈាម ត្រូវចំណាយពេលរាប់ឆ្នាំ និងរាប់សតវត្សរ៍ យើងត្រូវតែការពារប្រាសាទព្រះវិហាររបស់យើង»។*





*យោធាថៃបានទម្លាក់គ្រាប់បែក និងបាញ់ផ្លោងបំផ្លាញប្រាសាទព្រះវិហារ អំឡុងពេលឈ្លានពានប្រទេសកម្ពុជា ពីថ្ងៃទី២៤ ដល់២៨ ខែកក្កដា ឆ្នាំ២០២៥ និងពីថ្ងៃទី៧ ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។ (បណ្ណាញសារព័ត៌មានកម្ពុជា)*

# ការទទួលខុសត្រូវ គឺជាមូលដ្ឋានគ្រឹះ សម្រាប់ស្វែងរកសន្តិភាព

ឆាំង យុ



យោធាថៃបានទម្លាក់គ្រាប់បែក និងបាញ់ផ្លោងបំផ្លាញប្រាសាទព្រះវិហារ អំឡុងពេលឈ្លានពានប្រទេសកម្ពុជា ពីថ្ងៃទី២៤ ដល់២៨ ខែកក្កដា ឆ្នាំ២០២៥ និងពីថ្ងៃទី៧ ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។ (បណ្តាញសារព័ត៌មានកម្ពុជា)

ការឈ្លានពានរបស់យោធាថៃមកលើកម្ពុជា បានបង្ហាញពីចេតនារបស់យោធាថៃដែលមិនអើពើនឹងច្បាប់មនុស្សធម៌អន្តរជាតិ ដែលរួមមានទាំងច្បាប់អន្តរជាតិសម្រាប់ការការពារជនស៊ីវិល និងការការពារបេតិកភណ្ឌវប្បធម៌។

ជាងនេះទៅទៀត ការវាយប្រហារមកលើប្រាង្គប្រាសាទព្រះវិហារ គឺបានបង្ហាញអំពីការមិនគោរព និងភាពព្រងើយកន្តើយចំពោះសាលក្រមនៃតុលាការយុត្តិធម៌អន្តរជាតិ។ ប្រហែលជាអ្នកអាចចងចាំបានថា បន្ទាប់ពីព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ទ្រង់បានទាមទារនូវឯករាជ្យភាពជូនជាតិមាតុភូមិ ព្រះអង្គបានទទួលនូវជ័យជម្នះតាមផ្លូវច្បាប់ ក្នុងការតស៊ូប្រឆាំងនឹងសកម្មភាពរបស់ថៃនៅតំបន់ប្រាសាទព្រះវិហារ ដែលរំលោភបំពានមកលើដែនអធិបតេយ្យ និងបូរណភាពទឹកដីរបស់កម្ពុជា។

ព្រះរាជសកម្មភាពទាំងនេះ គឺមិនមែនជាព្រះរាជសកម្មភាពតូចតាចទេ ផ្ទុយទៅវិញ ព្រះរាជសកម្មភាពទាំងនេះបានឆ្លុះបញ្ចាំងពីជ័យជម្នះជាយុទ្ធសាស្ត្រ ដែលតាមបន្តួលងបន្លាចថៃរហូតមកទល់



យោធាថៃបានទម្លាក់គ្រាប់បែក និងបាញ់ផ្លោងបំផ្លាញប្រាសាទព្រះវិហារ អំឡុងពេលឈ្លានពានប្រទេសកម្ពុជា ពីថ្ងៃទី២៤ ដល់២៨ ខែកក្កដា ឆ្នាំ២០២៥ និងពីថ្ងៃទី៧ ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។ (បណ្តាញសារព័ត៌មានកម្ពុជា)

សព្វថ្ងៃ ហើយព្រះរាជសកម្មភាពទាំងនេះមានចំណែកយ៉ាងសំខាន់ នឹងអាចជាហេតុផលមួយដែលយោធាថៃហាក់ដូចជាមានចេតនា និងគោលដៅក្នុងការវាយប្រហារតំបន់ប្រាសាទព្រះវិហារដោយប្រើប្រាស់កាំភ្លើងធំ, ដ្រូន (យន្តហោះគ្មានមនុស្សបើក) និងការទម្លាក់គ្រាប់បែកតាមអាកាសដោយប្រើប្រាស់យន្តហោះចម្បាំងប្រភេទ F-16។

ជាចុងក្រោយ ការគាំទ្ររបស់រដ្ឋាភិបាលថៃចំពោះសកម្មភាពរបស់យោធាថៃ ដូចដែលបានពិពណ៌នាខាងលើ គឺបង្ហាញពីចេតនា និងការសម្រេចចិត្តរបស់រដ្ឋាភិបាលថៃ ក្នុងការមិនគោរព និងមិនអើពើចំពោះកាតព្វកិច្ចដែលខ្លួនបានយល់ព្រមក្រោមកិច្ចព្រមព្រៀងឈប់បាញ់ដែលសម្របសម្រួលដោយសហរដ្ឋអាមេរិក និងអាស៊ាន។ សរុបសេចក្តីមក ប្រទេសថៃបានប្រព្រឹត្តសកម្មភាពដែលរំលោភបំពានច្បាប់អន្តរជាតិយ៉ាងធ្ងន់ធ្ងរបំផុតជាច្រើនដង ហើយប្រទេសថៃត្រូវតែមានការទទួលខុសត្រូវចំពោះការប្រព្រឹត្តនូវសកម្មភាពទាំងនេះ ដើម្បីថែរក្សាសន្តិភាព និងធានាសន្តិសុខនៅក្នុងតំបន់ ទោះបីជាមិនមែនទទួលខុសត្រូវនៅថ្ងៃនេះក៏ដោយ ក៏ច្បាស់ណាស់ថា នាពេលអនាគតដ៏ខ្លីខាងមុខ។



# ការឈ្លានពានរបស់ប្រទេសថៃមកលើប្រទេសកម្ពុជា ក្នុងឆ្នាំ២០២៥

ឆាំង យុ



*យោធាថៃចូលទន្ទ្រានកាន់កាប់ផ្ទះសម្បែងនិងភូមិឋានប្រជាជនកម្ពុជាក្នុងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យដោយខុសច្បាប់ ។ (បណ្តាញសារព័ត៌មានថៃ)*

រាល់វចនានុក្រមល្បីល្បាញទាំងអស់បានកំណត់និយមន័យពាក្យ «ការឈ្លានពាន» ជាទូទៅថាគឺជាទង្វើ ដែលយោធាឈានចូលប្រទេសដទៃដោយប្រើប្រាស់កម្លាំងដើម្បីគ្រប់គ្រងលើទីតាំងទាំងនោះ (ជាឧទាហរណ៍គឺការឈ្លានពានរបស់ប្រទេសអាល្លឺម៉ង់ទៅលើប្រទេសប៉ូឡូញក្នុងឆ្នាំ១៩៣៩)។ និយមន័យមួយផ្សេងទៀតទៅលើពាក្យ «ការឈ្លានពាន» នេះបានពិពណ៌នាថាគឺជាការចូលលុកលុយរបស់យោធាដើម្បីដណ្តើមយក ប្លន់យកទន្ទ្រានយក ឬរំលោភយកដែនដីរបស់ប្រទេសដទៃ។ ពាក្យមួយទៀតដែលប្រហាក់ប្រហែលវានោះគឺ «ការកាន់កាប់ដោយអរិភាព» ផ្តោតជាពិសេសទៅលើសកម្មភាពលុកលុយរបស់យោធាតែម្តង។ ផ្អែកទៅលើកាលៈទេសៈនានា ទោះបីជាភាគីថៃប្រហែលជាមិនចង់ឲ្យគេហៅការកាន់កាប់ដោយអរិភាពរបស់ខ្លួនទៅលើទឹកដីកម្ពុជាថាជា «ការឈ្លានពាន»ក៏ដោយ ទង្វើរបស់ថៃគឺពិតជាមានសភាពស្របទៅនឹងនិយមន័យខាងលើ។

រដ្ឋាភិបាលថៃចង់រារាំងប្រព័ន្ធផ្សព្វផ្សាយសាធារណៈ សហគមន៍អន្តរជាតិនិងភាគីកម្ពុជាចំពោះការប្រើប្រាស់ពាក្យ «ការឈ្លានពាន» ក្នុងការ

ពិពណ៌នាអំពីការគ្រប់គ្រងដោយកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនសព្វថ្ងៃទៅលើទីតាំងមួយចំនួនដែលស្ថិតដែនអធិបតេយ្យភាពរបស់កម្ពុជា ស្របពេលដែលបទឈប់បាញ់បានចូលជាធរមាន ដោយសារតែពាក្យនេះបានធ្វើឱ្យប៉ះពាល់ដល់ភាពស្របច្បាប់នៃទង្វើរបស់ខ្លួនដែលពុំស្របទៅតាមដំណើរការឈានទៅសម្រេចបានសន្តិភាព។

ទោះបីជាយ៉ាងណាក្តីវាគឺជារឿងចាំបាច់ក្នុងការចងចាំថា អំឡុងពេលនៃការឈ្លានពានរបស់ប្រទេសថៃមកលើផ្នែកខ្លះនៃដែនអធិបតេយ្យភាពរបស់កម្ពុជា ប្រជាជនកម្ពុជាបានទទួលរងការធ្វើទុក្ខបុកម្នេញ។ អាជីវកម្មនានាត្រូវបានបិទឈប់ដំណើរការ ទាំងស្រងការរស់នៅប្រចាំថ្ងៃបានប្រព្រឹត្តទៅក្រោមការបង្ខិតបង្ខំ និងការយាយីពីកងកម្លាំងប្រដាប់អាវុធបរទេស ហើយព័ត៌មានអំពីទង្វើដ៏អាក្រក់នេះកំពុងត្រូវបានបិទបាំងដោយរដ្ឋាភិបាលថៃដែលកំពុងប៉ុនប៉ងអនុវត្តសកម្មភាពកាន់កាប់នេះដោយលាក់លៀម។

ចូរកុំយល់ច្រឡំឱ្យសោះ ការកាន់កាប់ដោយអរិភាពនេះក៏ជាការឈ្លានពានដែរ ហើយវាគឺជាភស្តុតាងបន្ថែមទៀតនៃការរំលោភបំពានជាបន្តបន្ទាប់ និងដោយចំហរបស់ប្រទេសថៃ ចំពោះដំណើរការឈានទៅសម្រេចបានសន្តិភាពដែលជ្រោមជ្រែងដោយសហរដ្ឋអាមេរិក និងអាស៊ាន។







យោធាថៃចូលទន្ទ្រានកាន់កាប់ប្រាសាទតាក្របី ក្នុងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ដោយខុសច្បាប់ ។
(បណ្តាញសារព័ត៌មានថៃ)



យោធាថៃចូលទន្ទ្រានកាន់កាប់តំបន់ថ្ម ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់ ដោយខុសច្បាប់ ។
(បណ្តាញសារព័ត៌មានថៃ)

# ប្រទេសថៃត្រូវតែផ្តល់សំណង

**ឆាំង យុ**



*ស្ពានជ័យជម្នះ (បុស្ពានមេទឹក) ក្នុងឃុំថ្នដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ ទឹកដីប្រទេសកម្ពុជា ត្រូវកងទ័ពអាកាសទម្លាក់គ្រាប់បែកពីយន្តហោះចម្បាំង F-16 ចំនួន៣គ្រាប់ដើម្បីបំផ្លាញ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៥។ (មជ្ឈមណ្ឌលឯកសារកម្ពុជា)*

«ប្រទេសថៃត្រូវតែទទួលខុសត្រូវ ហើយការដាក់ឱ្យទទួលបន្ទុកចំពោះអំពើរបស់ខ្លួន ត្រូវតែភ្ជាប់ទៅនឹងការផ្តល់សំណង»។

បទឈប់បាញ់គឺជាអ្វីដែលគួរឱ្យស្វាគមន៍ ហើយកិច្ចព្រមព្រៀងសន្តិភាពអចិន្ត្រៃយ៍មួយគឺជាអ្វីដែលគួរឱ្យស្វាគមន៍ទៅទៀត ប៉ុន្តែសម្រាប់ទស្សនរបស់ប្រទេសកម្ពុជានិងសហគមន៍អន្តរជាតិ អ្វីដែលសម្រេចបានទាំងនេះ គឺប្រហែលជាមិនទាន់គ្រប់គ្រាន់នៅឡើយទេ។

ជម្លោះនេះមិនបានចាប់ផ្តើម ហើយក៏មិនត្រូវបានអូសបន្លាយដោយប្រទេសកម្ពុជាដែរ។ ខណៈពេលដែលការបញ្ចប់ជម្លោះគឺជាគោលដៅបន្ទាន់ ប៉ុន្តែវាគឺមិនមែនជាគោលដៅសំខាន់ចុងក្រោយនោះទេ។ វាហាក់ដូចជាមានជំនឿកាន់តែច្រើនឡើងថា បទឈប់បាញ់ រួមទាំងសន្តិភាពនឹងមិនអាចកែប្រែអ្វីឡើយ កុំថាឡើយធ្វើឱ្យធូរស្រាលឡើងវិញនូវវិបត្តិមនុស្ស-ធម៌ដ៏មហន្តរាយដែលកើតមានឡើង ទាំងសងខាងព្រំដែននៃប្រទេសទាំងពីរ។ វាប្រហែលជាមិនសមរម្យនោះទេ ក្នុងការមើលរំលងនូវការពិតដែលមានភស្តុតាងជាក់ស្តែងបញ្ជាក់ថា ជម្លោះនេះត្រូវបានបង្កឡើងដោយរបៀបវារៈរបស់ក្រុមជាតិនិយមថៃ

មួយចំនួន ហើយភាគច្រើនគឺក្រុមយោធាថៃ។

ខ្ញុំគិតថាបទឈប់បាញ់ដែលបានស្នើឡើងនេះនឹងមិនឋិតថេរនោះទេប៉ុន្តែប្រសិនបើវាគឺជាការពិតវិញនោះ ខ្ញុំយល់ឃើញថាវាគឺជាជំហានមួយឈានទៅមុខ។ ខ្ញុំសូមកោតសរសើរដល់មន្ត្រីទាំងអស់ដែលទទួលខុសត្រូវក្នុងការអនុវត្ត តំណាងឱ្យរដ្ឋមួយដែលមានភាពចាស់ទុំ។ ខ្ញុំគិតបន្ថែមទៀតថាបទឈប់បាញ់បណ្ដោះអាសន្នណាមួយគឺមិនអាចនាំទៅរកកិច្ចព្រមព្រៀងសន្តិភាពអចិន្ត្រៃយ៍។ ប្រទេសថៃមិនអាចមានសន្តិភាពជាមួយប្រទេសកម្ពុជាបានទេ លុះត្រាតែប្រទេសថៃមានសន្តិភាពសម្រាប់ខ្លួនឯង ហើយសន្តិភាពនេះនឹងមិនកើតមានឡើងទេ រហូតដល់ក្រោយការបោះឆ្នោតឆ្នាំ២០២៦។ ទោះបីជាមានកិច្ចព្រមព្រៀងសន្តិភាពអចិន្ត្រៃយ៍ក៏ដោយ ខ្ញុំមិនយល់ឃើញថាវាគ្រប់គ្រាន់នោះទេ។

ប្រទេសថៃត្រូវតែទទួលខុសត្រូវនូវរាល់សកម្មភាពរបស់ខ្លួនរួមទាំងការផ្ដល់សំណងដល់ប្រជាជនខ្មែរដែលទទួលរងផលប៉ះពាល់ដោយវិបត្តិសង្គ្រាម។ បន្ថែមពីនេះ វាគួរតែមានគណៈកម្មការស្វែងរកការពិតមួយដែលឯករាជ្យ និងដឹកនាំដោយសង្គមស៊ីវិលបង្កើតឡើងសម្រាប់កិច្ចខិតខំប្រឹងប្រែងនេះ។ ជាការពិតណាស់ ប្រសិនបើប្រទេសកម្ពុជាមិនបានអនុវត្តតាមកម្រិតស្តង់ដារអន្តរជាតិឱ្យបានពេញលេញទេ បញ្ហាទាំងនេះក៏គួរតែស្ថិតក្រោមការតាមដាននិងត្រួតពិនិត្យដោយគណៈកម្មការនេះដែរ។

នេះគឺមិនមែនជាលក្ខខណ្ឌមួយសម្រាប់ស្វែងរកសន្តិភាពទេ ប៉ុន្តែវាគឺជាលក្ខខណ្ឌមួយដើម្បីទប់ស្កាត់សង្គ្រាមនាពេលបច្ចុប្បន្ននិងទៅអនាគត។ សន្តិភាពក៏ដូចជាសង្គ្រាមដែរ គឺទាមទារឱ្យមានការដឹកនាំដ៏ឆ្នើម ហើយការស្វែងរកសន្តិភាពរវាងប្រជាជាតិនិងប្រជាជាតិគឺត្រូវទាមទារឱ្យមានការទទួលខុសត្រូវនៅក្នុងជម្លោះនេះ ដែលមិនស្ថិតក្រោមភាពចង្អៀតចង្អល់នៃជាតិនិយមឡើយ។







ស្ពានជ័យជម្នះ (ឬស្ពានមេទឹក) ក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ ទឹកដីប្រទេសកម្ពុជា ត្រូវកងទ័ពអាកាសទម្លាក់គ្រាប់បែកពីយន្តហោះចម្បាំង F-16 ចំនួន៣គ្រាប់ ដើម្បីបំផ្លាញ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៥។ (មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ស្មារតីប្រជាជនខ្មែរទាំងអស់បានផ្សារភ្ជាប់យ៉ាងជ្រាលជ្រៅជាមួយទឹកដី

ឆាំង យុ



យោធាថៃបានទម្លាក់គ្រាប់បែក និងបាញ់ផ្លោងបំផ្លាញប្រាសាទព្រះវិហារ អំឡុងពេលឈ្លានពានប្រទេសកម្ពុជា ពីថ្ងៃទី២៤ ដល់២៨ ខែកក្កដា ឆ្នាំ២០២៥ និងពីថ្ងៃទី៧ ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។
(បណ្ណាញសារព័ត៌មានកម្ពុជា)

ទីតាំងនានានៅតាមតំបន់ព្រំដែនរបស់ប្រទេសកម្ពុជា នាពេលបច្ចុប្បន្ន ដែលយោធាថៃកំពុងដណ្ដើមកាន់កាប់ រួមទាំងទីតាំងទីសក្ការៈនៃវប្បធម៌ខ្មែរ និងប្រាសាទបុរាណ គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់អន្តរជាតិ និងជាភស្តុតាងបន្ថែមទៀតដែលបង្ហាញពីការមិនគោរពចំពោះកិច្ចព្រមព្រៀងបទឈប់បាញ់របស់យោធាថៃ ជាមួយប្រទេសកម្ពុជា ក្រោមការសម្របសម្រួលរបស់សហរដ្ឋអាមេរិក និងអាស៊ាន។ ប៉ុន្តែការកត់សម្គាល់ក្នុងអត្ថបទនេះមិនមែនផ្តោតសំខាន់ទៅលើការរំលោភបំពានរបស់យោធាថៃនោះទេ។ ផ្ទុយទៅវិញការកត់សម្គាល់ពេលនេះ គឺផ្តោតលើស្មារតីដ៏រឹងមាំនៃប្រជាជនកម្ពុជា ដែលផ្សារភ្ជាប់យ៉ាងជ្រាលជ្រៅជាមួយ ទឹកដីដែលយោធាថៃកំពុងតែកាន់កាប់។

ស្មារតីប្រជាជនខ្មែរបានផ្សារភ្ជាប់យ៉ាងជ្រាលជ្រៅជាមួយ ទឹកដី ហើយ ទឹកដីគឺជាផ្នែកមួយដែលមិនអាចកាត់ផ្តាច់បានពីប្រជាជាតិខ្មែរ។ ដូច្នេះរាល់សកម្មភាពទាំង ឡាយណាដែលប៉ុនប៉ងឈ្លានពានកាន់កាប់ឬបញ្ចូលទឹកដីរបស់ប្រជាជនខ្មែរធ្វើជាកម្មសិទ្ធិរបស់ខ្លួនមិនត្រឹម

តែជាទង្វើដែលខុសឆ្គងតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការខិតខំដោយឥតប្រយោជន៍។ យ៉ាងហោចណាស់នៅក្នុងប្រវត្តិសាស្ត្រ យោធាបុអាផ្ជាធរសៀមនាជំនាន់មុនបានព្យាយាមដណ្តើមកាន់កាប់ទឹកដីរបស់ប្រទេសកម្ពុជាចំនួនពីរដង ប៉ុន្តែយោធាបុអាផ្ជាធរសៀមនាជំនាន់នោះបានបរាជ័យ។ មូលហេតុបរាជ័យរបស់យោធាបុអាផ្ជាធរសៀម គឺជាប្រធានបទសម្រាប់ពិភាក្សានៅពេលក្រោយ ប៉ុន្តែកុំឱ្យមានការភាន់ច្រឡំឱ្យសោះ។ ការព្យាយាមនាពេលបច្ចុប្បន្ន ដើម្បីដណ្តើមកាន់កាប់ កែប្រែ និងគ្រប់គ្រងតំបន់ទាំងនេះជាផ្នែកមួយនៃប្រទេសថៃគឺនឹងត្រូវជួបនូវវាសនាដូចគ្នា។

ការទស្សន៍ទាយជាមុននេះ មិនមែនផ្អែកលើសកម្មភាពណាមួយរបស់ប្រទេសកម្ពុជានោះទេ ប៉ុន្តែជាការទស្សន៍ទាយដោយផ្អែកលើជោគវាសនានៃទឹកដីទាំងនេះ។ ដោយសារទឹកដីទាំងនេះត្រូវបានគ្រប់គ្រងដោយប្រជាជនខ្មែរជាប្រវត្តិសាស្ត្រ ការគ្រប់គ្រងលើទឹកដីទាំងនេះត្រូវរំពឹងទុកថានឹងក្លាយជាផ្នែកមួយនៃប្រទេសកម្ពុជាជារៀងរហូត ហើយគ្មានសកម្មភាពអ្វីដែលប្រទេសថៃអាចធ្វើដើម្បីរារាំងអនាគតនេះបានឡើយ។









យោធាថៃបានទម្លាក់គ្រាប់បែក និងបាញ់ផ្លោងបំផ្លាញប្រាសាទព្រះវិហារ អំឡុងពេលឈ្លានពានប្រទេសកម្ពុជា ពីថ្ងៃទី២៤ ដល់២៨ ខែកក្កដា ឆ្នាំ២០២៥ និងពីថ្ងៃទី៧ ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។
(បណ្តាញសារព័ត៌មានកម្ពុជា)

# ការផ្ដល់ជំនួយរបស់សហរដ្ឋអាមេរិក

ឆាំង យុ




រូបរាប់ពីស្តាំ៖ ប្រធានាធិបតីសហរដ្ឋអាមេរិក ដូណាល់ ត្រាំ, នាយករដ្ឋមន្ត្រីកម្ពុជា ហ៊ុន ម៉ាណែត, នាយករដ្ឋមន្ត្រីថៃ អនុទិន ឆានវីរកូល និង នាយករដ្ឋមន្ត្រី ម៉ាឡេស៊ី អាន់វ៉ា អ៊ីប្រាហ៊ីម។ ប្រធាធិបតី ដូណាល់ ត្រាំ និងនាយករដ្ឋមន្ត្រីម៉ាឡេស៊ី អាន់វ៉ា អ៊ីប្រាហ៊ីម បានចូលរួមធ្វើជាសាក្សីក្នុងពិធីចុះកិច្ចព្រមព្រៀងសន្តិភាពរវាងនាយករដ្ឋមន្ត្រីកម្ពុជា ហ៊ុន ម៉ាណែត និង នាយករដ្ឋមន្ត្រីថៃ អនុទិន ឆានវីរកូល នៅទីក្រុងកូឡាឡាំពួរ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥។ (សេតវិមាន)

ការផ្ដល់ជំនួយរបស់សហរដ្ឋអាមេរិកចំនួន ៤៥ លានដុល្លារសហរដ្ឋអាមេរិក គឺជាជំហានឆ្ពោះទៅមុខដ៏អស្ចារ្យក្នុងការគាំទ្រដល់ដំណើរការសន្តិភាពរវាងប្រទេសថៃ និងកម្ពុជា ព្រមទាំងបន្តការជួយលើកកម្ពស់បន្ថែមទៀតនូវស្ថិរភាពក្នុងតំបន់នៅឥណ្ឌូប៉ាស៊ីហ្វិក។ យោងតាមសេចក្តីថ្លែងការណ៍របស់សហរដ្ឋអាមេរិក ជំនួយនេះនឹងជួយដល់ស្ថិរភាពតាមព្រំដែន ការបោសសម្អាតមីន និងគំនិតផ្តួចផ្តើមនានា ដើម្បីប្រយុទ្ធប្រឆាំងនឹងប្រតិបត្តិការឆបោក និងការជួញដូរគ្រឿងញៀន។ ការដោះស្រាយបញ្ហាទាំងនេះ គឺជា យន្តការដ៏សំខាន់ក្នុងការលើកកម្ពស់សន្តិសុខ សន្តិភាព និងវិបុលភាព ដែលមានសារសំខាន់ខ្លាំងសម្រាប់ប្រទេសទាំងពីរ (ប្រទេសកម្ពុជា និងថៃ), តំបន់ និងពិភពលោក។

ទោះជាយ៉ាងនេះក្តី ដូចទៅនឹងកិច្ចខិតខំប្រឹងប្រែងសន្តិភាពនាពេលកន្លងមកដែរ ការទាមទារកម្មសិទ្ធិលើដែនអធិបតេយ្យភាពដែលត្រួតស៊ីគ្នា នៅតែជាបុសគល់នៃបញ្ហាប្រឈមដ៏រ៉ាំរ៉ៃកំពុងបន្តកើតមានឡើង។ ដូច្នេះ ខណៈពេលដែលនេះ គឺជាឱកាសដ៏សំខាន់ដើម្បីទទួលស្គាល់ការដឹកនាំរបស់សហរដ្ឋ

អាមេរិកចំពោះបញ្ហាដ៏សំខាន់ៗទាំងនេះ រដ្ឋាភិបាលថៃនៅមានកិច្ចការជាច្រើនទៀត ដែលកំពុងបន្តជួបការលំបាកក្នុងការអនុវត្តតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងសន្តិភាពមុនៗ ចំពេលមានភាពមិនប្រាកដប្រជានយោបាយផ្ទៃក្នុង និងជម្លោះ។



រូបបដិមាព្រះសង្ឃ នៅខេត្តស្ទឹងត្រែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# រថភ្លើង

ឆាំង យុ



*មេដឹកនាំខ្មែរក្រហមជិះនៅលើរថភ្លើង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)។*
*(មជ្ឈមណ្ឌលឯកសារកម្ពុជា)*

អ្នកដំណើរតាមរថភ្លើងនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន គួរតែចងចាំថាមធ្យោបាយធ្វើដំណើរនេះ មានប្រវត្តិសាស្ត្រយ៉ាងសម្បូរបែប។ ដូចគ្នាទៅនឹងប្រវត្តិសាស្ត្រដទៃទៀតដែរ ប្រវត្តិសាស្ត្ររថភ្លើងបានជះឥទ្ធិពលយ៉ាងសំខាន់ចំពោះសង្គម ដោយរួមទាំងឥទ្ធិពលវិជ្ជមាន និងអវិជ្ជមានទៅលើផ្លូវចិត្ត។ មធ្យោបាយដឹកជញ្ជូនសាធារណៈគឺជាប្រភពនៃការវិវត្តខ្លួនរបស់សង្គមមនុស្ស តាមរយៈការផ្សារភ្ជាប់ទំនាក់ទំនងរវាងមនុស្ស សហគមន៍និងប្រជាជាតិទាំងមូល។

អំឡុងរបបខ្មែរក្រហម ប្រព័ន្ធផ្លូវដែកនៅប្រទេសកម្ពុជា មិនត្រឹមតែត្រូវបានប្រើប្រាស់សម្រាប់ការអភិវឌ្ឍន៍ដែលផ្តល់ផលវិជ្ជមានសម្រាប់សង្គមមនុស្សតែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងត្រូវបម្រើដល់គោលបំណងទុច្ចរិត ដូចជាការបង្ក្រាប ការដកហូតសិទ្ធិអំណាច និងការបំផ្លិចបំផ្លាញសហគមន៍វប្បធម៌ និងប្រជាជន។ ខ្មែរក្រហមបានប្រើប្រាស់រថភ្លើង និងមធ្យោបាយដឹកជញ្ជូនផ្សេងៗទៀត ដើម្បីជម្លៀសប្រជាជនដោយបង្ខំ ចាកចេញពីផ្ទះសម្បែងរបស់ខ្លួន ទៅកាន់ទីជនបទដាច់ស្រយាល ក្នុងគោលបំណងបម្រើដល់មនោគមវិជ្ជាសេដ្ឋកិច្ច និងនយោបាយជ្រុលនិយមហួសហេតុរបស់ខ្លួន ដែលបានបង្កជាការបំផ្លិច

បំផ្លាញចំពោះប្រជាជាតិកម្ពុជា។ ខណៈពេលដែលរថភ្លើងគឺជាសមិទ្ធផលដ៏លេចធ្លោ តំណាងឱ្យនិមិត្តរូបនៃជោគជ័យ និងវឌ្ឍនភាពរបស់មនុស្សជាតិ យើងមិនត្រូវបំភ្លេចប្រវត្តិសាស្ត្រដ៏សោកសង្រេងនេះទេ។

អ្នកដំណើរតាមរថភ្លើងនៅសម័យបច្ចុប្បន្នគួរតែត្រូវបានក្រើនរំឭកអំពីប្រវត្តិសាស្ត្រដ៏ស្មុគស្មាញនៃមធ្យោបាយធ្វើដំណើរនេះ។ ការរំឭកឡើងវិញនេះ មិនមែនដើម្បីបន្ទុចបង្អាក់តម្លៃ និងភាពងាយស្រួលនៃមធ្យោបាយធ្វើដំណើរនេះ ឬធ្វើឱ្យខូចអារម្មណ៍រីករាយរបស់អ្នកដំណើរពីការជិះរថភ្លើងទេ ប៉ុន្តែគឺដើម្បីធានាថាអ្នកដំណើរទាំងអស់ បានយល់ដឹងថារាល់បច្ចេកវិទ្យាដ៏អស្ចារ្យ និងសមិទ្ធផលដ៏ធំធេងរបស់មនុស្សជាតិគឺតែងបង្កប់នូវលទ្ធភាពដែលអាចត្រូវបានប្រើប្រាស់បម្រើដល់គោលបំណងទុច្ចរិត។

ប្រវត្តិសាស្ត្រដ៏ស្មុគស្មាញរបស់រថភ្លើងគឺជាមេរៀនមួយដែលមនុស្សជាតិបានបំភ្លេច ហើយយើងត្រូវសិក្សាឈ្វេងយល់សារជាថ្មីម្តងហើយម្តងទៀត។ ហេតុដូច្នេះ ការឈ្វេងយល់ពីប្រវត្តិសាស្ត្រដ៏ស្មុគស្មាញរបស់រថភ្លើង គួរតែត្រូវបានបញ្ចូលជាគោលការណ៍សីលធម៌ក្នុងជីវិតរស់នៅដ៏សាមញ្ញប្រចាំថ្ងៃ។



យោធាខ្មែរក្រហមជិះនៅលើរថភ្លើង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)។
(មជ្ឈមណ្ឌលឯកសារកម្ពុជា)



កម្មាភិបាល និងប្រជាជនធ្វើការងារនៅតាមសហករណ៍ឈរនៅអមសងខាងផ្លូវរថភ្លើង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)។
(មជ្ឈមណ្ឌលឯកសារកម្ពុជា)



អៀង សារី (រូបដើរខាងមុខ) ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) រួមជាមួយមេដឹកនាំខ្មែរក្រហមចុះពិនិត្យផ្លូវរថភ្លើង។ (មជ្ឈមណ្ឌលឯកសារកម្ពុជា)



ប្រជាជនរែកសំណាបនៅតាមបណ្តោយផ្លូវរថភ្លើង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)។
(មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រះ ម៉ាត់ ៖ ការរត់គេចចេញពីរបបខ្មែរក្រហម ដោយមិនជោគជ័យ

*លី សុខឃាង*



*កម្មាភិបាលខ្មែរក្រហមនៅសហករណ៍។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ប្រះ ម៉ាត់បានឆ្លើយនៅក្នុងចម្លើយសារភាពរបស់ខ្លួន ចុះកាលបរិច្ឆេទថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៧ អំពីការណែនាំឱ្យរត់គេចខ្លួន និងការសម្រេចចិត្តគេចខ្លួនជាមួយគ្នីគ្នាចំនួន៤នាក់ផ្សេងទៀត។ ការរត់គេចខ្លួនចូលក្នុងព្រៃ ក្នុងគោលបំណងធ្វើដំណើរឆ្ពោះទៅប្រទេសថៃ គឺមិនបានជោគជ័យទេ។ បន្ទាប់ពីការធ្វើដំណើរអស់រយៈពេលជាងដប់ថ្ងៃ អ្នកទាំងបីត្រូវបានកងទ័ពខ្មែរក្រហមឃាត់ខ្លួន ខណៈដែលម្នាក់ទៀតបានបែកគ្នាយ៉ាងអាថ៌កំបាំងនៅក្នុងព្រៃ។ ម៉ាត់ បានឆ្លើយសារភាពដូចខាងក្រោម៖

ប្រះ ម៉ាត់មានទីកន្លែងកំណើតនៅភូមិកប់ភ្លុក ឃុំភ្លើងឆេះរទេះ ស្រុកដង្កោ ខេត្តកណ្ដាល។ ឪពុករបស់ម៉ាត់ឈ្មោះ ប្រះ នន់ (ស្លាប់) និងម្ដាយឈ្មោះ ថៃ សួន ដែលអ្នកទាំងពីរប្រកបរបរត្បាញបង្គី សម្រាប់លក់ចិញ្ចឹមជីវិត។ ម៉ាត់ មានបងប្អូនបង្កើតចំនួន៦នាក់ (ប្រុស៥នាក់ និងស្រី១នាក់)។ ម៉ាត់រស់នៅជាមួយឪពុកម្ដាយរហូតដល់ឆ្នាំ១៩៦៨ ដែលនៅពេលនោះ ម៉ាត់ ចាប់ផ្ដើមរៀបគ្រួសារ។ ម៉ាត់ បានប្រកបរបរជាច្រើនដើម្បីចិញ្ចឹមគ្រួសាររួមមាន៖ រែកដី ជាងផ្ទះ ធ្វើម៉ុងចិន និងធាក់រ៉ឺម៉កជាដើម។ នៅក្នុងខែតុលា ឆ្នាំ១៩៧៣ ម៉ាត់ ក៏បានចូលបម្រើជាកងស្ម័យត្រាណ នៅក្នុងឃុំភ្លើងឆេះរទេះ បន្ទាប់ពីទទួលបានការអប់រំបំពាក់បំប៉នពី កាន ដែលជាមេឃុំ។ ភារកិច្ចរបស់

ម៉ាត់ គឺស៊ើបការពិនិត្យរកកងទ័ពរំដោះ និងតាមដានប្រជាជន។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ម៉ាត់ត្រូវបានអង្គការជម្លៀសទៅកាន់ភូមិធាយ ឃុំវត្តអង្គ ស្រុកទូកមាស តំបន់៣៥។ ម៉ាត់ បានបញ្ជាក់ថា ខ្លួនមិនដែលធ្វើអ្វីឱ្យប៉ះពាល់ដល់មាតិការបស់បក្សទេ នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧។ ម៉ាត់ ក៏ធ្លាប់ត្រូវបានអង្គការចាត់ឱ្យទៅធ្វើការងារនៅឃុំដូច និងឃុំសំរោង នៃស្រុកដដែល រយៈពេលមួយខែ។

នៅពេលត្រឡប់ពីការងារនៅក្នុងឃុំទាំងពីរ ម៉ាត់ ក៏បានផ្លៀតទៅអង្គុយលេងផ្ទះ តានី ដែលស្ថិតនៅចម្ងាយតែ៨ម៉ែត្រប៉ុណ្ណោះពីផ្ទះរបស់ខ្លួន។ តានីក៏ចាប់ផ្ដើមសួរ ម៉ាត់ ថា៖ «តើម៉ាត់ឯងមានដឹងរឿងទេ?»។ ម៉ាត់ ក៏ឆ្លើយថា ខ្លួនមិនដឹងរឿងអ្វីទេ។ តានី ក៏បានប្រាប់ម៉ាត់ថា ក្នុងពេលដែលម៉ាត់កំពុងធ្វើការងារនៅឯឃុំទាំងនោះ អង្គការបានបញ្ជូនមនុស្ស៤នាក់ឱ្យទៅរៀនសូត្រ។ តានីបញ្ជាក់ទៀតថា៖ «រូបអ្នកណាក៏ដូចរូបអ្នកណាដែរ ឱ្យតែអង្គការតម្រូវទៅរៀនសូត្រ គឺមិនសូវឃើញត្រឡប់មកផ្ទះវិញទេ»។ តានីក៏បានប្រាប់ឱ្យម៉ាត់រត់គេចខ្លួន ក្រែងលោបានរួចខ្លួន។ ការសន្ទនារបស់អ្នកទាំងពីរក៏ត្រូវបានផ្អាក ដោយសារតែមានប្រជាជនដើរកាត់មុខផ្ទះ។

នាល្ងាចម៉ោង៧ នៃថ្ងៃបន្ទាប់ អ្នកទាំងពីរជួបនិយាយគ្នាបន្តទៀត។ តានីបានប្រាប់ថាអ្នកទាំងឡាយដែលធ្លាប់ធ្វើការងារនៅក្នុងទឹកដីខ្មាំងកាលពីមុន ត្រូវបានអង្គការបញ្ជូនទៅរៀនសូត្រជាបន្តបន្ទាប់។ តានីក៏បានសួរអំពីការសម្រេចចិត្តរបស់ម៉ាត់។ ម៉ាត់ ក៏បានបង្ហាញពីភាពស្ទាក់ស្ទើរ ដោយហេតុថាមានកងទ័ពខ្មែរក្រហមច្រើនណាស់។ តានីក៏បន្តក្រើនរំឭកថា បើមិនគេចខ្លួនទេ ម៉ាត់ ប្រាកដជាត្រូវស្លាប់ជាក់ជាពុំខាន។ តានី ក៏បាននិយាយទៀតថា៖ «ម៉ាត់ អើយជឿតាទៅ តាមិនបេះភូតភរទេ ពេលរៀបចេញទៅ ម៉ាត់ឯងទៅយកក្រមាពីប្រពន្ធខ្ញុំមួយទៅ ខ្ញុំបានប្រាប់គាត់ហើយ»។ នៅពេលនោះ ម៉ាត់ក៏បានយល់ស្របជាមួយតានី ហើយតានីបានប្រាប់ថា មនុស្សពីរនាក់ទៀតរួមមាន វុធ និង ស៊ុន ក៏នឹងរួមដំណើរនេះដែរ។ អ្នកទាំងពីរនាក់ក៏ត្រូវផ្អាកនិយាយគ្នាទៀត ដោយសារតែបានឮមាត់ប្រធានសហករណ៍ ដែលកំពុងដើរសំដៅមករកខ្លួន។

លុះព្រឹកឡើង ម៉ាត់ ក៏បានធ្វើការងារធម្មតា និងបានជួបជាមួយ វុធ និង ស៊ុន ដែលអ្នកទាំងពីរក៏បានទទួលការណែនាំពី តានី ដូចគ្នា។ ស៊ុន ក៏បានប្រាប់ម៉ាត់ ថា កែម ក៏នឹងរួមដំណើរនៅក្នុងការរត់គេចខ្លួននេះដែរ។ ម៉ាត់ក៏បានទទួលការបញ្ជាក់ពី វុធ ដែរថា ខ្លួនក៏នឹងរត់គេចខ្លួនដែរ ដោយកំណត់យកវេលាម៉ោង៨យប់ និងទីតាំងរោងស្ករចាស់ នៃភូមិកន្ទឹម ដែលជាទីណាត់ជួបគ្នា។

ដូចការណាត់ អ្នកទាំងបួនក៏បានជួបគ្នា ហើយ កែម បាននិយាយថា ខ្លួនអាចចិញ្ចឹមមិត្តទាំងអស់គ្នានៅក្នុងក្រុមដោយមិនឱ្យដាច់ពោះទេ។ ប៉ុន្តែយើងត្រូវធ្វើដំណើរឱ្យដល់ទឹកដីសៀម តាមផ្លូវភ្នំល្អាង និងផ្លូវតានី ដែលជាផ្លូវដឹកខ្សាច់។ បន្ទាប់ពីធ្វើដំណើរអស់រយៈពេលមួយយប់មួយថ្ងៃ អ្នកទាំងបួនក៏បានទៅដល់ភ្នំក្រាំងលាវ និងបានឮសំឡេងកូនគោស្រែក។ ដោយសារតែភាពហេវហត់ អ្នកទាំងបួនក៏គិតគូររកម្ហូបអាហារ និងបានស្រុះស្រួលគ្នាដើរសំដៅទៅកូនគោនោះ។ អ្នកទាំងបួនក៏ស្រាប់តែប្រទះឃើញបុរសម្នាក់បររទេះគោ និងកុមារម្នាក់រួមជាមួយឆ្កែពីរក្បាលផង។ ដោយសារឆ្កែព្រុសខ្លាំងពេក អ្នកទាំងបួនក៏នាំគ្នារត់រកកន្លែងពួន។ បន្ទាប់ពីបុរសនោះបររទេះផុតទៅ ម៉ាត់បាននិយាយថា កែម បាត់ខ្លួនឈឹង ដោយមិនដឹងទៅទីណាទេ។ ម៉ាត់ បានបន្តថា មិត្តក្នុងក្រុមនៅសល់តែបីនាក់ទេ ប៉ុន្តែនៅតែប្ដេជ្ញាថានឹងបន្តដំណើរទៅមុខទៀត ក្នុងទិសដៅឆ្ពោះទៅប្រទេសសៀមដដែល។

ម៉ាត់ ក៏បានឆ្លើយទៀតថា ខ្លួននិងមិត្តរួមដំណើរពីរនាក់ទៀត ក៏នាំគ្នាដើរបណ្ដើរ និងនិយាយគ្នាបណ្ដើរអស់រយៈពេល១០ថ្ងៃទៀត ដែលនៅពេលនោះក៏បានជួបជាមួយកងទ័ពការពារផ្លូវជាតិលេខ៤។ កងទ័ពក៏បានសាកសួរ និងនាំយកអ្នកទាំងបីទៅកាន់ទីតាំង

កងទ័ព។ បន្ទាប់ពីផ្តល់បាយឱ្យហូបរួចមក ខ្លួន និងមិត្តរួមដំណើរទាំងពីរ វុធ និង ស៊ីន ត្រូវបានឃាត់ខ្លួនតែម្តង នៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៧។

ចម្លើយសារភាពរបស់ម៉ាត់ ក៏បានចង្អុលបង្ហាញឈ្មោះ និងភិនភាគសម្គាល់របស់អ្នកដែលរួមសកម្មភាពចំនួនពីរនាក់ រួមមាន៖ (១) តានី ដែលមានអាយុ៦០ឆ្នាំ និងមានតួនាទីជាសមាជិកសេដ្ឋកិច្ចសហករណ៍ភូមិធាយ មានកម្ពស់១ម៉ែត្រ៦០ សម្បុរសល្អម ក្បាលធំ ភ្នែកធំ ដាក់ធ្មេញមាសមួយក្រាស់ខាងលើ ស្លាកស្នាមបាក់ជើងស្តាំ និងមានប្រពន្ធចំនួនពីរ(ស្លាប់មួយ) និងមានកូនចំនួន៧នាក់។ (២) កែម ដែលមានអាយុ៣៩ឆ្នាំ និងមានតួនាទីជាសមាជិកសហករណ៍ភូមិធាយ មានកម្ពស់១ម៉ែត្រ៦៥ សម្បុរខ្មៅ មាឌធំមាំ ក្បាលធំ ភ្នែកល្អម ដុះពុកមាត់ច្រើន ដាក់ធ្មេញមាសថ្គាមចំនួនមួយ និងមានប្រពន្ធព្រមទាំងកូនចំនួន៥នាក់។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ J00២៦២ រាល់ចម្លើយសារ ភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និង ធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម។ ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ ប្រុះ ម៉ាត់ ពិតប្រាកដឬយ៉ាងណានោះទេ។**



កម្មាភិបាលខ្មែរក្រហមនៅតាមសហករណ៍។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ទិដ្ឋភាពនៅតំបន់ព្រំដែនលើកំពូលភ្នំដងរែក ស្ថិតក្នុងបន្ទាត់ក្រហម

**មេក ទិន និង លី សុខឃាង**



ទិដ្ឋភាពនៅតំបន់ព្រំដែនលើកំពូលភ្នំដងរែក ក្នុងស្រុកអន្លង់វែង ស្ថិតក្នុងបន្ទាត់ក្រហម នៅថ្ងៃពុធ ទី១៨ ខែមករា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃពុធ ទី១៨ ខែមករា ឆ្នាំ២០២៦ ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ទទួលបានការអនុញ្ញាតពីសមត្ថកិច្ចពិនិត្យប្រចាំការនៅក្នុងតំបន់បន្ទាត់ក្រហមឱ្យចូលទៅពិនិត្យមើលការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង (អតីតផ្ទះប្រជុំតាម៉ុក លើកំពូលភ្នំដងរែក)។ ទិដ្ឋភាពនៅតាមបណ្តោយបន្ទាត់ព្រំដែនលើភ្នំដងរែក និងភូមិឋានមួយចំនួនដែលស្ថិតនៅក្នុងបន្ទាត់ក្រហម មានសភាពស្ងាត់ជ្រងំគ្មានមនុស្សរស់នៅប្រៀបបានដូចជាទីរហោឋាន។ ភូមិឋានធ្លាប់តែមានមនុស្សរស់នៅ លក់ដូរអ៊ូអរ បែរជាលែងមានមនុស្សរស់នៅ។ នៅតាមផ្លូវធ្វើដំណើរធ្លាប់តែមានចរាចរណ៍ចេញចូលប្រែជាគ្មានយានយន្ត ឡាន ម៉ូតូ កង់ ធ្វើដំណើរទៅវិញ។

សាលាបឋមសិក្សាស្រះឈូក រួមទាំងសាលាបឋមសិក្សាអូរក្រញូង ត្រូវបានបិទទ្វារមិនទាន់បើកដំណើរការនៅឡើយទេ ដែលជាហេតុធ្វើឱ្យសិស្សានុសិស្សត្រូវផ្អាកការសិក្សារៀនសូត្ររយៈពេលយូរ។ ចំណែកឯសិស្សានុសិស្សនៅតាមអនុវិទ្យាល័យ និងវិទ្យាល័យអន្លង់វែង ថ្នាក់ដឹកនាំសាលាមិនអនុញ្ញាតឱ្យសិស្សធ្វើដំណើរចេញពីសាលានោះទេ។ ការធ្វើបែបនេះ គឺជាការការពារសុវត្ថិភាពដល់សិស្សគ្រប់រូប អំឡុងពេលព្រំដែននៅមិនទាន់ស្ងប់ស្ងាត់។ អាស្រ័យ

ហេតុនេះហើយ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងក៏បានរំកិលសកម្មភាពថ្នាក់រៀនទៅតាមកាលវិភាគបន្តបន្ទាប់វិញ។

បន្ថែមពីនេះទៀត នៅតាមផ្ទះប្រជាពលរដ្ឋ និងទីតាំងមួយចំនួនដែលទទួលរងការប៉ះពាល់ពីការទម្លាក់គ្រាប់បែករបស់យោធាថៃ បន្តឱ្យមានសភាពខូចខាតទាំងស្រុង និងនៅមិនទាន់មានការរៀបចំបោសសម្អាតឡើងវិញនៅឡើយទេ។ ទង្វើយោធាថៃបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់រចនាសម្ព័ន្ធស៊ីវិលកម្ពុជាជាច្រើន។ ទីតាំងអគារផ្សារអន្តរជាតិជាំ និងកាស៊ីណូរួមទាំងផ្ទះប្រជាជននៅក្បែរនោះ ត្រូវបានឆេះខូចខាតទ្រព្យសម្បត្តិគ្មានសេសសល់។

ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានធ្វើដំណើរឡើងទៅភូមិឋាននៅលើខ្នងភ្នំដងរែក និងច្រកទ្វារអន្តរជាតិជាំ។ យើងបានឃើញទីតាំងគ្រាប់ផ្លោងជាច្រើនដែលត្រូវបានដាក់សញ្ញាសម្គាល់រួចជាស្រេច ភាពខូចខាតនៃដំបូលផ្សារអន្តរជាតិជាំ ដំបូល និងបង្អួចនៃកាស៊ីណូជាំ ព្រមទាំងស្លាកស្នាមនៃការឆាបឆេះផ្ទះប្រជាពលរដ្ឋនៅក្បែរច្រកទ្វារអន្តរជាតិជាំ។ ទិដ្ឋភាពជាក់ស្តែងទាំងនេះត្រូវបានបង្កឡើងដោយយោធាថៃ ដែលបើកការវាយប្រហារដោយរថក្រោះ និងកាំភ្លើងផ្លោងជាច្រើនប្រភេទ បាញ់ប្រហារមករយៈពេលប្រមាណជា៥ម៉ោង ចាប់ពីម៉ោង៧ព្រឹករហូតដល់ម៉ោង១២ថ្ងៃត្រង់ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៥កន្លងមក។

ហេតុដូច្នេះហើយ តំបន់ខ្នងភ្នំដងរែក និងច្រកទ្វារអន្តរជាតិជាំ ស្ថិតនៅក្នុងតំបន់គ្រោះថ្នាក់នៅឡើយ ព្រោះអ្នកជំនាញនៅមិនទាន់រៀបចំបោសសម្អាតអំបែងគ្រាប់ និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ។






ទិដ្ឋភាពនៅតំបន់ព្រំដែនលើកំពូលភ្នំដងរែក ក្នុងស្រុកអន្លង់វែង ស្ថិតក្នុងបន្ទាត់ក្រហម នៅថ្ងៃពុធ ទី១៤ ខែមករា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប៊ូ សុភាន់ ៖ ដង្ហើយរកយុត្តិធម៌សម្រាប់ប្តី និងក្រុមគ្រួសារ

ផាច សម្ភស្ស



អ្នកស្រី ប៊ូ សុភាន់ (អង្គុយកណ្តាល) និងប្រជាជនរងគ្រោះនៅឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អ្នកស្រី ប៊ូ សុភាន់ មានជំងឺបេះដូងប្រចាំកាយ បានរៀបរាប់ទាំងទឹកភ្នែកថា កាលពីរសៀលថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០២៥ ប្តីខ្ញុំឈ្មោះ រិទ្ធ ផ្លូន អាយុ៤៧ឆ្នាំ បានត្រូវអំបែងគ្រាប់ផ្លោងរបស់ទាហានថៃធ្លាក់មកបំស្នា និងបាក់ឆ្អឹងខ្នងនៅក្នុងភូមិស្ពាន ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ ប្តីខ្ញុំបានស្លាប់ដោយសាររបួសធ្ងន់ធ្ងរ នៅខណៈពេលបញ្ជូនមកព្យាបាលនៅមន្ទីរពេទ្យមង្គលបុរីនាយប់ថ្ងៃដដែលនោះ។ អ្នកស្រី ប៊ូ សុភាន់បានរៀបរាប់រឿងរ៉ាវរបស់ខ្លួន និងប្តីដូចខាងក្រោម៖

ខ្ញុំឈ្មោះ ប៊ូ សុភាន់ ភេទស្រី អាយុ៤៤ឆ្នាំ មានស្រុកកំណើតនៅភូមិគោករមៀត ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ បច្ចុប្បន្នខ្ញុំរស់នៅភូមិស្ពាន ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយ-មានជ័យ។ ខ្ញុំមានមុខរបរធ្វើស្រែ និងស៊ីឈ្នួល។ ប្តីខ្ញុំឈ្មោះ រិទ្ធ ផ្លូន អាយុ៤៧ឆ្នាំ មានស្រុកកំណើតនៅភូមិគោកព្រេច ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ ខ្ញុំរៀបការឆ្នាំ១៩៩៨។ ខ្ញុំមានកូនចំនួន៥នាក់ នៅឆ្នាំ២០០៧ ខ្ញុំបានបែកពីឪពុកម្តាយ និងផ្លាស់មករស់នៅភូមិស្ពាន ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។

អំឡុងពេលផ្ទុះអាវុធកម្ពុជា-ថៃលើកទី១ ចន្លោះថ្ងៃ២៤-២៨ ខែកក្កដា ឆ្នាំ២០២៥ ប្រជាពលរដ្ឋនៅក្នុងភូមិស្ពាន ឃុំគោករមៀត ស្រុកថ្មពួក ខេត្ត

បន្ទាយមានជ័យ មិនមានភៀសសឹកឡើយ ពីព្រោះសភាពការណ៍នៅក្នុងភូមិស្ងប់ស្ងាត់ធម្មតាៗអំឡុងពេលផ្ទុះអាវុធកម្ពុជា-ថៃលើកទី២ គឺចាប់ពីម៉ោង៣រសៀលថ្ងៃទី៨ ខែធ្នូឆ្នាំ២០២៥ ទាហានថៃបានបាញ់គ្រាប់ផ្លោងចូលក្នុងភូមិស្ពាន ឃុំគោករមៀត ស្រុកថ្មពួកជាច្រើនគ្រាប់ៗ ពេលនេះខ្ញុំបានឃើញគ្រាប់ផ្លោងរបស់ថៃមួយគ្រាប់ហោះមកត្រូវចំស្ពាននៅក្បែរសាលារៀនក្នុងភូមិស្ពានៗ ខ្ញុំឃើញប្រជាពលរដ្ឋភៀសខ្លួនចេញពីភូមិខាងលិចមកជាច្រើនៗ ប្តីខ្ញុំឃើញដូច្នេះបានរៀបចំអីវ៉ាន់ដាក់គោយន្តរួចប្រាប់ខ្ញុំថាឱ្យទៅមុន ខ្ញុំបានគ្រាម្ដាយចាស់ និងកូនសរុបចំនួន៤នាក់បានចេញទៅឃុំគោកកថិន ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យៗ ចំណែកប្តីខ្ញុំនៅចាំផ្ទះ ដាក់បាយជ្រូក និងយាមផ្ទះៗ ពេលព្រលប់ៗខ្ញុំបានទៅដល់ឃុំគោកកថិន ខ្ញុំឃើញប្រជាពលរដ្ឋភៀសខ្លួនមកជាច្រើនរាប់រយ រាប់ពាន់នាក់ៗ បន្តិចក្រោយមកខ្ញុំបានទទួលទូរសព្ទរបស់អ្នកភូមិស្ពានប្រាប់ថា ប្តីខ្ញុំត្រូវគ្រាប់ផ្លោង អ្នកភូមិបញ្ជូនទៅមន្ទីរពេទ្យថ្មពួកៗ បន្ទាប់មកក្រុមគ្រូពេទ្យបានបញ្ជូនបន្តទៅមន្ទីរពេទ្យមង្គលបុរីៗ ពេលនោះខ្ញុំកំពុងតែជិះគោយន្តមិនទាន់ទៅដល់ឃុំគោកកថិនស្រួលបួលផង ខ្ញុំបានដើររកឡានជិះទៅមើលប្តីខ្ញុំនៅមន្ទីរពេទ្យមង្គលបុរីទាំងយប់ៗ ពេលទៅដល់មន្ទីរពេទ្យដំបូង គ្រូពេទ្យបានប្រាប់ខ្ញុំថា ប្តីនៅមានសង្ឃឹម៧០ភាគរយៗ បន្ទាប់មកគ្រូពេទ្យប្រាប់ថារៀបចំបញ្ជូនប្តីខ្ញុំទៅភ្នំពេញ ប៉ុន្តែមិនទាន់បានឡើងដល់ឡានផង គ្រូពេទ្យបានរុញប្តីខ្ញុំត្រឡប់ទៅបន្ទប់អ្នកជំងឺវិញៗ នៅវេលាម៉ោងប្រហែល១២អាធ្រាតពេទ្យប្រាប់ឱ្យខ្ញុំត្រៀមចិត្ត ប្តីខ្ញុំបានស្លាប់ហើយៗ

ប្តីខ្ញុំត្រូវគ្រាប់ផ្លោងរបស់ទាហានថៃចំស្មា និងបាក់ឆ្អឹងខ្នង គាត់ត្រូវគ្រាប់ផ្លោងនៅជិតរណ្ដៅលេណដ្ឋានក្បែរផ្ទះបងជីដូនមួយខ្ញុំនៅក្នុងភូមិស្ពាន ពេលនោះពួកគាត់មានគ្នា៣នាក់៖ ប្តីខ្ញុំត្រូវអំបែងគ្រាប់ចំស្មា បាក់ឆ្អឹងខ្នងស្លាប់នៅមន្ទីរពេទ្យមង្គលបុរី ឪពុកមាខ្ញុំឈ្មោះ ខ្វាន់ ហេង ត្រូវក្បាលខាងក្រោយស្លាប់នៅពេទ្យលោកសង្ឃ បងប្រុសជីដូនមួយខ្ញុំ ឈ្មោះ ថ្លៃ ទិត ត្រូវរបួសដៃៗ

ខ្ញុំបានយកសពប្តីចេញពីពេទ្យ ទៅបូជានៅវត្តថ្មពួកទាំងយប់ថ្ងៃដដែលនោះពីព្រោះទាហានថៃបាញ់កាន់តែខ្លាំងហើយប្រជាពលរដ្ឋបានភៀសសឹកកាន់តែច្រើនៗ ពេលខ្ញុំដឹកសពប្តីខ្ញុំមកវត្តថ្មពួក ដោយគិតថានៅទីរួមស្រុកថ្មពួកមិនទាន់ក្ដៅខ្លាំង ហើយយើងអាចរៀបចំពិធីបុណ្យសពបាន ប៉ុន្តែពេលខ្ញុំដឹកសពប្តីខ្ញុំមកដល់ស្ពានទី៨នៅទ្រាស ទាហានថៃបានបន្តបាញ់ផ្លោងចូលដល់ទីរួមស្រុកថ្មពួកៗ ខ្ញុំបន្តដឹកសពប្តីរហូតដល់វត្តថ្មពួក ខ្ញុំឮសូរគ្រាប់ផ្លោងរបស់ថៃកាន់តែខ្លាំងឡើងៗៗ ខ្ញុំមិនបានរៀបចំពិធីបុណ្យសពប្តីធំដុំទេៗ ពេលធ្វើបុណ្យមានគ្នា៤ ទៅ១០នាក់ និងព្រះសង្ឃ៥អង្គប៉ុណ្ណោះៗ ខ្ញុំបូជាសពប្តីរួចរហូតដល់ម៉ោង៥ព្រឹកទើបរើសធាតុ ខ្ញុំឱបធាតុប្តីរត់ទៅពន្លៃស្វាយស ស្រុកភ្នំស្រុកៗ បន្ទាប់មកខ្ញុំបានរៀបចំពិធីបុណ្យ៧ថ្ងៃប្តីបង្គ្រប់កិច្ចនៅវត្តត្រពាំងថ្ម ជាទីកន្លែងដែលខ្ញុំភៀសសឹកទៅស្នាក់នៅៗ ខ្ញុំបាននិមន្តព្រះសង្ឃចំនួន៥អង្គមកសូត្រធម៌ ដោយមានបាយសម្លបន្តិចបន្តួចប៉ុណ្ណោះៗ ខ្ញុំភៀសសឹកមកស្នាក់នៅវត្តត្រពាំងថ្មរយៈពេល៧ថ្ងៃ ខ្ញុំបានត្រឡប់មកមើលផ្ទះម្ដង ដើម្បីយកស្រូវយកអង្ករមកហូបៗ នៅចុងខែធ្នូឆ្នាំ២០២៥ ខ្ញុំត្រឡប់មករស់នៅផ្ទះវិញ រួចយកធាតុប្តីទៅដាក់នៅក្នុងចេតិយឪពុកក្មេកខ្ញុំនៅភូមិគោកព្រេច ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យៗ ខ្ញុំមានការឈឺចាប់ និងសោកស្ដាយខ្លាំងចំពោះកងទ័ពថៃដែលបានបាញ់ផ្លោងដាក់ប្រជាពលរដ្ឋស្លូតត្រង់ដែលមិនដឹងរឿងៗ ខ្ញុំចង់ឱ្យអន្តរជាតិដាក់ទោសថៃដែលឈ្លានពានមកលើខ្មែរបាញ់មកលើប្រជាពលរដ្ឋស្លូតត្រង់ៗ ថៃបានធ្វើឱ្យខ្ញុំបែកបាក់គ្រួសារ និងត្រូវរស់នៅដោយគ្មានប្តី ខ្ញុំពិបាកខ្លាំងណាស់ៗ កាលពីប្តីខ្ញុំនៅរស់ ពេលខ្ញុំឈឺ ទោះអត់មានលុយយ៉ាងណាក៏ប្តីបង្ខំឱ្យទៅពេទ្យដែរៗ ប្តីខ្ញុំសុខចិត្តខ្ចីលុយគេជំពាក់គេៗ បន្ទាប់មកប្តីខ្ញុំខំប្រឹងរកស៊ីសងលុយគេវិញ ដើម្បីឱ្យប្រពន្ធមានសុខភាពល្អ និងជាសះស្បើយៗ ពេលអត់ពីប្តីទៅ ខ្ញុំនឹកឃើញគ្រប់បែបយ៉ាង ព្រោះឥឡូវខ្ញុំកំពុងមានជំងឺបេះដូងប្រចាំកាយៗ ខ្ញុំមិនដឹងថាមានអ្នកណាត្រូវរកប្រាក់ចិញ្ចឹមកូនទេៗ

# រត់គេចឆ្ពោះទៅទិសឦសាន ៖ ជម្លោះនិងការភៀសសឹក តាមរយៈបទពិសោធន៍របស់ក្រុមគ្រួសារមួយ

សូ ហ្វារីណា



ឈឿម សង្ហារ អាយុ៣៥ឆ្នាំ និងប្រពន្ធឈ្មោះ អ៊ី ស៊ីដា ថតរូបជុំគ្នាជាមួយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឈឿម សង្ហារ អាយុ៣៥ឆ្នាំ និង ប្រពន្ធឈ្មោះ អ៊ី ស៊ីដា អាយុ៣០ឆ្នាំ មានទីលំនៅ ភូមិពង្រ ឃុំបន្ទាយអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ ផ្ទះរបស់គាត់មានចម្ងាយប្រហែល១០គីឡូម៉ែត្រពីប្រកដប់គគីរ ជាប់នឹងខេត្តបុរីរម្យ ប្រទេសថៃ។ គាត់ទាំងពីរមានកូន៣នាក់ (ប្រុស២នាក់ និងស្រី១នាក់)។ កូនប្រុសច្បងអាយុ១១ឆ្នាំ ចំណែកកូនប្រុសនិងស្រីដែលមានអាយុប្រហែល៧ខែ គឺជាកូនភ្លោះដែលប្រសូត្រចេញមកដោយការវះកាត់នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៥។ ក្រុមគ្រួសាររបស់គាត់បានភៀសខ្លួនពីការទម្លាក់គ្រាប់បែករបស់យោធាថៃ តាំងពីភាគឧត្តរ ដល់ភាគពាយ័ព្យ រហូតដល់ភាគឦសាន ដើម្បីស្វែងរកទីតាំងសុវត្ថិភាព ហើយតាំងទីលំនៅបណ្ដោះអាសន្ននៅភូមិពូតាំង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៥។ សង្ហារ សម្លឹងមើលមុខកូនតូចទាំងពីរបណ្ដើរ ពោលពាក្យនេះបណ្ដើរ «គ្នាកើតមកតូចប៉ុណ្ណេះសោះ ស្គាល់រស់ជាតិសង្គ្រាមបាត់ទៅហើយ។ រត់ដល់ទៅ៣ដងហើយ»។ ចំណែក ស៊ីដា និយាយថា «យើងនាំគ្នារត់ឱ្យឆ្ងាយរហូតលែងឮសំឡេងយន្តហោះសៀមទម្លាក់គ្រាប់បែក»។ រយៈពេលជិតមួយខែបន្ទាប់ពីបទឈប់បាញ់កាលពីថ្ងៃទី២៨ ខែធ្នូ ហើយ ឈឿម សង្ហារ និង អ៊ី ស៊ីដា ព្រមទាំងក្រុមគ្រួសារ មិនទាន់បានវិលត្រឡប់ទៅផ្ទះនៅឯខេត្តឧត្តរមានជ័យ

នៅឡើយ ដោយសារគាត់យល់ថា មិនទាន់មានសុវត្ថិភាពពេញលេញនៅឡើយ។

***ខាងក្រោមនេះគឺជាការរៀបរាប់របស់ អ៊ី ស៊ីដា និង ឈឿម សង្ហារ អំពីការជម្លៀសដោយបង្ខំពីទីតាំងមួយទៅទីតាំងមួយទៀតក្នុងអំឡុងខែធ្នូ ឆ្នាំ២០២៥៖***

កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ គឺរយៈពេល ២ថ្ងៃបន្ទាប់ពីទាហានថៃបើកការវាយលុកលើប្រទេសកម្ពុជា ជាលើកទីពីរ ក្នុងឆ្នាំ២០២៥ ខ្ញុំបាននាំកូនភ្លោះតូចរបស់ខ្ញុំអាយុ៧ខែ ព្រមទាំងកូនប្រុសអាយុ១១ឆ្នាំ រត់គេចពីការទម្លាក់គ្រាប់បែក។ ចំណែកប្តីរបស់ខ្ញុំនៅមើលថែផ្ទះ។ នៅពេលយប់ ប្តីខ្ញុំចូលទៅពួននៅក្នុងលេណដ្ឋាននៅក្បែរផ្ទះ។ ខ្ញុំបានមកស្នាក់នៅជាមួយប្អូនថ្លៃនៅឯឃុំបន្ទាយឆ្មារប្រហែលមួយអាទិត្យ។ ដោយសារស្នូរកាំភ្លើងធំនៅតែបន្តឮ ខ្ញុំផ្លាស់ទៅស្នាក់នៅវត្តត្រពាំងស្វាយរយៈពេល២យប់។ បន្ទាប់មកខ្ញុំបន្តទៀតទៅស្នាក់នៅក្បែរអាងត្រពាំងថ្ម ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។ ក្រោយមក ខ្ញុំបានធ្វើដំណើរទៅស្រុកក្រឡាញ់ ខេត្តសៀមរាប។ ដោយសារកូនតូចរបស់ខ្ញុំយំពេក ខ្ញុំបានវិលត្រឡប់មកផ្ទះដើម្បីជួបជុំប្តី នៅភូមិពង្រវិញ។

នៅពេលត្រឡប់មកដល់ផ្ទះវិញ ខ្ញុំនិងគ្រួសារបានចូលពួនក្នុងលេណដ្ឋាននៅក្បែរផ្ទះ។ ដោយសារលេណដ្ឋានមានទំហំតូចមិនអាចផ្ទុកមនុស្សរហូតដល់ ៥នាក់ ប្តីរបស់ខ្ញុំសុខចិត្តចេញមកពួនក្បែរលេណដ្ឋាន ដោយទុកឱ្យខ្ញុំនិងកូនពួននៅទីនោះ។



សិស្សសាលាបឋមសិក្សានៅភូមិពូតាំង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥ ទាហានថៃវាយប្រហារយើងកាន់តែខ្លាំងជាងពេលមុនៗ យើងបានសម្រេចចិត្តរត់ចេញពីផ្ទះជាថ្មីម្តងទៀត ដើម្បីទៅរកកន្លែងដែលមានសុវត្ថិភាព។ យើងបានជិះឡានឈ្នួលទៅស្នាក់នៅជំរំភៀសសឹកនៅឯវិទ្យាល័យប៉ោយចារ ខេត្តបន្ទាយមានជ័យ ដោយស្នាក់នៅទីនោះបានប្រហែល១យប់។ បន្ទាប់មកក៏ធ្វើដំណើរទៅស្រុកក្រឡាញ់ខេត្តសៀមរាប។ យើងធ្វើដំណើរកាន់តែឆ្ងាយកាន់តែល្អ ដោយសារទាហានថៃទម្លាក់គ្រាប់លើសពីទីតាំងសមរភូមិទៀត។ ទាហានថៃធ្លាប់បានទម្លាក់គ្រាប់បែកពីលើយន្តហោះនៅក្បែរជំរំភៀសសឹករបស់យើងជាច្រើនកន្លែង។ ចុងក្រោយ យើងក៏បង្ខំចិត្តធ្វើដំណើរមករស់នៅជាមួយបងស្រី ដែលបានរៀបការជាមួយបងថ្លៃខ្ញុំនៅឯខេត្តមណ្ឌលគិរី ដោយជិះឡានឈ្នួលពីសៀមរាបទៅខេត្តរតនគិរី និងបន្តតាមឡានក្រុងមកខេត្តមណ្ឌលគិរី។ យើងនាំគ្នារត់ឱ្យឆ្ងាយរហូតលែងឮសំឡេងយន្តហោះសៀមទម្លាក់គ្រាប់បែក។



ឈឿម សង្ហារ អាយុ៣៥ឆ្នាំ និង ប្រពន្ធឈ្មោះ អ៊ី ស៊ីដា អាយុ៣០ឆ្នាំ មានទីលំនៅ ភូមិពង្រ ឃុំបន្ទាយអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ភៀសខ្លួនមករស់នៅបណ្តោះអាសន្ននៅភូមិពូតាំង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីធ្វើដំណើរអស់រយៈពេល១៦ម៉ោងគឺចាប់តាំងពីម៉ោង៧ព្រឹក ដល់ម៉ោង ១១យប់ យើងបានឈានជើងចូលមករស់នៅជាមួយបងស្រីនៅភូមិ

ពូតាំង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៥។ នៅទីនេះប្រជាជននិងអាជ្ញាធរមានចិត្តល្អនិងមានភាពរួសរាយរាក់ទាក់ ដល់យើងដែលជាជនភៀសសឹក។



អ៊ី ស៊ីដា អាយុ៣០ឆ្នាំ និងកូនៗទាំងបីនាក់ ភៀសខ្លួនមករស់នៅបណ្ដោះអាសន្ននៅភូមិពូតាំង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៥។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅពេលបទឈប់បាញ់ចូលជាធរមាននៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៥ យើងមានអារម្មណ៍ធូរស្បើយបន្តិច ដោយសារទាហានសៀម លែងទម្លាក់គ្រាប់ដូចមុនទៀត។ ប៉ុន្តែប្រជាជននៅទីនោះនៅតែភ័យខ្លាច ព្រោះមិនទាន់មានសុវត្ថិភាពពេលលេញនៅឡើយទេ។ ទាហានសៀមនៅតែរករឿងយើង ហើយលួចបាញ់ចូលមកទឹកដីកម្ពុជាម្ដងៗ។ ទោះយ៉ាងណា យើងមិនឃើញវីរកងទ័ពកម្ពុជាបាញ់តបតឡើយ ដើម្បីរក្សាភាពស្ងប់ស្ងៀម។

ខ្ញុំនឹកផ្ទះ និងតែងតែទាក់ទងទៅបងប្អូនមួយចំនួនដែលបានវិលចូលភូមិឋានវិញ។ បងខ្ញុំរៀបរាប់ទាំងភ័យ និងយំប្រាប់ខ្ញុំថា «ឯងសំណាងហើយដែលបានចាកចេញផុត។ ទាហានសៀមបានចូលមកទម្លាក់គ្រាប់បែកយ៉ាងគំហុកនិងជ្រៃនៅក្បែរនោះរយៈពេល៣ថ្ងៃចុងក្រោយ។

រហូតមកដល់ពេលនេះ ខ្ញុំមិនទាន់រកការងារជាក់លាក់បានធ្វើនៅឡើយទេ។ អ្នកភូមិបានបបួលខ្ញុំទៅជួយដកដំឡូងមីនៅឯចម្ការ គ្រាន់បានប្រាក់ខ្លះសម្រាប់ទិញទឹកដោះគោ និងអាហារឱ្យកូនៗ ខ្ញុំបានចុះឈ្មោះកូនប្រុសច្បងរបស់ខ្ញុំឱ្យចូលរៀននៅសាលាបឋមសិក្សាពូតាំង ថ្នាក់ទី៥ ដោយមានការស្វាគមន៍យ៉ាងកក់ក្ដៅពីសំណាក់លោកគ្រូអ្នកគ្រូ និងមិត្តរួមថ្នាក់។

ជម្លោះ និងការឈ្លានពានរបស់ថៃ មិនត្រឹមតែបង្កភាពអសន្តិសុខនិងប៉ះពាល់ដល់ជីវភាពរស់នៅប៉ុណ្ណោះទេ ប៉ុន្តែបានបង្កផលប៉ះពាល់ខាងផ្លូវចិត្តដល់អ្នកជម្លៀសដូចជារូបខ្ញុំនិងក្រុមគ្រួសារ។ នៅពេលមកដល់ទីនេះភ្លាមៗ ខ្ញុំនិងក្រុមគ្រួសារនៅតែមានការភ័យខ្លាចនឹងសំឡេងយន្តហោះឬសំឡេងដែលស្រដៀងយន្តហោះ ដោយសារយើងមានអារម្មណ៍ដក់ជាប់នឹងសន្ទឹកយន្តហោះទម្លាក់គ្រាប់របស់ថៃមកលើភូមិឋានរបស់យើង។ សំឡេងនិងទម្ងន់គ្រាប់ដែលបានទម្លាក់នេះខ្លាំងណាស់ រហូតដល់រញ្ជួយដី ទោះយើងស្ថិតនៅជាង១០គីឡូម៉ែត្រក៏ដោយ។

នៅទីនេះ ខ្ញុំមានអារម្មណ៍សុវត្ថិភាពដោយសារស្ថិតនៅឆ្ងាយពីតំបន់ជម្លោះ និងស្ថិតនៅភាគឦសាន។ ខ្ញុំនឹកផ្ទះ និងចង់ត្រឡប់ទៅផ្ទះវិញ ដើម្បីប្រកបរបរស្រែចម្ការចិញ្ចឹមជីវិត ប៉ុន្តែមិនទាន់ហ៊ានត្រឡប់ទៅវិញនៅឡើយទេដោយខ្លាចក្រែងមានការវាយប្រហារពីទាហានថៃទៀត។ ខ្ញុំតែងតែទូរសព្ទសួរសុខទុក្ខបងប្អូននិងសាច់ញាតិនៅឯភូមិ។ ខ្ញុំបន់ស្រន់ឱ្យមានសន្តិភាពឆាប់ៗ ដើម្បីវិលទៅផ្ទះនិងបានជួបជុំសាច់ញាតិវិញ។ ខ្ញុំអាណិតកូនតូចៗទាំងពីរណាស់ គ្នាកើតមកតូចប៉ុណ្ណេះសោះ ស្គាល់រស់ជាតិសង្គ្រាមបាត់ទៅហើយ។ រត់ដល់ទៅ៣ដងហើយ។



រូបចម្លាក់ដំរីនៅក្នុងក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ទន្លេមេគង្គ អ្នកនាំសារដ៏ស្ងៀមស្ងាត់អំពីសង្គ្រាម មកដល់អ្នកភូមិរស់នៅតាមដងទន្លេ

ស្រេង លីដា



ទេសភាពនៅតាមដងទន្លេមេគង្គ ស្រុកបុរីអូរស្វាយសែនជ័យ នាពេលល្ងាចៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពិតជាមិនគួរឱ្យជឿ ដែលប្រទេសថៃហ៊ានធ្វើសង្គ្រាមឈ្លានពានជាលើកទី២ ទៅលើបូរណភាពទឹកដីប្រទេសកម្ពុជានៅព្រឹកថ្ងៃទី៧ ខែធ្នូឆ្នាំ២០២៥ពីព្រោះយើងទើបតែមានសន្តិភាពមកវិញក្រោយពីកិច្ចព្រមព្រៀងសន្តិភាពជាផ្លូវការមួយ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ក្រោមកិច្ចផ្តួចផ្តើមដោយសហរដ្ឋអាមេរិក។

នៅពេលដែលមានសង្គ្រាម ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរក្បែរសមរភូមិត្រូវបានខ្ទេចខ្ទាំភ្លាមៗ ហើយភូមិឋាន និងផ្ទះសម្បែងរបស់ប្រជាជនក្លាយទៅជាតំបន់គ្រោះថ្នាក់ៗ ខណៈពេលដែលប្រជាជនកម្ពុជារាប់សែននាក់ត្រូវបង្ខំចិត្តជម្លៀសចេញពីផ្ទះទៅរកតំបន់សុវត្ថិភាព កងទ័ពកម្ពុជាបានរត់ចូលទៅតំបន់សមរភូមិក្តៅដើម្បីប្រយុទ្ធឈរជើងយ៉ាងរឹងមាំ ការពារបូរណភាពទឹកដីកម្ពុជា។ក្នុងរយៈពេលនេះ ខ្ញុំនិងប្រជាជនដទៃទៀតដែលរស់នៅភូមិមួយក្បែរព្រំដែនកម្ពុជា- ឡាវ បានបន្តតាមដានស្ថានភាពសង្គ្រាម តាមប្រព័ន្ធផ្សព្វផ្សាយ និងស្តាប់ឮសំឡេងផ្ទុះគ្រាប់បែកពីចម្ងាយៗ ខាងក្រោមនេះគឺជាកំណត់ហេតុស្តីពីព្រឹត្តិការណ៍ទូទៅនៅស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ក្នុងរយៈពេលសង្គ្រាមឈ្លានពានពីសំណាក់ប្រទេសថៃមកលើប្រទេសកម្ពុជា៖

## ការប្រើយន្តហោះចម្បាំង F-16 វាយប្រហារលើកម្ពុជាសារជាថ្មី

នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ ខ្ញុំបានអានការចុះផ្សាយអំពីយោធាថៃប្រើប្រាស់យន្តហោះចម្បាំង

F-16 ទម្លាក់គ្រាប់បែកមកលើទឹកដីកម្ពុជាតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ។ រហូតមកដល់ពេលនេះយន្តហោះចម្បាំង F-16 បន្តទម្លាក់គ្រាប់បែកនិងគ្រាប់បែកចង្កោម លើដែនអធិបតេយ្យភាពកម្ពុជាដែលបណ្ដាលឱ្យមានប្រជាជនស្លូតត្រង់បាត់បង់ជីវិត និងបំផ្លិចបំផ្លាញប្រាសាទបុរាណខ្មែរ សាលារៀន វត្តអារាម ផ្ទះ ផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធនានា។ ការទម្លាក់គ្រាប់បែក និងគ្រាប់បែកចង្កោមយ៉ាងសន្ធឹករបស់យោធាថៃ បានរំពុកខ្ញុំអំពីសាច់រឿង និងការភ័យខ្លាចរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិអូរស្វាយ ពីការទម្លាក់គ្រាប់បែបនេះកាលពី៥០ឆ្នាំកន្លងទៅ។

## ទន្លេមេគង្គគឺជាអ្នកនាំសារដ៏ស្ងៀមស្ងាត់អំពីសង្គ្រាម

ទោះបីក្នុងគ្រាមានសង្គ្រាម ខ្ញុំតែងតែអង្គុយមើលទេសភាពដ៏ស្រស់ត្រកាលនៃសុរិយាអស្តង្គតលើផ្ទៃទឹកទន្លេមេគង្គនៅក្នុងភូមិខ្ញុំ ពីព្រោះពេលវេលានេះមិនមានទូកបើកបរលើផ្ទៃទឹកទន្លេ ហើយ ទឹកទន្លេមេគង្គបានហូរយ៉ាងស្ងៀមស្ងាត់។ នៅក្នុងភាពស្ងៀមស្ងាត់នៃធម្មជាតិនេះ ទឹកទន្លេមេគង្គបាននាំយកនូវសំឡេងដ៏គួរឱ្យរន្ធត់មួយមកគឺសំឡេងផ្ទុះអាវុធពីចម្ងាយ និងសំឡេងប្រយុទ្ធគ្នាក្នុងសង្គ្រាមយ៉ាងក្ដៅគគុកនៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ។ សំឡេងផ្ទុះអាវុធខ្លាំងក្លានៅក្នុងសមរភូមិនេះមិនត្រឹមតែធ្វើឱ្យខ្ញុំនឹករឭកទៅដល់វីរកងទ័ពជួរមុខកម្ពុជាដែលកំពុងតែប្រយុទ្ធតស៊ូប្រឆាំងសង្គ្រាមឈ្លានពាន ប៉ុន្តែថែមទាំងផ្ដល់សារដាស់តឿនដល់ប្រជាជនក្នុងភូមិខ្ញុំ និងសហគមន៍ផ្សេងទៀតនៅក្បែរទន្លេឱ្យដឹងពីគ្រោះថ្នាក់ដែលសង្គ្រាមអាចមកដល់ភូមិយើង។ ទន្លេមេគង្គគឺជាទីកន្លែងដែលបង្ហាញទេសភាពដ៏ស្រស់ស្អាតនាពេលសុរិយាអស្តង្គតលើផ្ទៃទឹក និងជាអ្នកនាំសារដ៏ស្ងៀមស្ងាត់អំពីសង្គ្រាមដែលអាចឱ្យខ្ញុំនិងអ្នកភូមិផ្សេងទៀតអាចដឹងជាមុនអំពីគ្រោះថ្នាក់ដែលខិតជិតមកដល់។ ទន្លេមេគង្គក៏អាចជាការក្រើនរំឭកស្មារតីប្រុងប្រយ័ត្នដល់អ្នកភូមិដែលរស់នៅតាមមាត់ទឹកទន្លេឱ្យត្រៀមខ្លួនរួចរាល់ជាមុនថា៖ សង្គ្រាមមិនស្ថិតនៅទីកន្លែងមួយកន្លែងនោះទេ គឺវានឹងហូរដូចទឹកទន្លេរីករាលដាលពីទីកន្លែងមួយទៅ ទីកន្លែងមួយទៀត។



សិស្សនៅក្នុងស្រុកបុរីអូរស្វាយសែនជ័យ ជិះទូកមកសាលារៀន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## វីរកងទ័ពជួរមុខកម្ពុជា រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ

នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥ ខ្ញុំទទួលបានដំណឹងពីពូ ពេជ្រ រ៉ៃ ដែលជាអ្នកបើកបរទូកចម្លងរបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជា សាខាខេត្តស្ទឹងត្រែងថា កូនប្រុសរបស់គាត់ ឈ្មោះ លី ជាលិញ អាយុ២១ឆ្នាំ និងវីរកងទ័ពជួរមុខកម្ពុជាដែលរស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយ សែនជ័យត្រូវបានបញ្ជូនទៅកាន់សមរភូមិមុខ ទិសត្រពាំងប្រាសាទ និងត្រៀមខ្លួនបន្តទៅកាន់គោលដៅប្រយុទ្ធការពារបូរណភាពទឹកដីក្នុងសមរភូមិដូចជា សមរភូមិភូមិជោគជ័យ សមរភូមិអូរបីជាន់ សមរភូមិបឹងត្រកួន និងសមរភូមិភូមិព្រៃចាន់។ ខណៈពេលដែលសមរភូមិមុខនៅតែបន្តក្ដៅ វីរកងទ័ពជួរមុខកម្ពុជា ជាលិញ និងមិត្តរួមអាវុធបានបង្ហាញ ឆន្ទៈមោះមុត និងត្រៀមខ្លួនរួចជាស្រេចដើម្បីប្រយុទ្ធការពារទឹកដីកម្ពុជា។ ខ្ញុំសូមផ្ញើកម្លាំងចិត្តពីសមរភូមិក្រោយទៅកាន់វីរកងទ័ពជួរមុខកម្ពុជា។

## ការពលីជីវិតរបស់វីរនគរបាលជួរមុខកម្ពុជា

នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ ខ្ញុំនិងអ្នកភូមិអូរស្វាយ ទទួលបានដំណឹងដ៏រន្ធត់ថាពូ ឈន ឡុងឌី

វីរនគរបាលជួរមុខកម្ពុជា នៅវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៧០១ បានពលីជីវិតនៅសមរភូមិមុខទិសមុំបី ខេត្តព្រះវិហារ។ អ្នកភូមិអូរស្មាយ និងខ្ញុំពិតជាសោយស្តាយខ្លាំងណាស់ក្នុងការទទួលបានដំណឹងដ៏ក្រៀមក្រំនេះ ប៉ុន្តែក៏មានមោទនភាពចំពោះវីរភាពនិងការលះបង់របស់គាត់ក្នុងនាមជាវីរនគរបាលជួរមុខកម្ពុជា។ ខ្ញុំសូមគោរពដឹងគុណនិងចងចាំអំពីវីរភាព និងការលះបង់ឈាមស្រស់សាច់ស្រស់របស់គាត់ក្នុងការការពារបូរណភាពនិងអធិបតេយ្យភាពកម្ពុជាយើង។



សិស្សនៅក្នុងស្រុកបុរីអូរស្មាយសែនជ័យ ជិះទូកមកសាលារៀន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## យោធាថៃបញ្ជូនយន្តហោះគ្មានមនុស្សបើកចូលមកស៊ើបការណ៍ និងចារកម្ម នៅខេត្តស្ទឹងត្រែង

នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ យោធាថៃបានបញ្ជូនយន្តហោះគ្មានមនុស្សបើក (ដ្រូន) ចូលមកកាន់ឃុំព្រះរំកិល ស្រុកបុរីអូរស្មាយសែនជ័យ ដែលជាដែនអធិបតេយ្យភាពកម្ពុជា។ បន្ទាប់ពីទទួលបានដំណឹងបែបនេះ ខ្ញុំនិងអ្នកភូមិដទៃទៀតបង្ហាញការព្រួយបារម្ភថាយោធាថៃអាចនឹងប្រើប្រាស់យន្តហោះចម្បាំង F-16 ទម្លាក់គ្រាប់បែក និងគ្រាប់បែកចង្កោម នៅភូមិសាស្ត្រនានាក្នុងស្រុក។ បន្ទាប់មកទៀត សមត្ថកិច្ចក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែងបានរកឃើញ និងកំណត់អត្តសញ្ញាណភ្នាក់ងារចារកម្មរបស់យោធាថៃម្នាក់ដែលមានវត្ថុតាង ឯកសារក្រដាសព្រីនអំពីទីតាំងនានា ជាភាសាថៃច្រើនសន្លឹក។ ជនសង្ស័យនេះ បានធ្វើសកម្មភាពថតរូបនៅតាមទីតាំងយុទ្ធសាស្ត្រ និងទីតាំងសំខាន់ៗក្នុងក្រុងស្ទឹងត្រែង។ ដំណឹងដែលថាយោធាថៃបញ្ជូនយន្ត-ហោះគ្មានមនុស្សបើកសម្រាប់ស៊ើបការណ៍ និងចារកម្មមកកាន់ខេត្តស្ទឹងត្រែង បានបង្កើនការព្រួយបារម្ភបន្ថែមទៀតដល់អ្នកភូមិ។

## ការរៀបចំសម្លៀកបំពាក់ សម្ភារ និងស្បៀងអាហារចាំបាច់សម្រាប់ត្រៀមជម្លៀសក្នុងគ្រាអាសន្ន

ចន្លោះពីថ្ងៃទី១៣ដល់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៥ ប្រទេសថៃ នៅតែបន្តមហិច្ឆតាឈ្លានពានប្រទេសកម្ពុជា ហើយបានប្រើប្រាស់យន្តហោះចម្បាំង F-16 ទម្លាក់គ្រាប់បែក ទ្រង់ទ្រាយធំ និងមិនរើសគោលដៅរហូតដល់ភូមិសាស្ត្រក្នុងខេត្តសៀមរាប។ អ្នកភូមិបានរៀបចំវេចខ្ចប់សម្ភារ និងស្បៀងអាហារចាំបាច់ដើម្បីត្រៀមលក្ខណៈក្នុងគ្រាអាសន្ន។ ចំណែកអ្នកភូមិអូរស្មាយមួយចំនួន ដែលមានសាច់ញាតិឬអ្នកស្គាល់គ្នារស់នៅប្រទេសឡាវ ត្រៀមរត់គេចខ្លួនចូលទៅកាន់ប្រទេសឡាវ ហើយប្រជាជនខ្លះទៀត ត្រៀមរត់គេចខ្លួនទៅតំបន់សុវត្ថិភាពតាមការណែនាំ និងរៀបចំរបស់អាជ្ញាធរ។



ទេសភាពនៅទន្លេមេគង្គ ស្រុកបុរីអូរស្មាយសែនជ័យ នាពេលល្ងាច។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រាសាទចៅស្រីវិបុល

សាំង ចិន្តា



*រូបចម្លាក់នៅប្រាសាទចៅស្រីវិបុល។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ប្រាសាទចៅស្រីវិបុលកសាងឡើងក្នុងអំឡុងសតវត្សរ៍ទី១១ក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី១ បច្ចុប្បន្នស្ថិតនៅក្នុងភូមិត្រាច សង្កាត់បល្ល័ង្ក ក្រុងរុនតាឯក ខេត្តសៀមរាបមានចម្ងាយប្រមាណ២៨គីឡូម៉ែត្រ ភាគខាងកើតពីទីរួមខេត្តសៀមរាប។ ប្រាសាទនេះសង់នៅលើកំពូលភ្នំតូចមួយកម្ពស់ប្រហែល៦០ម៉ែត្រ។ ប្រាសាទនេះ មានប្រាង្គបី និងមានកំពែងពីរជាន់។ កំពែងទី១ គឺសង់ពីថ្មបាយក្រៀម មានទ្វារចេញចូលគ្រប់ទិសទាំងបួន។ កំពែងទី២ គឺសង់ពីថ្មភក់ មានគោបុរៈចំនួនបួនតាមទិសនីមួយៗ។ ប្រាង្គពីរដែលជាបណ្ណាល័យ បែរមុខទៅទិសខាងលិច ឯប្រាង្គសំខាន់មួយនៅកណ្តាល បែរមុខទៅទិសខាងកើត។ នៅជុំវិញតួប្រាសាទមានព្រះចេតិយបុរាណ សរុបចំនួនបី ដែលត្រូវបានសន្និដ្ឋានតៗគ្នាថាជា «ព្រះចេតិយរបស់ព្រះបាទយសកេរ្តិ៍ និង ព្រះមហេសី ព្រមទាំងបុត្រាព្រះនាមព្រះបាទចៅស្រីវិបុល»។ ប្រាសាទនេះ



លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ក្រុមការងារ និងភ្ញៀវទេសចរណ៍មកពីប្រទេសកាណាដា មកទស្សនកិច្ចប្រាសាទចៅស្រីវិបុល ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មានកសិណ (គូ) ទឹកព័ទ្ធជុំវិញៗ ប្រាសាទរងការខូចខាតស្ទើរតែទាំងស្រុងដោយសារតែសង្គ្រាម ការលួចគាស់កកាយរកវត្ថុបុរាណ និងដើមឈើធំៗដុះបុសជ្រែកថ្មដែលបណ្តាលឱ្យប្រាសាទដួលរលំ។

នៅក្នុងរបបខ្មែរក្រហម ខ្មែរក្រហមរុះរើនិងសែងរូបសំណាកព្រះកម្លាយទៅបោះចោលនៅក្នុងព្រៃស្ថិតនៅខាងជើងភ្នំដែលជាទីកន្លែងអ្នកភូមិមិនហ៊ានដើរទៅក្បែរនោះទេ ពីព្រោះតែខ្លាចបារមីព្រះកម្លាយ។ បន្ទាប់មកទីតាំងនោះប្រែក្លាយទៅជាព្រៃរហោឋានហើយជំនឿអំពីបារមីព្រះកម្លាយក៏សាបរលត់បន្តិចម្តងៗ។

## ជំនឿអំពីបារមីរូបសំណាកនៅលើភ្នំប្រាសាទចៅស្រីវិបុល

អ្នកភូមិនិយាយតៗគ្នាពីមួយជំនាន់ទៅមួយជំនាន់អំពីឫទ្ធិបារមីរបស់រូបសំណាកបុរាណនៅលើភ្នំប្រាសាទចៅស្រីវិបុល ប៉ុន្តែដំណាលរឿងនិងតួអង្គអំពីរូបសំណាកដែលមានឫទ្ធិបារមីខ្លាំងគឺមិនដូចគ្នាឡើយ។

## រូបសំណាកថ្ម «នាងសន្ធមា» ក្នុងរឿងព្រេងខ្មែរ៖ ភ្នំស្រីវិបុល

ដំណាលរឿងអំពីរូបសំណាកថ្ម «នាងសន្ធមា» និងការធ្លាក់ខ្លួនឈឺរបស់ព្រះសង្ឃ និងអ្នកភូមិ៖ «នៅចំពីមុខព្រះវិហារមានរូបសំណាកថ្មធំមួយដែលមានទម្រង់ជារូបមនុស្សស្រីដេកអាក្រាតកាយ ដែលអ្នកភូមិធ្វើការសន្មតហៅថា “នាងសន្ធមា” ដែលមានឫទ្ធិខ្លាំងក្លា។ ប្រសិនបើមាននរណាមួយដើរទៅ ដើរមកដោយបានកាត់ពីមុខរូបសំណាកថ្មនេះ និងមិនបានគោរពបូជាទេ អ្នកនោះនឹងចុកពោះ និងធ្លាក់ខ្លួនឈឺថ្កាត់មួយរំពេចៗ ដោយហេតុនេះហើយ នៅពេលដែលព្រះសង្ឃ ព្រះនាម សៅ (អាយុជាង៤០ឆ្នាំ) ក្លាយជាព្រះគ្រូចៅអធិការវត្ត ព្រះអង្គ បានឱ្យពុទ្ធបរិស័ទគាស់រំលើងរូបសំណាកថ្មនេះ យកទៅដាក់ក្នុងព្រៃខាងកើតព្រះវិហារ ដែលមានចម្ងាយប្រមាណ៥០០ម៉ែត្រ។ ចាប់តាំងពីពេលនោះមក អ្នកភូមិលែងចុកពោះ ឬធ្លាក់ខ្លួនឈឺ ប៉ុន្តែមិនហ៊ានដើរចូលព្រៃចំទីកន្លែងដែលរូបសំណាកថ្មនេះត្រូវបានបោះបង់ចោលទេ។ ហេតុដូចនេះហើយ បរិវេណព្រៃម្តុំរូបសំណាកថ្មនោះបានប្រែក្លាយទៅជាព្រៃរហោឋានរហូតមកដល់សព្វថ្ងៃនេះ»។



ភ្ញៀវទេសចរណ៍មកពីប្រទេសកាណាដា មកទស្សនកិច្ចប្រាសាទចៅស្រីវិបុល។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## រូបសំណាក៖ «ព្រះកម្លាយ»

លោក រឹម ហ៊ាប អាយុ៦៨ឆ្នាំ (គិតត្រឹមឆ្នាំ២០១០) រស់នៅភូមិត្រាច ឃុំបល្ល័ង្គ ស្រុកប្រាសាទបាគង ខេត្តសៀមរាប និងជាចាស់ព្រឹទ្ធាចារ្យ បានលើកឡើងថា៖ «ប្រាសាទចៅស្រីវិបុល មានបារមីស័ក្តិសិទ្ធិពីព្រោះនៅលើកំពូលភ្នំប្រាសាទមានរូបសំណាក «ព្រះកម្លាយ»។ អ្នកភូមិមិនហ៊ាននិយាយអ៊ីផ្តេសផ្តាសទេ ព្រោះខ្លាចបារមីរបស់ «ព្រះកម្លាយ» ដែលតែងតែធ្វើឱ្យចុកពោះ និងធ្លាក់ខ្លួនឈឺស្លាប់។ ដំបូងឡើយ មានវត្តអារាមមួយនៅលើកំពូលភ្នំ ហើយព្រះសង្ឃគង់នៅវត្តតែងតែចុកពោះ ឬធ្លាក់ខ្លួនឈឺ ដែលជាហេតុធ្វើឱ្យព្រះសង្ឃ និងអ្នកភូមិសម្រេចមតិផ្លាស់ប្តូរទីតាំងវត្តពីកំពូលភ្នំទៅជើងភ្នំវិញ ដោយរក្សាទុកព្រះវិហារនៅលើកំពូលភ្នំ។

## ប្រវត្តិប្រាសាទចៅស្រីវិបុល

តាមដំណាលរឿងព្រេងខ្មែរ «ភ្នំស្រីវិបុល» និងការចងចាំរបស់ចាស់ព្រឹទ្ធាចារ្យ នៅក្នុងភូមិត្រាចដំណាលថា៖ «ព្រះមហាក្សត្រ ព្រះនាម ព្រះបាទយសកេរ្តិ៍ ឡើងគ្រងរាជ្យនៅនគរសិម្ពលី និងមានអគ្គមហេសី ព្រះនាម សុវណ្ណមាលា។ ព្រះបាទយសកេរ្តិ៍ មានព្រះហឫទ័យប្រកបទៅដោយព្រះធម៌សប្បុរស។ នៅថ្ងៃមួយ ព្រះបាទភូមោវិលោរាជា ព្រះមហាក្សត្រនៃនគរជិតខាង ដែលមានព្រះហឫទ័យលោភលន់ពង្រីកដែនដីនគរ បានលើករេហ៍ពលដើម្បីវាយដណ្តើមយកទ្រព្យសម្បត្តិនៅនគរសិម្ពលី»។

នៅសហគមន៍បល្ល័ង្គបានដំណាលរឿងថា ព្រះបាទភូមោវិលោរាជា មានព្រះហឫទ័យចង់វាយកាន់កាប់ដែនដីនគរសិម្ពលី ដោយសារតែគំនុំអតីតជាតិ។ ព្រះបាទយសកេរ្តិ៍ បានចិញ្ចឹមសត្វទទាទឹកមួយក្បាលនៅក្នុងទ្រុង។ លុះក្រោយមក សត្វទទាទឹកមួយក្បាលនោះបានងាប់ និងចាប់ជាតិជាមនុស្ស គឺព្រះបាទភូមោវិលោរាជា ដែលចងចាំអំពីអតីតជាតិរបស់ខ្លួន។ ក្រោយពីចងចាំអតីតជាតិមុនរបស់ខ្លួនដែលជាសត្វទទាទឹកនោះ ព្រះបាទភូមោវិលោរាជា មានព្រះហឫទ័យគុំកួននិងចង់សងសឹក ហើយបានកេណ្ឌរេហ៍ពលទៅវាយប្រហារព្រះបាទយសកេរ្តិ៍។



ភ្ញៀវទេសចរណ៍មកពីប្រទេសកាណាដា មកទស្សនកិច្ចប្រាសាទចៅស្រីវិបុល។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីព្រះបាទភូមោវិលោរាជា វាយប្រហារនគរសិម្ពលី ព្រះបាទយសកេរ្តិ៍បាននាំព្រះអគ្គមហេសី ព្រះនាម សុវណ្ណមាលា ដែលកំពុងតែមានព្រះគភ៌ រត់ភៀសព្រះកាយចេញពីព្រះរាជវាំងទៅគង់នៅក្នុងព្រៃជ្រៅ ហើយបានទុករាជសម្បត្តិថ្វាយ ព្រះបាទភូមោវិលោរាជា។ ការសម្រេចព្រះហឫទ័យរបស់ព្រះអង្គធ្វើឡើងបែបនេះ ពីព្រោះព្រះបាទយសកេរ្តិ៍ មានព្រះតម្រិះថា ប្រសិនបើព្រះអង្គបន្តគង់ និងធ្វើសង្គ្រាមតទល់នោះ ប្រជារាស្ត្ររបស់ព្រះអង្គនឹងទទួលរងគ្រោះជាអនេកជាមិនខាន។ នៅពេលដែលព្រះអង្គ និងព្រះរាជពនិតា ភៀសព្រះកាយទៅឆ្ងាយ

ផុតទៅ ប្រជារាស្ត្រប្រាកដជាសុខសាន្តត្រាណ។ ព្រះបាទភូមោវិលោរាជាបានឡើងគ្រងរាជសម្បត្តិលើដែននគរសិម្ពលីនេះទៅ។ ព្រះបាទ យសកេរ្តិ៍ និងព្រះអគ្គមហេសី ព្រះអង្គទាំងទ្វេយាងភៀសព្រះកាយទៅក្នុងព្រៃ គឺនៅតំបន់ភ្នំតូចមួយដែលជាភ្នំស្រីវិបុលនេះតែម្តង។

បើទោះបីជាឡើងគ្រងរាជសម្បត្តិនៅនគរសិម្ពលីនេះយ៉ាងណាក្តី ព្រះបាទ ភូមោវិលោរាជា មិនឱ្យព្រះបាទ យសកេរ្តិ៍ និងអគ្គមហេសី រស់នៅសុខសាន្តត្រាណឡើយ។ ព្រះបាទ ភូមោវិលោរាជា បានបញ្ជាវេហ៍ពលរបស់ព្រះអង្គស្វែងរកតាមចាប់ព្រះកាយ ព្រះបាទយសកេរ្តិ៍ នៅពេលដែលព្រះអង្គកំពុងតែយាងបេះផ្លែឈើនិងជីកឫសឈើ យកធ្វើជាព្រះស្ងោយសម្រាប់ព្រះអគ្គមហេសីរបស់ព្រះអង្គដែលកំពុងតែពរផ្ទៃជិតគ្រប់ខែ។ ព្រះបាទ យសកេរ្តិ៍ត្រូវបានចាប់ព្រះកាយយកទៅបង្ខាំងទុក។ មិនយូរប៉ុន្មានព្រះអគ្គមហេសីរបស់ព្រះបាទយសកេរ្តិ៍ប្រសូត្រព្រះរាជបុត្រនៅកណ្តាលព្រៃនិងថ្វាយព្រះនាមព្រះរាជបុត្រថា «ស្រីវិបុល»។

នៅពេលដែលព្រះរាជបុត្រមានព្រះជន្មាយុ ១៥-១៦ ព្រះវស្សា ព្រះរាជបុត្រតែងតែសាកសួរព្រះរាជមាតា អំពីព្រះរាជបិតា។ ព្រះរាជមាតាក៏និទានរឿងរបស់ព្រះអង្គ និងព្រះស្វាមីឱ្យព្រះរាជបុត្រជ្រាបសព្វគ្រប់។ បន្ទាប់មកពីដឹងថាព្រះរាជបិតាព្រះអង្គនៅគង់មានព្រះជន្មនៅឡើយ និងត្រូវបានឃុំព្រះកាយ ព្រះរាជកុមារសុំលាព្រះរាជមាតាដើម្បីទៅស្វែងរកព្រះរាជបិតា។ ព្រះរាជមាតាបានឃាត់ព្រះរាជបុត្រព្រោះតែព្រះហឫទ័យបារម្ភអំពីសុវត្ថិភាពរបស់បុត្រ។ ទោះបីជាមានការហាមឃាត់យ៉ាងណាក្តី ព្រះរាជបុត្រនៅតែទទូចចង់ទៅស្វែងរកព្រះរាជបិតា រហូតដល់ព្រះរាជមាតាព្រះរាជានុញ្ញាត។ ព្រះរាជមាតាបានប្រគល់ព្រះពស្ត្រសម្រាប់រាជ្យជាប់ជាមួយព្រះរាជបុត្រ ដើម្បីបង្ហាញព្រះរាជបិតាថា ព្រះរាជបុត្រគឺពិតជាបុត្ររបស់ព្រះអង្គ។ ព្រះរាជមាតាមានព្រះបន្ទូលថា៖ «ចូរបុត្រទៅកុំយូរឱ្យហួស៧ថ្ងៃ! ប្រសិនបើកំណត់៧ថ្ងៃបុត្រមិនវិលត្រឡប់មកវិញទេ ព្រះមាតានឹងបែកព្រះឱរាព្រះសុគតជាមិនខាន»។ ព្រះរាជបុត្រថ្វាយព្រះបង្គំលាព្រះរាជមាតា និងយាងព្រះរាជដំណើរឆ្ពោះទៅកាន់ទីដែលឃុំឃាំងព្រះរាជបិតា។ គាប់ជួននៅពេលនោះ ព្រះបាទភូមោវិលោរាជា ចាត់បញ្ជាឱ្យពេជ្ឈឃាតនាំយកព្រះកាយ ព្រះបាទ យសកេរ្តិ៍ ទៅប្រហារជីវិតនៅកណ្តាលព្រះលាន។ ព្រះរាជបុត្រស្ទុះចូលទៅជិតពេជ្ឈឃាតហើយមានព្រះបន្ទូលឃាត់ថា៖ «សូមអ្នកដោះលែងព្រះរាជបិតារបស់យើងនេះចុះ ហើយសម្លាប់យើងជំនួសវិញ។ ខ្លួនយើងគឺជាបុត្ររបស់ព្រះបាទយសកេរ្តិ៍ ហើយសូមធានាទទួលទោសទាំងអស់នេះ។» ពេជ្ឈឃាតទាំងអស់ស្រឡាំងកាំងកាំងស្មារតីគ្រប់ៗគ្នា ហើយផ្អាកប្រហារជីវិតអ្នកទោសនេះសិន។ បន្ទាប់មក មានការទូលរាយការណ៍ព្រះរាជា ព្រះបាទ ភូមោវិលោរាជា សុំសេចក្តីរាជានុញ្ញាតអំពីព្រះតម្រិះរបស់ព្រះអង្គ។ ព្រះបាទភូមោវិលោរាជាបានរាជានុញ្ញាតឱ្យពេជ្ឈឃាតប្រហារជីវិតព្រះរាជបុត្រាជំនួសចុះ។ បន្ទាប់មក ព្រះបាទយសកេរ្តិ៍ ត្រូវបានដោះលែងព្រះកាយ ហើយព្រះរាជបុត្រស្រីវិបុល ត្រូវបាននាំយកមកទីកន្លែងប្រហារជីវិតជំនួសវិញ។

ព្រះបាទ ភូមោវិលោរាជា បញ្ជាឱ្យដំរីជាន់ប្រហារជីវិតព្រះរាជបុត្រ ប៉ុន្តែដំរីមិនបានដើរជាន់សម្លាប់នោះទេ ប៉ុន្តែបែរទៅជាលត់ជង្គង់នៅមុខព្រះរាជបុត្រស្រីវិបុលទៅវិញ។ ព្រះបាទភូមោវិលោរាជា ក៏បញ្ជាឱ្យពេជ្ឈឃាតប្រហារជីវិតព្រះរាជបុត្រស្រីវិបុល ប៉ុន្តែនៅពេលដែលដកដាវចេញ ដាវរបស់ពេជ្ឈឃាតប្រែជាទន់ដូចសំឡីមិនមានគ្រោះថ្នាក់អ្វីដល់ជីវិតរបស់ព្រះរាជបុត្រឡើយ។

បន្ទាប់ពីជ្រាបអំពីហេតុចម្លែកបែបនេះ ព្រះបាទភូមោវិលោរាជា ព្រះអង្គ ស្តេចយាងចេញទៅទតហេតុដ៏អស្ចារ្យនេះដោយផ្ទាល់ព្រះនេត្រ ប៉ុន្តែជាអកុសលចេញពីអំពើអាក្រក់ដែលព្រះអង្គបានប្រព្រឹត្តកន្លងមក នៅពេលនោះព្រះធរណីបានស្រូបយក

ព្រះបាទ ភូមោវិលោរាជា ដែលជាព្រះរាជាអធម៌នេះ បាត់ព្រះកាយទៅ។ ប្រជារាស្ត្រ និងនាម៉ឺន មន្ត្រីគ្រប់ជាន់ថ្នាក់ បានកោតស្ញប់ស្ញែងអនុភាពឫទ្ធិបារមីរបស់ព្រះរាជបុត្រស្រីវិបុល។ ប្រជារាស្ត្រ និងនាម៉ឺនមន្ត្រីគ្រប់ជាន់ថ្នាក់បានមូលមតិគ្នាថ្វាយរាជ្យសម្បត្តិទៅព្រះរាជបុត្រ ស្រីវិបុលហើយព្រះអង្គសព្វព្រះរាជហឫទ័យយល់ព្រមទទួលសំណើឡើងជាព្រះរាជា។



ភ្ញៀវទេសចរណ៍មកពីប្រទេសកាណាដា មកទស្សនកិច្ចប្រាសាទចៅស្រីវិបុល។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ព្រះរាជពិធីរាជាភិសេកឡើងគ្រងរាជ្យត្រូវបានរៀបចំឡើងនៅពេលនោះតែម្តង ហើយព្រះរាជបុត្រទទួលបានព្រះរាជនាម ព្រះបាទ ស្រីវិបុល។ នាពេលរាត្រីស្ងប់ស្ងាត់ ព្រះបាទ ស្រីវិបុល ក្រាបទូលព្រះរាជបិតាអំពីព្រះបណ្តាំរបស់ព្រះរាជមាតា ដែលព្រះអង្គព្រះបន្ទូលផ្តែផ្តាំកំណត់កុំឱ្យហួស៧ថ្ងៃ ប៉ុន្តែយប់នោះគឺជាថ្ងៃកំណត់ជាថ្ងៃទី៧។ ព្រះបាទ យសកេរ្តិ៍ និងព្រះបាទ ស្រីវិបុល ព្រះអង្គទាំងទ្វេសម្រេចព្រះហឫទ័យព្រមព្រៀងរត់ភៀសព្រះកាយចេញពីព្រះបរមរាជវាំង មិនឱ្យនាម៉ឺន ដឹងអំពីព្រះរាជដំណើរនេះ។ ព្រះអង្គទាំងទ្វេធ្វើព្រះដំណើរតាមព្រះបាទាយ៉ាងលឿន ឆ្លងកាត់ព្រៃ និងឆ្លងកាត់វាលស្តោះសំដៅទៅកាន់ទីដែលព្រះអគ្គមហេសី សុវណ្ណមាលា ព្រះអង្គគង់នៅ។ ដោយសារតែផ្លូវលំបាកនិងមានចម្ងាយឆ្ងាយ ព្រះរាជដំណើរនេះត្រូវប្រព្រឹត្តឡើងអស់រយៈ១យប់១ថ្ងៃ ទើបអាចទៅដល់។ នៅពេលដែលព្រះអង្គទាំងទ្វេទៅដល់ព្រះអគ្គមហេសី សុវណ្ណមាលា បានសុគតផុតហួសទៅហើយ។ ព្រះបាទយសកេរ្តិ៍ និងព្រះបាទ ស្រីវិបុល ព្រះអង្គទាំងទ្វេរន្ធត់ព្រះទ័យយ៉ាងខ្លាំង។ នៅពេលដែលព្រះរាជពិធីបូជាព្រះសពរបស់ព្រះអគ្គមហេសី សុវណ្ណមាលា រៀបចាប់ផ្តើម ព្រះបាទ ស្រីវិបុល ព្រះអង្គព្រះតម្រិះថា៖«ការសុគតរបស់ព្រះរាជមាតាសុគតគឺដោយសារតែព្រះអង្គ។ ហេតុនេះហើយ ព្រះអង្គគួរតែស្វែងរកវិធីណាដើម្បីសំដែងការតបស្នងឱ្យស័ក្តិសមនឹងព្រះហឫទ័យស្រឡាញ់យ៉ាងជ្រាលជ្រៅបំផុតរបស់ព្រះរាជមាតាចំពោះព្រះអង្គ»។

បន្ទាប់ពីបានព្រះតម្រិះហើយ ព្រះបាទ ស្រីវិបុល តម្កល់ព្រះសពរបស់ព្រះរាជមាតាក្នុងមឈូស ហើយបានលើកមឈូសដាក់លើព្រះឱរា ដោយព្រះអង្គផ្ទីទ្រមឈូសរបស់ព្រះរាជមាតា។ លុះបូជាព្រះសពរបស់ព្រះរាជមាតារួចរាល់ទៅ ព្រះបាទ ស្រីវិបុល ព្រះអង្គក៏កន្សៀយព្រះជន្មទៅជាមួយព្រះរាជមាតា។ ព្រះបាទ យសកេរ្តិ៍ ពិបាកហឫទ័យជាពន់ពេក ប៉ុន្តែព្រះអង្គខំទប់ព្រះចិន្តា ហើយត្រឡប់មកទទួលគ្រប់គ្រងរាជ្យសម្បត្តិវិញ។ ក្រោយពេលដែលឡើងគ្រងរាជសម្បត្តិវិញ ព្រះបាទយសកេរ្តិ៍ កសាងប្រាង្គសិលានៅចំទីដែលព្រះបាទស្រីវិបុល ព្រះអង្គផ្ទីទ្រមឈូសព្រះរាជមាតា ដើម្បីតម្កល់ព្រះបរមអដ្ឋិធាតុនៃព្រះអគ្គមហេសីនិងព្រះរាជបុត្រដោយព្រះប្រសិទ្ធនាមថា «ប្រាសាទចៅស្រីវិបុល»។



មគ្គុទ្ទេសក៍ទេសចរណ៍នៅប្រាសាទចៅស្រីវិបុល។
(បណ្ណសារមជ្ឈមណ្ឌលឯកកម្ពុជា)

# ខ្មែរក្រហមសម្លាប់ឪពុករបស់ខ្ញុំដោយសារតែជាប់ប្រវត្តិជានិគមជនសង្គមរាស្ត្រនិយម

**ស្រេង លីដា**

ខ្ញុំឈ្មោះ នៅ បូ អាយុ៧៨ឆ្នាំ កើតនៅខេត្តព្រះវិហារ បច្ចុប្បន្នរស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ខ្ញុំមានឪពុកឈ្មោះ នាង នៅ និងម្ដាយឈ្មោះ ឡៀវ អេង។ ខ្ញុំគឺជាកូនច្បងក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៣នាក់។ ខ្ញុំបានរៀបការនៅឆ្នាំ១៩៦៨។ ប្ដីខ្ញុំឈ្មោះ ឈឿន ឆន ក្រោយរៀបការយើងមានកូនចំនួន៤នាក់ក្នុងនោះមានប្រុសម្នាក់។



នៅ បូ អាយុ៧៨ឆ្នាំ បច្ចុប្បន្នរស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ហេតុផលដែលគ្រួសាររបស់ខ្ញុំផ្លាស់មករស់នៅបុរីអូរស្វាយ គឺដោយសារតែឪពុករបស់ខ្ញុំជាទាហានចូលនិវត្តន៍ និងធ្លាប់ឈរជើងនៅតាមព្រំដែន។ បន្ទាប់មក សម្ដេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ បានធ្វើការប្រកាសជ្រើសរើសទាហានទាំងអស់ដែលបានចូលនិវត្តន៍ឱ្យមករស់នៅបុរីអូរស្វាយ។ ទាហានចូលនិវត្តន៍ និងគ្រួសារត្រូវបានបញ្ជូនមករស់នៅបុរីអូរស្វាយ និងទទួលបានរបបចែកឱ្យដូចជា ផ្ទះកាឡុង (ផ្ទះនិគមជន), ដីធ្លីសម្រាប់ធ្វើស្រែចម្ការ, គ្រាប់ពូជ និងថវិកាប្រចាំខែជាដើម។ ក្រោយមកទៀត មានគ្រួសារប្រជាជនក្រីក្រដែលរស់នៅតាមបណ្ដាខេត្តនានា ត្រូវបានបញ្ជូនមកកសាងជីវិតរស់នៅបុរីអូរស្វាយ ។ សម្ដេចព្រះ នរោត្តម សីហនុ បានកែននាយទាហានចូលនិវត្តន៍ និងគ្រួសារប្រជាជនដែលមានជីវភាពក្រីក្រមករស់នៅបុរីអូរស្វាយ គឺដើម្បីបុព្វហេតុការពារទឹកដីពីការឈ្លានពានប្រទេសជិតខាង។

និគមជនទាំងអស់បាន ទទួលបានការគាំទ្រ ឧបត្ថម្ភក្នុងការចាប់ផ្ដើមជីវភាពនៅលើទឹកដីបុរីអូរស្វាយ និងបានធ្វើការប្រមូលទិន្នផលស្រូវ និងដំណាំកសិកម្មផ្សេងៗដើម្បីដាក់លក់នៅទីផ្សារសហគមន៍។ ក្រៅពីការដាំដំណាំកសិកម្ម, បុរីអូរស្វាយក៏មានរោងចក្រផលិតស្ករអំពៅ និងរោងចក្រតម្បាញ។ យុវជនត្រូវបានជ្រើសរើសឱ្យធ្វើការងារនៅរោងចក្រផលិតស្ករអំពៅ ចំណែកឯយុវនារី អាចធ្វើការងារជាអ្នកតម្បាញ។ នៅពេលនោះ ខ្ញុំជាអ្នកតម្បាញក្នុងរោងតម្បាញក្រណាត់។ ប្រជាជនទាំងអស់មានការងារធ្វើរៀងៗខ្លួន និងទទួលបាន

ប្រាក់ប្រចាំខែចំនួន៧៥០រៀលក្នុងមួយខែ។ នៅបុរីអូរស្វាយ លោក ម៉ៅ សង្វៀម គឺជាអ្នកដែលរៀបចំនិងកសាងសមិទ្ធផលនានា ក្រោមការដឹកនាំ និងចង្អុលបង្ហាញរបស់សម្តេចព្រះ នរោត្តម សីហនុ។ នៅពេលនោះ ក៏មានច្បាប់មួយ គឺប្រជាជនទាំងអស់នៅបុរីអូរស្វាយ កុំប្រើប្រាស់ និងនិយាយភាសាឡាវ ដោយមូលហេតុថា មានការលើកឡើងថា ទីកន្លែងណាដែលមានប្រជាជននិយាយភាសាឡាវ ទីកន្លែងនោះគឺជាទឹកដី ឡាវ។ ដូច្នេះហើយ ការនិយាយភាសាឡាវ និងការស្លៀកសម្លៀកបំពាក់ ឡាវត្រូវបានហាមឃាត់ជាកំហិត។

ស្ថានភាពរស់នៅបុរីអូរស្វាយ ក្នុងគ្រាដំបូងគឺមានភាពលំបាក ពីព្រោះមិនមានសម្ភារ និងរបស់របរប្រើប្រាស់ជាប្រចាំថ្ងៃគ្រប់គ្រាន់។ យ៉ាងណាក៏ដោយ ប្រជាជនបន្តរស់នៅ និងបន្តធ្វើជាខែលការពារទឹកដីពីការឈ្លានពានរបស់ប្រទេសជិតខាង។ ប្រជាជនក៏ជួបបញ្ហាជំងឺគ្រុនចាញ់ផងដែរ ដែលបណ្តាលឱ្យមានប្រជាជនជាច្រើនបានស្លាប់បាត់បង់ជីវិត។ សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ប្រោសព្រះរាជទាននូវជំនួយបន្ទាន់ជាបន្តបន្ទាប់ ដែលរួមមានថ្នាំពេទ្យ ស្បៀងអាហារ និងសម្ភារប្រើប្រាស់ចាំបាច់ផ្សេងៗ។ នៅឆ្នាំ១៩៦៨ សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ យាងមកសម្ពោធសមិទ្ធផលដែលត្រូវបានកសាងរួមមានមន្ទីរពេទ្យ, ផ្ទះកាឡុង, ស្តូបអនុស្សាវរីយ៍, មន្ទីរចាត់ការ និងផ្សារសហគមន៍ជាដើម។ នៅពេលនោះ ខ្ញុំក៏ទៅទទួលព្រះរាជដំណើររបស់សម្តេចព្រះ នរោត្តម សីហនុ និងទទួលបានព្រះរាជអំណោយជាក្រណាត់សមួយដុំ ដែលមានប៉ាក់អក្សរថា «សង្គមរាស្ត្រនិយម»។

នៅខែមីនា ឆ្នាំ១៩៧០បន្ទាប់ពីលោក លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ និងបង្កើតរបបសាធារណរដ្ឋខ្មែរ តំបន់បុរីអូរស្វាយ បានក្លាយទៅជាសមរភូមិប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម។ បុរីអូរស្វាយ ទទួលរងការទម្លាក់គ្រាប់បែកយ៉ាងខ្លាំងក្លា។ អ្នកភូមិនៅបុរីអូរស្វាយ រស់នៅក្នុងស្ថានភាពពិបាក និងមានការភ័យខ្លាច ពីព្រោះរាល់ពេលដែលមានការទម្លាក់គ្រាប់បែកមកម្តងៗ អ្នកភូមិទាំងអស់ត្រូវរត់ចូលរណ្តៅលេណដ្ឋានដើម្បីគេចពីអំបែងគ្រាប់បែក។ នៅពេលនោះ កងទ័ពវៀតណាម ក៏មានវត្តមាននៅបុរីអូរស្វាយ។ កងទ័ពវៀតណាមដែលបានឈរជើងនៅក្នុងព្រៃ បានចូលមកសម្ងំលាក់ខ្លួននៅក្នុងផ្ទះអ្នកភូមិ ដើម្បីគេចពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក។ នៅពេលដែលទាហានអាមេរិកឃើញកងទ័ពវៀតណាមនៅកន្លែងណាមួយ ទាហានអាមេរិកនឹងធ្វើការទម្លាក់គ្រាប់បែកនៅទីកន្លែងនោះ។ យ៉ាងណាក៏ដោយ ការទម្លាក់គ្រាប់បែករបស់ទាហានអាមេរិកបានបណ្តាលឱ្យមានការខូចខាតដល់ទីតាំងផ្សេងៗនៅបុរីអូរស្វាយ។

នៅឆ្នាំ១៩៧៥ ការទម្លាក់គ្រាប់បែក លែងកើតមានឡើងតទៅទៀត បន្ទាប់ពីកងទ័ពខ្មែរក្រហមបានគ្រប់គ្រងប្រទេសទាំងស្រុងក្នុងតំបន់បុរីអូរស្វាយ និងភូមិសាស្ត្រនានានៅខេត្តស្ទឹងត្រែង។ ប្រជាជនត្រូវបានជម្លៀសចេញពីភូមិទៅធ្វើការនៅកន្លែងឆ្ងាយ។ ខ្ញុំទើបតែសម្រាលកូនបានប្រហែល៣ខែ។ បើទោះបីជាខ្ញុំទើបតែសម្រាលកូនក្តី, ខ្មែរក្រហមនៅតែបញ្ជូនឱ្យខ្ញុំធ្វើការងារដូចជា បុកស្រូវ និងវែងអង្ករ ដែលជាហេតុធ្វើឱ្យកូនរបស់ខ្ញុំមិនបានបៅគ្រប់គ្រាន់។ ខ្ញុំត្រូវខិតខំធ្វើការឱ្យគ្រប់ផែនការរបស់ខ្មែរក្រហម។ នៅពេលដែលកូនរបស់ខ្ញុំធំបន្តិច ខ្មែរក្រហមបានចាត់តាំងឱ្យខ្ញុំទៅធ្វើការងារនៅកងចល័តវ័យកណ្តាលដូចមិត្តនារីៗផ្សេងទៀតដែរ។ ខ្ញុំអាណិតស្រណោះកូនរបស់ខ្ញុំជាទីបំផុត ពីព្រោះខ្ញុំជាម្តាយត្រូវឃ្លាតឆ្ងាយពីកូន និងត្រូវយកកូនខ្ញុំទៅដាក់ក្នុងកងកុមារ។ ខ្ញុំបានផ្តាំផ្ញើដល់អ្នកមើលថែកូនខ្ញុំឱ្យជួយបំបៅផង។ ដើម្បីយកចិត្តអ្នកមើលថែកូនខ្ញុំ គឺខ្ញុំមានតែជីកដំឡូងព្រៃស្ងោរយកមកឱ្យអ្នកមើលហូប។

ក្រោយមកទៀត ខ្មែរក្រហមបានចល័តខ្ញុំទៅធ្វើការងារនៅភូមិញៀន គឺជាទីកន្លែងដែលខ្ញុំត្រូវធ្វើការងារខ្លាំង មានដូចជា លើកភ្លឺស្រែ, ដកស្ទូងស្រូវ និងលើកទំនប់អូរពូក ដែលមានកម្ពស់ប្រហែល១៥ម៉ែត្រ។ ការងារនៅពេលនោះ គឺគ្មានពេលសម្រាកគ្រប់គ្រាន់ និងមិនមានអាហារហូបចុកគ្រប់គ្រាន់ឡើយ។ ខ្ញុំហូបតែបាយលាយចេកមួយចានចង្កឹះតូចមួយដើម្បីចម្អែតក្រពះ និងបន្តរស់តទៅទៀតដើម្បីជួបមុខកូនៗ ដោយសារតែអត់ឃ្លានពេក នៅពេលយប់ខ្ញុំតែងតែលួចដីកដំឡូង និងមើមក្ដួចយកមកស្ងោរហូបៗ ពេលខ្លះ ខ្ញុំក៏មានអង្ករដាំបាយហូប ពីព្រោះប្ដីរបស់ខ្ញុំគឺជាអ្នកដឹកជញ្ជូនអង្ករនិងស្បៀង ដូច្នេះហើយគាត់បានលួចយកអង្ករខ្លះយកមកឱ្យប្រពន្ធ។

នៅថ្ងៃមួយ ខ្ញុំទទួលបានដំណឹងថា ឪពុករបស់ខ្ញុំត្រូវបានខ្មែរក្រហមចាប់យកទៅរៀនសូត្រ។ ម្ដាយនិងបងប្អូនផ្សេងទៀតក៏ដឹងដំណឹង ហើយបាននាំគ្នាយំអាណិតស្រណោះគាត់ៗ ជាសំណាងល្អ ខ្មែរក្រហមបានដោះលែងឪពុករបស់ខ្ញុំឱ្យវិលមកផ្ទះវិញ ដោយសារតែការចាប់ច្រឡំ។ ខ្ញុំមិនដែលឃើញខ្មែរក្រហមសម្លាប់មនុស្សនោះទេ ប៉ុន្តែខ្ញុំដឹងថា អ្នកភូមិជាច្រើនបានបាត់ខ្លួនជាបន្តបន្ទាប់ៗ ខ្ញុំធ្លាប់ឃើញខ្មែរក្រហមយកទូកមកដឹកប្រជាជនៗ ខ្ញុំមិនដឹងថា ទូកទាំងនោះដឹកប្រជាជនយកទៅកន្លែងណា ឬប្រហែលជាត្រូវខ្មែរក្រហមវាយសម្លាប់បណ្ដែតតាមទឹកទន្លេក៏មិនដឹង។

ខ្ញុំក៏ធ្លាប់ចូលរួមពិធីប្ដេជ្ញា (រៀបការ) ដែលមានទាំងអស់ប្រហែលជា២០គូ ដោយតម្រូវឱ្យខាងប្រុសអង្គុយជាជួរម្ខាង និងខាងស្រីអង្គុយជាជួរម្ខាងទៀត និងគូរៀបការទាំងអស់ត្រូវធ្វើការប្ដេជ្ញាថា «យកគ្នាជាប្ដីប្រពន្ធអស់មួយជីវិតដើម្បីការពារបក្ស ប្ដេជ្ញាៗ!»។

នៅឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានវាយផ្ដួលរំលំរបបខ្មែរក្រហម និងរំដោះប្រទេសកម្ពុជា និងសង្គ្រោះប្រជាជនៗ ខ្មែរក្រហមបានជម្លៀសខ្ញុំ និងប្រជាជនផ្សេងទៀតទៅជាមួយៗ ប៉ុន្តែខ្ញុំនិងគ្រួសារ បានលួចរត់ចេញពីភូមិញៀនដោយធ្វើដំណើររហូតដល់បុរីអូរស្វាយវិញ។ ដោយសារតែមានការភិតភ័យពីសុវត្ថិភាព ខ្ញុំ និងប្ដីនាំកូនឆ្លងទន្លេមេគង្គទៅដល់ភូមិព្រះរំកិល និងបន្តទៅស្រុកឆែប ខេត្តព្រះវិហារ រួចបន្តឡើងភ្នំដងផ្ចិតៗ បន្ទាប់ពីស្នាក់នៅលើភ្នំដងផ្ចិតបានប្រហែល៤ថ្ងៃ ក៏ឃើញរថយន្តកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិ និងកងទ័ពស្ម័គ្រចិត្តវៀតណាមជាច្រើនមកដល់ជើងភ្នំ និងបានស្រែកប្រកាសខ្លាំងៗថា៖ «បងប្អូន យើងរួចផុតអស់ហើយ! សូមបងប្អូនវិលត្រឡប់ទៅភូមិស្រុកកំណើតរបស់បងប្អូនវិញចុះ!»។ ខ្ញុំ និងគ្រួសារបាននាំគ្នាចុះពីភ្នំ និងទៅរស់នៅគុជចំបក់ ដោយបានប្រកបរបរធ្វើស្រែចម្ការអស់រយៈពេលមួយឆ្នាំ ទើបសម្រេចចិត្តវិលត្រឡប់មករស់នៅបុរីអូរស្វាយវិញ និងបន្តរស់នៅរហូតដល់ពេលបច្ចុប្បន្ននេះ។ ខ្ញុំបានដឹងហើយថា មេដឹកនាំខ្មែរក្រហមត្រូវបាននាំមកកាត់ទោសចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅចន្លោះឆ្នាំ១៩៧៥-១៩៧៩។ ចំពោះបញ្ហាសុខភាពវិញ ខ្ញុំមានជំងឺប្រចាំកាយ ដូចជាក្រពះពោះវៀន ងងឹតភ្នែក និងឈឺសន្លាក់ៗ



លំនៅឋានរបស់ប្រជាជននៅតាមដងទន្លេមេគង្គ ក្នុងភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឡុង វ៉ាន់ ៖ អតីតគ្រូពេទ្យនៅមន្ទីរពេទ្យកុមារពេទ

មឿន ស្រីណុច



គ្រូពេទ្យក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ កម្មាភិបាលខ្មែរក្រហមបានរៀបចំទុកជាមុន មុននឹងអនុញ្ញាតឱ្យគណៈប្រតិភូមកពីប្រទេសស៊ុយអែត ចូលថតរូបនៅមន្ទីរពេទ្យនេះនៅក្នុងឆ្នាំ១៩៧៨។ (ហ្គុនណា បឺយស្រ្តម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឡុង វ៉ាន់អាយុ៦១ឆ្នាំ មានស្រុកកំណើតនៅភូមិមឿងចារ ឃុំដាងទង ស្រុកត្រាំកក់ ខេត្តតាកែវ។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ ផុស ស្លាប់ក្នុងឆ្នាំ១៩៧៧ ដោយសារជំងឺបុកពោះ។ ម្តាយឈ្មោះ ម៉ី សូត្រ ស្លាប់ដោយសារជំងឺចាស់ជរា។ ខ្ញុំមានបងប្អូនបង្កើតចំនួន៥នាក់ (ស្រី២នាក់ និងប្រុស៣នាក់) ហើយខ្ញុំគឺជាកូនទី២នៅក្នុងគ្រួសារ។ ខ្ញុំមានប្តីឈ្មោះ យក់ វ៉ា (ស្លាប់) និងមានកូនចំនួន៤នាក់ គឺ(ស្រី២នាក់ និងប្រុស២នាក់)។

កាលនៅវ័យកុមារ ខ្ញុំបានចូលរៀននៅសាលាវត្តមឿងចារត្រឹមថ្នាក់ទី១២ (នៅសង្គមចាស់)។ គ្រូរបស់ខ្ញុំឈ្មោះ វិត គឺជាអ្នករស់នៅក្នុងភូមិជាមួយខ្ញុំ។



ឡុង រ៉ាន់ អាយុ៦១ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រោយមកខ្ញុំបានឃើញយន្តហោះមកទម្លាក់គ្រាប់បែកនៅមុខផ្ទះរបស់ខ្ញុំ បណ្តាលឱ្យប្រជាជនម្នាក់ស្លាប់បាត់បង់ជីវិត និងងាប់គោជាច្រើនក្បាល។ ចំណែកខ្ញុំបានរត់ចូលក្នុងលេណដ្ឋានដើម្បីលាក់ខ្លួន។ ក្រោយមក ម្តាយខ្ញុំមិនឱ្យខ្ញុំទៅរៀនទៀតទេ ព្រោះខ្លាចយន្តហោះទម្លាក់គ្រាប់បែក។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបញ្ជូនខ្ញុំឱ្យចូលក្នុងកងកុមារភូមិមឿងចារ។ ខ្ញុំត្រូវបានបញ្ជូនឱ្យទៅរែកដីរែកអាចម៍គោយកទៅចាក់ក្នុងស្រែ។ ខ្ញុំធ្វើការចាប់ពីម៉ោង៧ព្រឹករហូតដល់ម៉ោង១១ ទើបសម្រាកហូបបាយ និងចាប់ផ្តើមពីម៉ោង២រសៀលរហូតដល់ម៉ោង៥ល្ងាច។ សម្រាប់របបអាហារ ខ្ញុំហូបបាយជាមួយសម្ល។ ឪពុករបស់ខ្ញុំត្រូវបានខ្មែរក្រហមប្រើឱ្យដាំបាយឱ្យកងចល័ត។ ចំណែកម្តាយខ្ញុំនៅមើលថែកូនតូចៗនៅផ្ទះ។

នៅខែមករា ឆ្នាំ១៩៧៦ ខ្ញុំ បងស្រីបង្កើតឈ្មោះ រី និងបងស្រីជីដូនមួយឈ្មោះ រ៉ន ត្រូវបានមេឃុំឈ្មោះ បឿន ជ្រើសរើសចេញពីកងកុមារភូមិឱ្យទៅរៀនពេទ្យនៅត្រពាំងគល់ ដែលជាមន្ទីរពេទ្យប្រចាំក្នុងស្រុកត្រាំកក់។ នៅរយៈពេល៦ខែដំបូង ខ្ញុំបានរៀនចាក់ថ្នាំ និងរៀនពីរបៀបព្យាបាលជំងឺទូទៅ។ នៅក្នុងមន្ទីរពេទ្យសម្បូរប្រជាជនមានជំងឺច្រើនណាស់ ហើយជំងឺទាំងអស់រួមមាន គ្រុនក្តៅ រាក និងគ្រុនផ្តាសាយ។ នៅទល់មុខមន្ទីរពេទ្យត្រពាំងគល់ មានរោងចក្រផលិតថ្នាំគ្រាប់ និងថ្នាំប្រភេទទឹក សម្រាប់យកមកផ្គត់ផ្គង់ក្នុងមន្ទីរពេទ្យ។ ក្រោយមក ខ្ញុំបានជួយចាក់ថ្នាំ និងមើលថែអ្នកជំងឺក្នុងមន្ទីរពេទ្យ។ របបអាហារសម្រាប់គ្រូពេទ្យ និងអ្នកជំងឺគឺហូបបាយ។

នៅដើមឆ្នាំ១៩៧៧ ខ្ញុំ មិត្តនារីឈ្មោះ សម្បត្តិ, ណាត និងនារីចំនួន៤នាក់ទៀត ត្រូវបានប្រធានមន្ទីរពេទ្យឈ្មោះ នាង ជ្រើសរើសឱ្យទៅរៀនជំនាញពេទ្យបន្ថែមនៅទីក្រុងភ្នំពេញ។ ទៅដល់ភ្នំពេញ ខ្ញុំ និងមិត្តឈ្មោះ សម្បត្តិ ត្រូវបានបញ្ជូនឱ្យទៅរៀននៅមន្ទីរពេទ្យកុមារព១ (នៅវត្តភ្នំ)។ នៅមន្ទីរពេទ្យកុមារព១ មានឈ្មោះ មិញ និង នី គឺជាវេជ្ជបណ្ឌិតប្រចាំនៅមន្ទីរពេទ្យ។ នៅមន្ទីរពេទ្យមានសុទ្ធតែកុមារទាំងអស់ ហើយភាគច្រើនមានជំងឺគ្រុនក្តៅ រាក និងជំងឺរបេង។ គ្រប់កុមារទាំងអស់មានសរសេរក្រដាស់ឈ្មោះផ្ទាល់ខ្លួន និងឈ្មោះរបស់ឪពុកម្តាយបិទនៅចុងគ្រែពេទ្យ។ នៅពេលព្រឹក ខ្ញុំចូលព្យាបាលកុមារ។ ម៉ោង១១ព្រឹក ខ្ញុំ និង សម្បត្តិ ត្រូវទៅរៀនភាសាចិនជាមួយគ្រូជនជាតិចិនដើម្បីងាយស្រួលអានអក្សរលើថ្នាំពេទ្យ។ នៅម៉ោង១ទៅម៉ោង២រសៀល ខ្ញុំត្រូវចូលព្យាបាល និងមើលថែកុមារបន្តទៀត។ នៅពេលយប់ ខ្ញុំ ត្រូវចូលយាមប្រចាំការរហូតទល់ព្រឹក ដូច្នេះមិនមានពេលសម្រាកឡើយ។ នៅមន្ទីរពេទ្យព-១ មានគ្រូពេទ្យប្រហែល១០០នាក់ ដែលត្រូវបានចាត់ទៅតាមផ្នែកផ្សេងៗមានផ្នែកព្យាបាលជំងឺទូទៅ ផ្នែកដាំបាយ ផ្នែកបោកខោអាវ និងផ្នែកអនាម័យ។

នៅឆ្នាំ១៩៧៩ ខ្ញុំសម្បត្តិនិងគ្រូពេទ្យទាំងអស់បានឡើងជិះរថយន្តជាមួយកងទ័ពខ្មែរក្រហមភៀសខ្លួនចេញពីភ្នំពេញធ្វើដំណើរកាត់តាមខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់។ កងទ័ពវៀតណាមបានចាំស្ទាក់នៅខេត្តពោធិ៍សាត់ និងបានដេញបាញ់ពីក្រោយ ទើប ខ្ញុំ



គ្រូពេទ្យក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ កម្មាភិបាលខ្មែរក្រហមបានរៀបចំទុកជាមុន មុននឹងអនុញ្ញាតឱ្យគណៈប្រតិភូមកពីប្រទេសស៊ុយអែត ចូលថតរូបនៅមន្ទីរពេទ្យនេះនៅក្នុងឆ្នាំ១៩៧៨។
(ហ្គុនណា បឺយស្ត្រម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

និងសម្បត្តិបានចុះពីលើរថយន្តរត់ភៀសខ្លួនទៅដល់ស្រុកលាច (ស្រុកភ្នំក្រវាញ) រួចរត់ទៅនៅព្រៃខ្លួតរយៈពេល២យប់។ បន្ទាប់ទៀត ខ្ញុំ និងសម្បត្តិបានរត់ភៀសខ្លួនទៅតាមកងទ័ពខ្មែរក្រហមដល់ភ្នំវាយចាប ស្ថិតនៅក្នុងស្រុកសំឡូត ខេត្តបាត់ដំបង។

នៅឆ្នាំ១៩៨០ ខ្ញុំបានចូលធ្វើការក្នុងកងដឹកជញ្ជូនជាមួយ គឹម ពៅ ដែលមានទីតាំងនៅស្រុកសំឡូត ហើយមេកងរបស់ខ្ញុំឈ្មោះ មើ និង ណាន។ ខ្ញុំដឹកជញ្ជូនគ្រាប់ចេញពីបង្គោល ឡាក់លេខ៧០នៅព្រំដែនកម្ពុជា-ថៃយកទៅឱ្យកងទ័ពខ្មែរក្រហមនៅសំឡូត។ ពេលដឹកជញ្ជូនមានកងទ័ពខ្មែរក្រហមដើរនាំផ្លូវ និងមានកងនារីចំនួន១០០នាក់ដើរតាមពីក្រោយ។ ជួនកាល ខ្ញុំត្រូវជញ្ជូនគ្រាប់ចេញពីព្រំដែនកម្ពុជា-ថៃរហូតដល់អូរជាំ ប្រកបស្មៀត។ អំឡុងពេលដឹកជញ្ជូន ខ្ញុំជួបការលំបាកនិងវេទនាខ្លាំងណាស់ ដោយសារត្រូវដេកហាលភ្លៀងហាលខ្យល់ ហើយរយៈពេល២ថ្ងៃទើបទៅដល់ទីតាំងនីមួយៗ។ ខ្ញុំបានដឹកជញ្ជូនគ្រាប់រហូតដល់ឆ្នាំ១៩៨៨។ បន្ទាប់មកខ្ញុំបានរៀបការជាមួយប្តីឈ្មោះ យក់ វ៉ា គឺជាកងទ័ពខ្មែរក្រហម នៅអូររថក្រោះ ស្រុកសំឡូត។

នៅឆ្នាំ១៩៩៦ គឹម ពៅ បានដឹកនាំគ្រួសារកងទ័ពខ្មែរក្រហមប្រហែល៧០គ្រួសារចេញពីស្រុកសំឡូតទៅរស់នៅអូរសោម។ នៅចុងឆ្នាំ១៩៩៦ ខ្ញុំ និងក្រុមគ្រួសារកងទ័ពទាំងអស់បានចេញពីអូរសោមមករស់នៅក្នុងភូមិប្រម៉ោយ។ ខ្ញុំមករស់នៅផ្ទះមើលថែកូនៗ។ ចំណែកប្តីត្រូវចេញទៅសមរភូមិប្រយុទ្ធ។ នៅថ្ងៃទី៥ ដល់ថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៩៧ ខ្ញុំបានរត់ចេញពីប្រម៉ោយទៅរស់នៅអូរល្ហុង និងក្បាលឡាន ក្នុងស្រុកវាលវែង។ នៅឆ្នាំ១៩៩៨ ខ្ញុំ និងប្តីបានត្រឡប់មករស់នៅភូមិប្រម៉ោយវិញ។ សព្វថ្ងៃខ្ញុំមានជំងឺប្រចាំកាយដូចជា លើសឈាម និងក្រពះពោះវៀន។

# ប្រាក់ ថា ៖ ខ្ញុំត្រូវបានបញ្ជូនទៅឈរជើងការពារព្រំដែននៅអូរដាក់ដាំ

***លី សុខឃាង***



*ប្រាក់ ថា ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហមដល់ លី សុខឃាង និង មេក វិន បុគ្គលិកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ប្រាក់ ថា ភេទប្រុស អាយុ៧៦ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងភូមិស្វាយទៀប ឃុំស្វាយទៀប ស្រុកចំការលើ ខេត្តកំពង់ចាម។ សព្វថ្ងៃ ប្រាក់ថា រស់នៅក្នុងភូមិប្រោក ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

ប្រាក់ ថា បាននិយាយថា៖ «កាលពីកុមារភាព ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ពីសង្គមចាស់។ ខ្ញុំក៏សម្រេចចិត្តបួសរៀននៅវត្តតាំងគោកនៅក្នុងឆ្នាំ១៩៦១។ ខ្ញុំបានបន្តរៀនជាមួយព្រះសង្ឃអស់រយៈពេល៦ឆ្នាំ។ ការសិក្សាបានផ្តោតលើភាសាបាលីនិងព្រះធម៌ ហើយក៏បានអនុវត្តការបង្រៀនជាមួយសិស្សក្មេងៗនៅក្នុងវត្តជាដើម។ កាលពីសម័យសង្គមរាស្ត្រនិយម ខ្ញុំដើរតាមរថយន្តដុតខស ដែលបានធ្វើដំណើរពីខាងស្វាយទៀបទៅខេត្តកំពង់ចាម។ នៅជំនាន់នោះ ប្រជាជននៅតាមដងផ្លូវមិនហ៊ានសង់ផ្ទះនៅជិតផ្លូវពេកនោះទេ ព្រោះបញ្ហាហុយផ្សែងចេញពីរថយន្តដុតខស។ ខ្ញុំគឺជាកូនកំព្រាឪពុកម្តាយ តាំងពីតូចៗ ម្តាយឪពុកខ្ញុំបានស្លាប់ដោយសារជំងឺ។ ខ្ញុំមានបងប្អូនបង្កើតចំនួន២នាក់ ប៉ុន្តែបងរបស់ខ្ញុំបានស្លាប់បាត់ទៅហើយ។

រហូតដល់ឆ្នាំ១៩៦៨ ភូមិរបស់ខ្ញុំក៏ចាប់ផ្តើមកែនប្រជាជនដើម្បីបម្រើជាទ័ពព្រៃ។ អំឡុងពេលនោះខ្ញុំបានចូលរួមបម្រើក្នុងជួរទ័ពព្រៃជាមួយប្រជាជនជាច្រើននាក់ទៀត។ លុះដល់ឆ្នាំ១៩៧០ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីព្រះប្រមុខរដ្ឋ។ ខ្ញុំរួមទាំងកងកម្លាំងជាច្រើននាក់ទៀតត្រូវបានបញ្ជូនទៅវាយជាមួយកងទ័ព លន់ នល់។

*នៅចន្លោះឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៤ កងកម្លាំងខ្ញុំមានគោលដៅវាយរំដោះទីក្រុងភ្នំពេញ។ មុនដំបូងខ្ញុំវាយនៅម្តុំកប់ស្រូវ ហើយបន្តវាយចូលទៅដល់ទួលគោក។ ការវាយគ្នានៅក្នុងសមរភូមិមិនងាយស្រួលនោះទេ។ កងទ័ពទាំងអស់បានលះបង់អាយុជីវិត ព្រមទាំងគ្រួសាររបស់ខ្លួនដើម្បីចូលបម្រើទ័ព។ គ្មាននរណាម្នាក់ខ្លាចក្នុងការលះបង់គ្រប់យ៉ាងនៅពេលនោះទេ ពីព្រោះមនុស្សទាំងអស់សុទ្ធតែត្រូវដើរលើផ្លូវនោះតែមួយ។ ប៉ុន្តែទុក្ខលំបាកនៅក្នុងជួរកងទ័ពក៏មានច្រើនណាស់ដែរ ទាំងការហូបចុក និងការសម្រាកដែលយើងមិនទទួលបាននូវអ្វីដែលយើងចង់បាននោះទេ។ យើងហូបតែបាយជាមួយម្ហូបក្រៀមក្រោះ ដែលមិនជួយឱ្យមានកម្លាំងកំហែងប៉ុន្មានទេ។ ប៉ុន្តែកងទ័ពចេះតែតស៊ូប្រឹងប្រែងវាយបន្តទៅមុខ។ កងទ័ពទាំងពីរភាគីមានចំនួនជាច្រើននាក់បានស្លាប់ដោយសារការធ្វើសង្គ្រាម។ នៅក្នុងឆ្នាំ១៩៧៤ ខ្ញុំបានត្រូវរបួសចំស្មាមួយចំហៀង ធ្វើឱ្យខ្ញុំត្រូវចាកចេញពីជួរកងទ័ពមួយរយៈដើម្បីសម្រាកព្យាបាលរបួស។ មិនយូរប៉ុន្មានរបួសដែររបស់ខ្ញុំក៏បានជាសះស្បើយ ខ្ញុំក៏បានត្រឡប់ទៅសមរភូមិវិញ។*

*រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមក៏វាយដណ្តើមយកទីក្រុងភ្នំពេញទទួលបានជ័យជម្នះ។ នៅពេលដែលខ្ញុំចូលទៅដល់ភ្នំពេញ ខ្ញុំឃើញប្រជាជនត្រូវបានកងកម្លាំងមួយក្រុមជម្លៀសចេញពីទីក្រុងភ្នំពេញទៅទីជនបទ។ ទិដ្ឋភាពការជម្លៀសប្រជាជនកាលនោះ អ្នកខ្លះជិះឡាន អ្នកខ្លះជិះរទេះ ឯខ្លះទៀតដើររែកកូនចៅ និងសម្ភារមួយចំនួនដូចជាអង្ករ អំបិល ឆ្នាំង ចាន ជាដើម។ បន្ទាប់មក កងកម្លាំងខ្ញុំក៏បាននៅឈរជើងនៅភ្នំពេញមួយរយៈពេល។ កាលនោះការងារដែលខ្ញុំធ្វើគឺដើរបោសសម្អាតផ្ទះសម្បែងប្រជាជនដែលបានជម្លៀសចេញ។ ក្រៅពីនោះ ខ្ញុំមិនបានធ្វើអ្វីផ្សេងទៀតនោះទេ ព្រោះអ្នកមានតួនាទីធំៗជាអ្នកចាត់ចែង និងរៀបចំផែនការបន្ត។*

*ក្នុងរបបខ្មែរក្រហមកងទ័ពទាំងអស់ទទួលបានសម្លៀកបំពាក់ពីរសម្រាប់ និងស្បែកជើងមួយគូតែប៉ុណ្ណោះ ដោយមានពាក្យស្លោកមួយឃ្លានិយាយថា «កម្មសិទ្ធិសមរម្យ»។ ខ្ញុំបន្តបោសសម្អាតផ្ទះសម្បែងនៅភ្នំពេញរហូតដល់ថ្នាក់លើបញ្ជូនទៅនៅខេត្តមណ្ឌលគិរី។ ការធ្វើដំណើរទៅមណ្ឌលគិរីមុនដំបូងកងទ័ពទាំងអស់ត្រូវជិះទូកចេញពីភ្នំពេញទៅឈប់សម្រាកនៅខេត្តក្រចេះមួយយប់ ទើបធ្វើដំណើរដោយថ្មើរជើងបន្តទៅខេត្តមណ្ឌលគិរី។ ខ្ញុំរួមទាំងកងទ័ពជាច្រើននាក់ទៀតបានចំណាយពេលដើរអស់រយៈពេលមួយសប្តាហ៍ទើបទៅដល់ស្រុកកោះញែក។ នៅទីនោះអង្គការឱ្យខ្ញុំធ្វើស្រែ ចម្ការ ដាំដំណាំ ដោយបែកជាក្រុមកងទ័ព។ ការធ្វើស្រែនៅក្នុងរបបខ្មែរក្រហម គឺប្រើប្រាស់ចបកាប់ និងធ្វើដោយកម្លាំងមនុស្ស ទម្រាំតែធ្វើស្រូវរួចមួយរដូវៗកងទ័ពហត់នឿយណាស់។ ចំណែកឯផលស្រូវដែលទទួលបានគឺមានចំនួនច្រើនដោយសារតែដីនៅមានជីជាតិល្អ។ ការហូបចុកមិនសូវមានការលំបាកប៉ុន្មានខ្វះខាតទេ ព្រោះកងទ័ពអាចរកហូបដោយខ្លួនឯងបាន។*

*ក្រោយមក ខ្ញុំក៏ត្រូវអង្គការបញ្ជូនឱ្យទៅឈរជើងការពារព្រំដែននៅអូរដាក់ដាំ។ អូរដាក់ដាំគឺជាឈ្មោះអូរមួយដែលស្ថិតនៅចំកណ្តាលនៃខណ្ឌព្រំប្រទល់ប្រទេសកម្ពុជា និងវៀតណាម។ អូរនេះមានទឹកធ្លាក់ទៅដល់ទន្លេស្រែពក។ ជំនាន់នោះវៀតណាមនៅម្ខាងអូរម្នាក់បែកទឹកជាពីរ មួយចំហៀងវៀតណាមមួយចំហៀងកម្ពុជា។ ក្រៅពីការពារព្រំដែន កម្លាំងកងទ័ពខ្ញុំត្រូវធ្វើស្រែប្រមូលផលទុកដាក់សម្រាប់ផ្គត់ផ្គង់ខ្លួនឯង។ នៅឆ្នាំ១៩៧៧ ខ្ញុំក៏បានរៀបការ រួមជាមួយគូស្រករចំនួន៦៣គូផ្សេងទៀត។ ទីតាំងរៀបចំជំនុំផ្តុំគឺនៅសាលាកងពលក្នុងស្រុកកោះញែក។*

*បន្ទាប់ពីរៀបការហើយ ខ្ញុំបានបន្តឈរជើងនៅកោះញែករហូតដល់ឆ្នាំ១៩៧៩ កងទ័ពស្ម័គ្រចិត្តវៀតណាមវាយចូលមករំដោះ ទើបខ្ញុំជម្លៀសខ្លួនមកនៅជំរំអូរត្រាវលើភ្នំដងរែកវិញ។ នៅពេលដែលខ្ញុំធ្វើដំណើរមកដល់ភ្នំដងរែក ខ្ញុំក៏ចាប់ផ្តើមរស់នៅជាប្រជាជនធម្មតា។ ខ្ញុំលែងធ្វើជាកងទ័ពអ្វីទៀតនោះទេ។ រហូតដល់ឆ្នាំ១៩៩៨ កងកម្លាំងខ្មែរក្រហមបានរួបរួមគ្នាធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅតំបន់អន្លង់វែង ទើបខ្ញុំចុះមករស់នៅក្នុងភូមិព្រោកនេះរហូតដល់សព្វថ្ងៃ»។*

# ឡុង ថន ៖ ប្រធានអនុសេនាតូចលេខ២ ការពារព្រំដែនថ្មដា

**ចាន់ ណារិទ្ធ**

ខ្ញុំឈ្មោះ ឡុង ថន អាយុ៧៥ឆ្នាំ គឺជាប្រធានអនុសេនាតូចលេខ២ ការពារព្រំដែនថ្មដា។ ខ្ញុំមានស្រុកកំណើតនៅភូមិក្រប៉ៅ ឃុំពេជ្រចង្វារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។ បច្ចុប្បន្នខ្ញុំរស់នៅភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍-សាត់។ ខ្ញុំមានប្រពន្ធឈ្មោះ ឡុង សាកាន់ អាយុ៧៨ឆ្នាំ និងមានកូនចំនួន៧នាក់ គឺប្រុស២នាក់ និងស្រី៥នាក់។ សព្វថ្ងៃកូនរបស់ខ្ញុំមានគ្រួសារអស់ហើយ។ ខ្ញុំមានឪពុកឈ្មោះ ហម ស៊ីវ (ស្លាប់ឆ្នាំ១៩៩៦ ដោយសារជំងឺមហារីក) និងម្ដាយឈ្មោះ ទូច ដៃ (ស្លាប់ឆ្នាំ១៩៩៧ ដោយសារជំងឺមហារីកសួត)។ ខ្ញុំមានបងប្អូនបង្កើតចំនួន៨នាក់ (ប្រុស៦នាក់ និងស្រី២នាក់) ហើយខ្ញុំគឺជាកូនទី២នៅក្នុងគ្រួសារ។ បងប្អូនខ្ញុំបានស្លាប់ចំនួន៤នាក់។

កាលពីក្មេងខ្ញុំបានរៀនត្រឹមថ្នាក់ទី១០ (សង្គមចាស់) នៅសាលារៀននៅក្នុងវត្តភូមិថ្មល់។ មូលហេតុដែលខ្ញុំឈប់រៀនដោយសារតែម្ដាយឈឺគ្មានអ្នកមើលថែ។ បន្ទាប់ពីឈប់រៀន ខ្ញុំបានមកជួយឪពុកប្រកបរបរធ្វើស្រែ។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់ សម្ដេចព្រះនរោត្ដម សីហនុ ចេញពីតំណែង។ បន្ទាប់ពីរដ្ឋប្រហារបានរយៈពេល១ខែ ម្ដាយឪពុករបស់ខ្ញុំបានរៀបចំឱ្យខ្ញុំមានប្រពន្ធ។ ក្រោយពីរដ្ឋប្រហារបានរយៈពេល១ឆ្នាំ ចលនាតស៊ូខ្មែរក្រហមដឹកនាំដោយគាលក្ខ ចាប់ផ្ដើមចូលមកឃោសនានៅក្នុងភូមិក្រប៉ៅ។ គាលក្ខបានដឹកនាំអង្គភាពសិល្បៈចូលមកសម្ដែងសិល្បៈឱ្យប្រជាជនក្នុងភូមិក្រប៉ៅទស្សនា។ បន្ទាប់ពីចប់ការ



ឡុង ថន អាយុ៧៥ឆ្នាំ បច្ចុប្បន្នរស់នៅភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សម្ដែងសិល្បៈ គាលក្ខ បានឃោសនាប្រាប់ប្រជាជនក្នុងភូមិក្រប៉ៅឱ្យចូលរួមជាមួយកងទ័ពរំដោះ ដើម្បីតស៊ូវាយដណ្ដើមអំណាចឱ្យសម្ដេចព្រះ នរោត្ដម សីហនុ គ្រប់គ្រងវិញ។

នៅឆ្នាំ១៩៧២ ខ្ញុំបានសម្រេចចិត្តចាកចេញពីឪពុកម្ដាយ និងប្រពន្ធ ដើម្បីចូលរួមជាមួយកងទ័ពរំដោះដែលមានទីតាំងឈរជើងនៅក្នុងព្រៃ។ ពេលចូលទៅដល់ក្នុងព្រៃ គាលក្ខបានចែកកាំភ្លើងកាប៊ីនឱ្យខ្ញុំចំនួន១ដើម។ បន្ទាប់មក គាលក្ខបានចាត់តាំងខ្ញុំឱ្យធ្វើជាប្រធានក្រុមគ្រប់គ្រងកងទ័ពចំនួន១២នាក់ និងត្រូវបែកចែកកម្លាំងឱ្យចូលទៅឃោសនាអូស

ទាញប្រជាជននៅតាមភូមិៗ នៅឆ្នាំ១៩៧៣ តាលក្ខ បានដឹកនាំកម្លាំងទៅវាយជាមួយ ទាហាន លន់ នល់ ដែលឈរជើងនៅបន្ទាយលង្វែក ស្ថិតនៅក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ បន្ទាប់ពីវាយរំដោះបានបន្ទាយលង្វែក តាលក្ខ បានដកខ្ញុំនិងកងទ័ពផ្សេងទៀត សរុបមួយវរសេនាតូចឱ្យត្រឡប់មកឈរជើងនៅស្រុកបរិបូណ៌វិញ។ ពេលធ្វើដំណើរមកដល់ស្រុកបរិបូណ៌ ខ្ញុំនិងកងទ័ពទាំងអស់បានមកចូលរួមជាមួយកងអនុសេនាតូចលេខ៣៥ គ្រប់គ្រងដោយ តា ស្វួន ដែលជាកងទ័ពស្រុកបរិបូណ៌។ តាស្វួន បានចាត់តាំងឱ្យខ្ញុំដឹកនាំកងទ័ពមួយក្រុមដែលមានគ្នា១២នាក់ ដើម្បី ការពារតាមព្រំប្រទល់ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ ព្រោះខ្លាចតិញសម្ងាត់ ស៊ី.អ៊ី.អា ចូលមកស៊ើបការណ៍។

នៅឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា សហការជាមួយកងទ័ពវៀតណាម បានដឹកនាំកម្លាំងជាច្រើនបានធ្វើដំណើរតាមផ្លូវជាតិលេខ៥ សំដៅចូលមកវាយរំដោះនៅក្នុងខេត្តកំពង់ឆ្នាំង។ ដោយសារកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមមានចំនួនច្រើន ទើប ស្វួនបញ្ជាឱ្យកងទ័ពខ្មែរក្រហមទាំងអស់រត់ចូលព្រៃ។ បន្ទាប់មក ខ្ញុំបានធ្វើដំណើរទៅចូលរួមជាមួយកងពល៥៣០ ដែលឈរជើងនៅភូមិបំណក់ ឃុំបំណក់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ និងគ្រប់គ្រងដោយ តា ពន្លក។ បន្ទាប់ពីខ្ញុំចូលរួមជាមួយកងពល៥៣០ បានប្រហែលកន្លះខែ តាពន្លក បានដឹកនាំកម្លាំងទាំងអស់ធ្វើដំណើរចេញពីភូមិបំណក់សំដៅទៅព្រំដែនថៃ។ ពេលធ្វើមកដល់ព្រំដែនថៃដា កងទ័ពទាំងអស់ត្រូវបានបញ្ចូលជាមួយកងពលទី២ គ្រប់គ្រងដោយ តាវ៉ែន។ តាវ៉ែន បានចាត់តាំងឱ្យខ្ញុំធ្វើជាប្រធានអនុសេនាតូចលេខ១២ គ្រប់គ្រងកងទ័ពចំនួន៥០ទៅ ៦០នាក់។

នៅឆ្នាំ១៩៨៤ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាម បានដឹកនាំកម្លាំងចូលមកវាយកងទ័ពខ្មែរក្រហមនៅតំបន់ថ្មដា។ ពេលនោះកងពលទី២ (ដឹកនាំដោយ តាវ៉ែន) និងកងពលទី៣ (ដឹកនាំដោយ តាសេង) បានរៀបចំកម្លាំងដើម្បីចាំទប់ទល់ជាមួយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមនៅស៊ឹងមេទឹក។ ចំណែកប្រពន្ធខ្ញុំនិងប្រពន្ធកងទ័ពខ្មែរក្រហមផ្សេងទៀតបានរត់ភៀសខ្លួនទៅរស់នៅក្នុងជំរំខៅប្លូរបណ្តោះអាសន្ន។ នៅពេលកំពុងវាយតតាំងគ្នាជាមួយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាម ខ្ញុំត្រូវបានកងទ័ពវៀតណាមបាញ់ត្រូវស្មាខាងឆ្វេងចំនួន២គ្រាប់បណ្តាលឲ្យរងធ្ងន់ធ្ងរ។ ពេលនោះខ្ញុំត្រូវបានយុទ្ធមិត្តរួមអាវុធបញ្ជូនទៅសម្រាកព្យាបាលនៅពេទ្យអង្គភាពឈរជើងនៅតំបន់អូរភ្លូកដំរី។ បន្ទាប់ពីខ្ញុំសម្រាកព្យាបាលនៅពេទ្យបានប្រហែលកន្លះ ខ្ញុំត្រូវបញ្ជូនមកអង្គភាពជនពិការនៅចម្ការស្រូវដែលមានទីតាំងនៅខាងជើងច១។

ក្រោយពីកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមបានដកកងទ័ពត្រឡប់ទៅស្រុកភ្នំក្រវាញវិញ កងអនុសេនាតូច២និងកងវរសេនាធំរបស់អ៊ួនយ៉ង់ ត្រូវបានតាវ៉ែនបញ្ជាឱ្យទៅបោះទីតាំងឈរជើងលើភ្នំទំព័រដើម្បីធ្វើសកម្មភាពនៅតាមផ្លូវជាតិលេខ៥៦។ បន្ទាប់ពីឈរជើងលើភ្នំ



ឡុង ថន រងរបួសត្រង់ស្មា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទំព័របានរយៈពេល២ខែ កងអនុសេនាតូចលេខ១២ ត្រូវបានគាវែនផ្លាស់ឱ្យទៅនៅភូមិរវៀង ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ដើម្បីអប់រំអូសទាញប្រជាជនរស់នៅទីនោះ។

នៅឆ្នាំ១៩៩៣ កងអនុសេនាតូចលេខ១២ បានផ្លាស់ពីរវៀងមកឈរជើងនៅភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ជាមួយកងវរសេនាធំរបស់ អ៊ួន យ៉ង់។ ក្រោយពីសភាពការណ៍ស្ងប់ស្ងាត់ ខ្ញុំបានឡើងទៅយកប្រពន្ធពីជំរំខៅប្លូរឱ្យមករស់នៅភូមិប្រម៉ោយវិញ។ នៅឆ្នាំ១៩៩៥ កងទ័ពរដ្ឋាភិបាលកម្ពុជា បានដឹកនាំកម្លាំងឡើងមកវាយនៅស្រុកវាលវែលម្តងទៀត។ ពេលនោះខ្ញុំនិងប្រពន្ធបានរត់កៀសខ្លួនចេញពីស្រុកវាលវែង ទៅរស់នៅក្នុងជំរំខៅប្លូររយៈពេល៥ខែ ទើបសម្រេចចុះចូលជាមួយរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយ គឹម ពៅ។

បន្ទាប់ពីចូលរួមជាមួយកងទ័ពរដ្ឋាភិបាល គឹម ពៅ បានបញ្ជូនខ្ញុំឱ្យទៅការពារព្រំដែនថ្មដា ដែលមានទីតាំងនៅទល់មុខសុផាន់ហ៊ីន ខេត្តត្រាត ប្រទេសថៃ។ ក្រោយពីឈរជើងការពារព្រំដែនថ្មដាបានរយៈពេល១ឆ្នាំ ខ្ញុំបានផ្លាស់ពីព្រំដែនថ្មដាមកឈរជើងនៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ហើយបានសាងសង់ផ្ទះរស់នៅក្នុងភូមិប្រម៉ោយ និងប្រកបរបរធ្វើចម្ការដើម្បីផ្គត់ផ្គង់ជីវភាពបន្ថែមនៅក្នុងគ្រួសាររហូតមកដល់សព្វថ្ងៃ។



ផ្លូវលំនិងស្ពានឈើ នៅស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រឿងរ៉ាវរបស់ ឡុង សាកាន់ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

**មឿន ស្រីណុច**



ឡុង សាកាន់ អាយុ៧៣ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឡុង សាកាន់ភេទស្រីអាយុ៧៣ឆ្នាំកើតនៅភូមិកំពង់ស្វាយក្រោម ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល។ សព្វថ្ងៃខ្ញុំរស់នៅក្នុងភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ ជុំ លុយ (ស្លាប់) និងម្ដាយឈ្មោះ ហែម កួយ (ស្លាប់)។ ខ្ញុំមានបងប្អូនបង្កើតចំនួន ១១នាក់ (ស្រី៧នាក់) ហើយខ្ញុំគឺជាកូនទី៥ក្នុងគ្រួសារ។ សព្វថ្ងៃបងប្អូនរបស់ខ្ញុំ នៅរស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៥នាក់ (ស្រី៣នាក់)។ ខ្ញុំធ្លាប់រៀបការចំនួនពីរដង ដោយប្ដីទីមួយឈ្មោះ ប្រាក់ គឿន(ស្លាប់) មានកូនចំនួន៣នាក់(ស្រី២នាក់) និងប្ដីទីពីរឈ្មោះ ឡុង ថន មានអាយុ៧៥ឆ្នាំ និងមានកូនចំនួន៤នាក់ (ស្រី៣នាក់)។

វ័ពុកកាលពីវ័យកុមារ ខ្ញុំចូលរៀននៅសាលាមួយក្នុងភូមិកំពង់ស្វាយក្រោម បានត្រឹមថ្នាក់ទី១០ សង្គមចាស់ ហើយលោកគ្រូខ្ញុំឈ្មោះ ភ័ណ្ឌ។ នៅឆ្នាំ១៩៧០ មានការទម្លាក់គ្រាប់បែកខ្លាំងណាស់ ខ្ញុំបានរត់ចូលក្នុងលេណដ្ឋាន។ បន្ទាប់មកយួនធីវគីតែងតែចូលមកចាប់នារីស្អាតៗយកចេញពីភូមិជាញឹកញាប់ ខ្ញុំខ្លាច ហេតុនេះមានតែយកធ្យូងគូរលើមុខដើម្បីបិទបាំង។ គ្រាប់បែកទម្លាក់កាន់តែធ្ងន់ធ្ងរទៅ ខ្ញុំបានរត់ទៅពួនក្នុងទឹក និងបានត្រាំទឹកអស់រយៈពេលជាច្រើនម៉ោង។

នៅឆ្នាំ១៩៧៣ ក្រុមគ្រួសារខ្ញុំ និងអ្នកភូមិកំពង់ស្វាយក្រោមទាំងអស់ ត្រូវបានយួនធីវគីកៀរចូលក្នុងព្រៃទៅខាងស្អាង។ ក្រោយស្ងប់ស្ងាត់ការទម្លាក់គ្រាប់បែក ឪពុកម្ដាយរបស់ខ្ញុំបានត្រឡប់ទៅរស់នៅភូមិកំណើតវិញ។ ប៉ុន្តែខ្ញុំ មិនត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅវិញនោះទេ។ ខ្ញុំត្រូវនៅរៀនដេរខោអាវសម្រាប់កងទ័ព។ តមកទៀត កងទ័ពទាំងនោះបានបញ្ជូនខ្ញុំឱ្យទៅហាត់រៀនបាញ់កាំភ្លើង លូនក្រាប និងយុទ្ធសាស្ត្រធ្វើសង្គ្រាមនៅលើភ្នំតាម៉ៅ ស្ថិតក្នុងស្រុកបាទី ខេត្តតាកែវ។ ក្រោយពីហាត់ចប់ ខ្ញុំត្រូវទៅសមរភូមិប្រយុទ្ធជាមួយទាហាន លន់ នល់ គ្រប់ទីកន្លែង។ ក្រៅពីប្រយុទ្ធ ខ្ញុំត្រូវដើរសែងកងទ័ពរបួសទៅដាក់នៅសមរភូមិក្រោយដើម្បីព្យាបាល។

នៅក្នុងព្រៃ ខ្ញុំមានខោអាវខ្មៅតែ២សម្រាប់ប៉ុណ្ណោះសម្រាប់ផ្លាស់ប្តូរ។

នៅឆ្នាំ១៩៧៥ ខ្ញុំផ្លាស់មកនៅក្នុងខេត្តកណ្តាល និងបានទទួលតួនាទីជាមេក្រុមគ្រប់គ្រងកងចល័តនារី។ ខ្ញុំជាអ្នកដឹកនាំកងនារីទៅរែកដី និងលើកទំនប់។ ខ្ញុំត្រូវផ្លាស់ប្តូរទីកន្លែងរស់នៅពីមួយកន្លែងទៅមួយកន្លែងជាញឹកញាប់។

នៅឆ្នាំ១៩៧៨ អង្គការឱ្យខ្ញុំរៀបការប្តីឈ្មោះ ប្រាក់ គឿន។ ខ្ញុំ និងប្តីបានរៀបការដោយស្ម័គ្រចិត្តមិនមានការបង្ខិតបង្ខំឡើយ។ ខ្ញុំបានរៀបការនៅទីតាំងបែកចាន (ភ្នំពេញ)។ អំឡុងពេល ខ្ញុំរៀបការមានកងទ័ពចូលរួម និងមានម្ហូបអាហារជាច្រើន។ ខ្ញុំដឹងថាប្តីខ្ញុំមានតួនាទីជាប្រធានកងពល ប៉ុន្តែមិនបានដឹងច្បាស់ថាប្តីគ្រប់គ្រងកងពលលេខប៉ុន្មានទេ។ ប្តីខ្ញុំគ្រប់គ្រងកងទ័ព និងតែងតែឃើញមានប្រជាជនយកម្ហូបអាហារមកឱ្យគាត់ជាញឹកញាប់។ ជាពិសេសនៅពេលប្តីខ្ញុំទៅដល់កន្លែងណា តែងតែមាននារីៗស្អាតៗមកចាំទទួល។ ក្រោយមក ខ្ញុំ និងប្តីបានមករស់នៅក្នុងស្រុកសំឡូត ខេត្តបាត់ដំបង។ ប្តីរបស់ខ្ញុំបានចេញទៅធ្វើការងារ រីឯខ្ញុំនៅមើលកូនតូចៗនៅផ្ទះ។ ក្រោយមក ខ្ញុំបានចេញទៅខ្សែត្រៀមខាងមុខបាញ់ជាមួយកងទ័ពវៀតណាម។ ខ្ញុំត្រូវចល័តទៅគ្រប់កន្លែងក្នុងស្រុកសំឡូត។

នៅឆ្នាំ១៩៨៩ អ្នកស្រុកបានមកប្រាប់ខ្ញុំថា ប្តីខ្ញុំត្រូវបានបាញ់សម្លាប់ ព្រោះមានជាប់ទាក់ទងជាមួយទាហានខាងក្នុង។ ក្នុងពេលជាមួយគ្នា ខ្ញុំកើតកូនទី៣បាន៤ខែ។ បន្ទាប់ពីប្តីបានស្លាប់ ខ្ញុំមានការលំបាកណាស់ត្រូវមើលថែកូនម្នាក់ឯង។ ខ្ញុំមានជីវិតកម្សត់ និងបានឆ្លងកាត់ជីវិតតស៊ូអស់ជាច្រើនឆ្នាំ។ ខ្ញុំមានការលំបាកវេទនា និងគ្រោះថ្នាក់ច្រើនខ្លាំងណាស់។ ខ្ញុំតែងតែខិតខំធ្វើការងារទៅតាមអ្វីដែលខ្មែរក្រហមបញ្ជា ដើម្បីបាននៅរស់រានមានជីវិត។ អ្វីដែលខ្ញុំតែងតែងគិតក្នុងពេលធ្វើសង្គ្រាម គឺ សុំមានជីវិតរស់ ដើម្បីត្រឡប់ទៅរស់នៅជួបជុំជាមួយឪពុកម្តាយវិញ។ នៅឆ្នាំ២០០២ ខ្ញុំបានរៀបការជាមួយប្តីទី២ឈ្មោះ ឡុង ថន និងបានរស់នៅក្នុងភូមិប្រម៉ោយរហូតដល់បច្ចុប្បន្ន។



ចម្ការដំឡូងមី របស់ប្រជាជននៅស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# យុទ្ធសាស្ត្ររបស់ប្រទេសថៃក្នុងការដណ្តើមយកដែនអធិបតេយ្យភាពដែលបានបាត់បង់ក្រោមមហាអំណាចអាណានិគមៈ យន្តការទ្វេភាគីដ៏អន់បំផុត

ឆាំង យុ



រូបគំនូរបន្លាញពីកងទ័ពថៃវាយប្រហារ និងឈ្លានពានប្រទេសកម្ពុជា នៅក្នុងខេត្តសៀមរាប។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រទេសថៃផ្តល់អាទិភាពនិងថែមទាំងទាមទារឱ្យមានយន្តការចរចាទ្វេភាគី ជាជាងបង្កើតឱ្យមានយន្តការឬកិច្ចព្រមព្រៀងពហុភាគី ពីព្រោះតាមរយៈយន្តការចរចាទ្វេភាគី ប្រទេសថៃគឺមានអំណាចខ្លាំងក្លាក្នុងការ គាបសង្កត់ សម្លុតបង្ខិតបង្ខំ និងប្រើល្បិចកលយុទ្ធសាស្ត្រគ្របដណ្តប់លើដៃគូដែលខ្សោយជាងខ្លួន តាមទំនើងចិត្ត ហើយមិនប្រឈមនឹងការរិះគន់ឬការធ្វើឱ្យរាំងស្ទះមកពីមជ្ឈដ្ឋានខាងក្រៅ។ ប្រទេសកម្ពុជាមិនទាន់មានឧត្តមភាពផ្នែកសព្វាវុធ និងកម្លាំងទ័ពលើសប្រទេសថៃ ប៉ុន្តែក្នុងជម្លោះតាមបណ្តោយព្រំដែន ប្រទេសកម្ពុជាមានប្រៀបលើទស្សនអន្តរជាតិបូករួមទាំងសេចក្តីសម្រេចពីតុលាការយុត្តិធម៌អន្តរជាតិដែលឯករាជ្យ និងអព្យាក្រឹត។ ហេតុដូច្នេះ ប្រទេសថៃអាចសម្រេចបាននូវឧត្តមភាពលើដែនអធិបតេយ្យភាពរបស់កម្ពុជានៅតំបន់ព្រំដែនបាន លុះត្រាណាតែតាមរយៈយន្តការចរចាទ្វេភាគី ដោយបិទទ្វារ គាបសង្កត់ សម្លុត បង្ខិតបង្ខំ ដែលជាការរំលោភបំពានរបស់ប្រទេសថៃ ហើយមិនត្រូវបានមើលឃើញដោយសហគមន៍អន្តរជាតិ (ឬយ៉ាងហោចណាស់ យន្តការចរចាទ្វេភាគីនេះ ហាក់មានលក្ខណៈជាកិច្ចព្រមព្រៀងដែលអាចទទួលយកបានពីគ្រប់ភាគី បើទោះបីជាមានវិសមភាពក៏ដោយ)។



រូបគំនូរបង្ហាញពីកងទ័ពថៃវាយប្រហារ និងឈ្លានពានប្រទេសកម្ពុជា នៅក្នុងខេត្តសៀមរាប។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រទេសថៃបរាជ័យដោយមិនអាចឈ្លានទៅបង្កើតយន្តការចរចាទ្វេភាគី ហេតុដូច្នេះហើយទើបប្រទេសថៃបានទទួលយកយន្តការចរចាពហុភាគី និងយល់ព្រមតាមកិច្ចព្រមព្រៀងដែលត្រូវបានរៀបចំឡើងជាយន្តការពហុភាគី ដូចជាកិច្ចព្រមព្រៀងបទឈប់បាញ់ចុងក្រោយបង្អស់នៅទីក្រុងកូឡាឡាំពួរ។ ទោះបីជាយ៉ាងណាក៏ដោយ បទឈប់បាញ់មិនបាននាំប្រទេសថៃខិតទៅរកគោលដៅចុងក្រោយរបស់ខ្លួនក្នុងការគ្រប់គ្រងទឹកដីដែលខ្លួនបានជឿថាគឺជាកម្មសិទ្ធិស្របច្បាប់របស់ខ្លួន។ ជាក់ស្តែងតំបន់ទាំងនោះគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសកម្ពុជាអស់ជាច្រើនសតវត្សរ៍មកហើយ ហើយតំបន់ទាំងនោះនៅតែបន្តស្ថិតក្រោមការគ្រប់គ្រងរបស់ប្រទេសកម្ពុជាមកដល់សព្វថ្ងៃនេះ។ ទោះបីជាយ៉ាងនេះក្តី ប្រទេសថៃបានគ្រប់គ្រងលើតំបន់ទាំងនោះដោយខុសច្បាប់ក្នុងរយៈពេលខ្លីតែប៉ុណ្ណោះពីអតីតកាល ហើយប្រទេសថៃត្រូវបានបង្ខំដោយរដ្ឋាភិបាលលោកខាងលិចឱ្យប្រគល់ទឹកដីទាំងនោះមកឱ្យប្រទេសកម្ពុជាចំនួនពីរលើកគឺ (លើកទីមួយនៅឆ្នាំ១៩០៧ ប្រទេសបារាំងបានបង្ខំប្រទេសថៃឱ្យប្រគល់ទឹកដីប្រទេសកម្ពុជាដែលខ្លួនទន្ទ្រានយកមកឱ្យកម្ពុជាវិញ និងលើកទីពីរនៅឆ្នាំ១៩៤៦ សហរដ្ឋអាមេរិកបង្ខំប្រទេសថៃឱ្យប្រគល់ទឹកដីរបស់ប្រទេសកម្ពុជាដែលខ្លួនកាត់យកដោយខុសច្បាប់នៅឆ្នាំ១៩៤១ មកឱ្យកម្ពុជាវិញ)។ ប្រទេសថៃនៅតែបន្តចាត់ទុកការបង្ខិតបង្ខំរបស់រដ្ឋាភិបាលលោកខាងលិចគឺជាឧទាហរណ៍នៃការដាក់គំនាបដោយមិនសមស្របរបស់អាណានិគមដែលប្រទេសថៃបដិសេធមិនទទួលយកជាដាច់ខាត។

បញ្ហាទឹកដីទាំងនោះបានបន្សល់ទុកឱ្យយើងនូវស្ថានភាពដូចបច្ចុប្បន្ន ដែលយន្តការចរចាទ្វេភាគីហាក់បីដូចជាមិនទទួលបានផ្លែផ្កា ហើយយន្តការចរចាពហុភាគីក៏មិនអាចជួយឱ្យប្រទេសថៃសម្រេចបាននូវគោលដៅចុងក្រោយរបស់ខ្លួន ដូច្នេះប្រតិបត្តិការយោធាគឺជាមធ្យោបាយតែមួយគត់របស់ប្រទេសថៃ ក្នុងការសម្រេចបាននូវគោលបំណងយុទ្ធសាស្ត្រឈ្លានពានរបស់ខ្លួន។ បញ្ហានេះមិនមែនស្ថិតនៅលើការបំពេញតាមលក្ខខណ្ឌសន្តិភាពរបស់ប្រទេសថៃទៀតទេប៉ុន្តែវាគឺជាការចោទសួរថាតើប្រទេសកម្ពុជានិងសហគមន៍អន្តរជាតិមានឆន្ទៈក្នុងការធ្វើសម្បទានដែនអធិបតេយ្យភាពដើម្បីដោះដូរយកសន្តិភាពដែរឬយ៉ាងណា ហើយប្រសិនបើកម្ពុជាយល់ព្រមធ្វើសម្បទាន (ឬត្រូវបានបង្ខំឱ្យទទួលយកការបាត់បង់បូរណភាពទឹកដីនៅតាមបណ្តោយព្រំដែន) តើអ្វីទៅជារបៀបវារៈបន្តបន្ទាប់ទៀតដែលប្រទេសថៃនឹងទាមទារដើម្បីជាថ្នូរនឹងសន្តិភាព?

ប្រទេសកម្ពុជា និងសហគមន៍អន្តរជាតិ មិនគួរចាត់ទុកជម្លោះនេះត្រឹមតែជាបញ្ហាសន្តិសុខព្រំដែនទៀតនោះទេប៉ុន្តែជម្លោះនេះគឺជាវិវាទដែលកំពុងគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សេចក្តីសុខសាន្តរបស់ប្រទេសកម្ពុជា ។



រូបគំនូរបង្ហាញពីកងទ័ពថៃវាយប្រហារ និងឈ្លានពានប្រទេសកម្ពុជា នៅក្នុងខេត្តសៀមរាប។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# តើហេតុអ្វីបានជាពិបាកសម្រាប់ប្រទេសថៃដោយគ្រាន់តែនិយាយពាក្យថាសន្តិភាពនិងឈប់បាញ់

សូ ហ្វារីណា




រូបរាប់ពីស្តាំ៖ ប្រធានាធិបតីសហរដ្ឋអាមេរិក ដូណាល់ ត្រាំ, នាយករដ្ឋមន្ត្រីកម្ពុជា ហ៊ុន ម៉ាណែត, នាយករដ្ឋមន្ត្រីថៃ អនុទិន ឆានវីរកូល និង នាយករដ្ឋមន្ត្រីម៉ាឡេស៊ី អាន់វ៉ា អ៊ីប្រាហ៊ីម។ ប្រធានាធិបតី ដូណាល់ ត្រាំ និងនាយករដ្ឋមន្ត្រីម៉ាឡេស៊ី អាន់វ៉ា អ៊ីប្រាហ៊ីម បានចូលរួមធ្វើជាសាក្សីក្នុងពិធីចុះកិច្ចព្រមព្រៀងសន្តិភាពរវាងនាយករដ្ឋមន្ត្រីកម្ពុជា ហ៊ុន ម៉ាណែត និង នាយករដ្ឋមន្ត្រីថៃ អនុទិន ឆានវីរកូល នៅទីក្រុងកូឡាឡាំពួរ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥។ (សេតវិមាន)

«ប្រជាជនកម្ពុជា និងប្រជាជនថៃមានទស្សនរួមមួយគឺចង់ដោះស្រាយជម្លោះនេះឱ្យចប់ត្រឹមជំនាន់នេះ។ ប៉ុន្តែបែរជាខុសគ្នាស្រឡះក្នុងការដោះស្រាយ។ ការប្រើកម្លាំងយោធាមិនមែនជាដំណោះស្រាយ។ វានឹងអូសបន្លាយគ្រប់ជំនាន់។ ការប្រើកម្លាំងយោធាដើម្បីដោះស្រាយគឺប្រៀបដូចជា «ទឹកក្តៅកំពុងតែពុះ»។ នៅពេលអ្នកខំប្រឹងបិទគម្របហើយថែមភ្លើងនោះនឹងធ្វើឱ្យទឹកកាន់តែពុះខ្លាំង ហៀរចេញមកក្រៅរហូតដល់រីង។ ទីបំផុតអ្នកនឹងមិនទទួលបានអ្វីទាំងអស់។ ប៉ុន្តែប្រសិនបើយើងបើកគម្របកំសៀវ ពន្លត់ភ្លើង ហើយទុកឱ្យទឹកត្រជាក់ នោះយើងនឹងទទួលបានទឹកស្អិនពិសារទាំងអស់គ្នា»។

បើទោះបីជាមានសង្គ្រាមពាក្យសម្តីយ៉ាងខ្លាំងក្លារវាងប្រជាជនថៃ និងប្រជាជនកម្ពុជា ចាប់តាំងពីមានជម្លោះព្រំដែន និងការឈ្លានពានរបស់ទាហានថៃមកលើប្រទេសកម្ពុជា ប្រជាជនកម្ពុជានិងប្រជាជន

ថៃមានទស្សនៈរួមមួយគឺចង់ដោះស្រាយជម្លោះនេះឱ្យចប់ត្រឹមជំនាន់នេះ។ ប៉ុន្តែបែរជាខុសគ្នាស្រឡះក្នុងការដោះស្រាយ។

ប្រទេសថៃព្យាយាមប្រើកម្លាំងយោធាដើម្បីឈ្លានពានប្រទេសកម្ពុជា និងបំផុសចលនាប្រជាជនថៃឱ្យគាំទ្រយុទ្ធនាការរបស់ខ្លួន ដោយយកហេតុផលមិនត្រឹមត្រូវថា នេះធ្លាប់ជាទឹកដីរបស់ថៃនិងសន្យាទាមទារយកមកវិញ។

ចំណែកប្រទេសកម្ពុជាព្យាយាមអត់ធ្មត់និងដោះស្រាយជម្លោះដោយសន្តិវិធី ហើយប្រកាន់គោលការណ៍ការពារខ្លួននិងទឹកដីគឺ៖ «បើកងទ័ពថៃមិនបាញ់កងទ័ពកម្ពុជាមុនទេ កងទ័ពកម្ពុជាមិនតបតទៅវិញទេ»។

ហេតុអ្វីបានជាពាក្យថាសន្តិភាពនិងបទឈប់បាញ់ពិបាកសម្រាប់ប្រជាជនថៃនិយាយចេញមក បើទោះបីខ្លួនបានទទួលស្គាល់ថា យោធាថៃបានឈ្លានពានប្រទេសកម្ពុជាពិតមែន?

កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥ លោក ប្រាវិត រោចនាភ្រុត អ្នកកាសែតជើងចាស់របស់ Khaosod English បានផ្តួចផ្តើមឱ្យមានការដើរដើម្បីសន្តិភាព នៅវេលាម៉ោង៣ល្ងាច នៅទីក្រុងបាងកក។ គាត់បានសង្ឃឹមថា ប្រហែលមានមនុស្សច្រើននាក់ចូលរួម។ ប៉ុន្តែផ្ទុយស្រឡះ គឺមានតែប្រជាជនថៃ៦នាក់ប៉ុណ្ណោះ រួមទាំងគាត់បានបង្ហាញខ្លួននៅទីក្រុងបាងកក និង១០នាក់នៅខេត្តឈាងម៉ៃ។ មិនត្រឹមតែប៉ុណ្ណោះ គាត់ត្រូវបានរិះគន់យ៉ាងចាស់ដៃពីប្រជាជនថៃមួយចំនួនធំ។

នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ Miss World 2025 Opal Suchata បានជំរុញឱ្យយុវជនស្វែងរកសន្តិភាព នៅក្នុងពិធីទទួលរង្វាន់ Global Leadership Achievement Award ប៉ុន្តែត្រូវបានប្រជាជនថៃរិះគន់ដូចលោក ប្រាវិត ដែរ។

បណ្តាថ្នាក់ដឹកនាំក្នុងជួរកងទ័ពថៃ បានលើកពាក្យពេចន៍និងសម្តែងអាកប្បកិរិយាធ្វើសង្គ្រាមឈ្លានពានបំបាក់បំផ្លាញ និងទាមទារយកទឹកដីមួយចំនួនពីប្រទេសកម្ពុជា រហូតដល់ថ្នាក់ហ៊ានសម្លាប់ជនស៊ីវិលស្លូតត្រង់។

នៅក្នុងការបញ្ចេញមតិលើបណ្តាញសង្គម សារព័ត៌មាន យូធ្យូប របស់ថៃ ទាក់ទិននឹងជម្លោះព្រំដែនកម្ពុជា-ថៃ គឺភាគច្រើនជាទស្សនៈញុះញង់ និងជំរុញឱ្យកងទ័ពថៃបន្តប្រតិបត្តិការយោធា។ អ្នកទាំងនោះមិនបានគិតឬគិតតិចតួចដល់ប្រជាជនភៀសសឹកថៃដែលជាអ្នករងគ្រោះពិតប្រាកដ។

ចំណែកប្រទេសកម្ពុជា និងប្រជាជនកម្ពុជា ទាំងក្មេងទាំងចាស់ ប្រុសស្រី គ្រប់សាសនា ស្រែកហៅរកសន្តិភាពនិងធ្វើសកម្មភាពដើម្បីសន្តិភាព។

ខ្ញុំសូមសួរទៅរដ្ឋាភិបាលថៃនិងយោធាថៃថា «តើអ្នកនៅស្រមៃចង់បានទឹកដីកម្ពុជា និងរកលេសធ្វើសង្គ្រាមដល់ពេលណា? អ្នកតែងតែយកវិធីដោះស្រាយចាស់ដែលដូនតាអ្នកបានធ្វើមកលើប្រទេសកម្ពុជាចាប់តាំងពីសតវត្សរ៍ទី១៨ មកអនុវត្តលើប្រទេសកម្ពុជានៅសតវត្សរ៍ទី២១នេះទៀត? តើអ្នកគិតថា ប្រទេសកម្ពុជានៅតែបណ្តោយឱ្យអ្នកធ្វើបែបនេះទៀតឬយ៉ាងណា?

ខ្ញុំសូមសួរទៅប្រជាជនថៃថា «តើអ្នកឆ្ងល់ទេថា ប្រសិនបើទឹកដីនេះធ្លាប់ជាទឹកដីរបស់អ្នក ហេតុអ្វីបានជាប្រជាជនកម្ពុជាហៅអ្នកថាជាចោរតជំនាន់មកដល់សព្វថ្ងៃនេះ? អ្នកឮឬធ្វើមិនឮ? តើអ្នកដឹងឬធ្វើមិនដឹង?

ខ្ញុំយល់ថា ប្រសិនបើប្រទេសថៃពិតជាចង់ដោះស្រាយជម្លោះព្រំដែនត្រឹមជំនាន់នេះមែន ហើយបញ្ចប់ឱ្យបានឆាប់ នោះដំណោះស្រាយល្អសម្រាប់ប្រទេសយើងទាំងពីរគឺ៖

- កងទ័ពថៃ ឈប់បាញ់
- ដោះស្រាយជម្លោះដោយសន្តិវិធីនិងមានភាគីទីពចូលរួម ព្រោះការដោះស្រាយតែរវាងប្រទេសកម្ពុជា និងប្រទេសថៃ គឺលែងមានប្រសិទ្ធភាពហើយ។
- វិលទៅរកការអនុវត្តសេចក្តីប្រកាសរួមដែលបានធ្វើឡើងនៅ ទីក្រុងកូ ឡាឡាំពួរកាលពីខែតុលា។
- ឈប់ព្យាយាមរកលេសសង្គ្រាមទៀត

ដូច្នេះការប្រើកម្លាំងយោធាមិនងាយចប់ដើម្បីដោះស្រាយជម្លោះព្រំដែន នឹងអូសបន្លាយគ្រប់ជំនាន់។ ការប្រើកម្លាំងយោធាដើម្បីដោះស្រាយគឺប្រៀបដូចជា «ទឹកក្តៅកំពុងតែពុះ»។ នៅពេលអ្នកប្រឹងបិទគម្របហើយថែមភ្លើង នោះនឹងធ្វើឱ្យទឹកកាន់តែពុះខ្លាំង ហៀរចេញមកក្រៅ រហូតដល់រីង។ ទីបំផុតអ្នកនឹងមិនទទួលបានអ្វីទាំងអស់។ ប៉ុន្តែប្រសិនបើយើងបើកគម្របកំសៀវ ពន្លត់ភ្លើង ហើយទុកឱ្យទឹកត្រជាក់ នោះយើងនឹងទទួលបានទឹកឆ្អិនពិសារទាំងអស់គ្នា។




ប្រធានាធិបតីសហរដ្ឋអាមេរិក ដូណាល់ ត្រាំ ចូលរួមធ្វើជាសាក្សីក្នុងពិធីចុះកិច្ចព្រមព្រៀងសន្តិភាពរវាងនាយករដ្ឋមន្ត្រីកម្ពុជា ហ៊ុន ម៉ាណែត និង នាយករដ្ឋមន្ត្រីថៃ អនុទិន ឆានវីរកូល នៅ ទីក្រុងកូ ឡាឡាំពួរ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥។ (សេតវិមាន)



រូបរាប់ពីឆ្វេង៖ នាយករដ្ឋមន្ត្រីម៉ាឡេស៊ី អាន់វ៉ា អ៊ីប្រាហ៊ីម, ប្រធានាធិបតីសហរដ្ឋអាមេរិក ដូណាល់ ត្រាំ, នាយករដ្ឋមន្ត្រីថៃ អនុទិន ឆានវីរកូល និង នាយករដ្ឋមន្ត្រីកម្ពុជា ហ៊ុន ម៉ាណែត។ ប្រធានាធិបតី ដូណាល់ ត្រាំ និង នាយករដ្ឋមន្ត្រីម៉ាឡេស៊ី អាន់វ៉ា អ៊ីប្រាហ៊ីម បានចូលរួមធ្វើជាសាក្សីក្នុងពិធីចុះកិច្ចព្រមព្រៀងសន្តិភាពរវាងនាយករដ្ឋមន្ត្រីកម្ពុជា ហ៊ុន ម៉ាណែត និង នាយករដ្ឋមន្ត្រីថៃ អនុទិន ឆានវីរកូល នៅ ទីក្រុងកូ ឡាឡាំពួរ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥។ (សេតវិមាន)

# កម្ពុជាគួរមានលក្ខខណ្ឌចំនួន ៥ សម្រាប់ ការចរចាទ្វេភាគីជាមួយប្រទេសថៃ

ឆាំង យុ



ប្រាសាទស្តុកកក់ធំ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



តាមទស្សនដ៏ស្តួចស្តើងរបស់ខ្ញុំបាទ កម្ពុជាគួរមានលក្ខខណ្ឌចំនួន ៥ សម្រាប់ «**ការចរចាទ្វេភាគី**» ជាមួយប្រទេសថៃ៖

១) ប្រទេសថៃត្រូវតែទទួលស្គាល់នូវរាល់ «ខ» ចែងក្នុងកិច្ចព្រមព្រៀងបទឈប់បាញ់ជាលាយលក្ខណ៍អក្សរជាមុន ដែលជាមូលដ្ឋានគ្រឹះមិនអាចកែប្រែដោះដូរបាន។ ការទទួលស្គាល់ជាលាយលក្ខណ៍អក្សររាល់ «ខ» ចែងក្នុងកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយ និង ទាំងស្រុងត្រូវតែផ្សព្វផ្សាយជាសាធារណៈ។

២) បង្ហាញសុឆន្ទៈ ស្មោះត្រង់ និងចេតនាពិតប្រាកដរួមមានការដោះលែងវីរកងទ័ពកម្ពុជាដើម្បីជួសជុលរាល់ការរំលោភលើកិច្ចព្រមព្រៀងបទឈប់បាញ់ ព្រមទាំងការបំពានធ្ងន់ធ្ងរផ្សេងទៀតនាពេលកន្លងមក។

៣) ប្រកាន់ជំហរ ទាមទារឱ្យមានការផ្សព្វផ្សាយជាលាយលក្ខណ៍អក្សរយ៉ាងលម្អិតនិង ទាំងស្រុងដល់សាធារណជននូវរាល់ «ខ» ចែងក្នុងកិច្ចព្រមព្រៀង (គ្មាន «ខ»ចែងក្នុងកិច្ចព្រមព្រៀងគឺជាការសម្ងាត់នោះទេ)។

៤) ទទួលយកនូវស្ថាប័នតាមដានឃ្លាំមើលរួមគ្នាមួយ ដែលមានសមាសភាពភាគីកម្ពុជា និងថៃ បូករួមទាំងភាគីអព្យាក្រឹតទីបី ហើយមានអំណាចស្របច្បាប់ដើម្បីអង្កេតមើលការមិន

អនុវត្តកិច្ចព្រមព្រៀង រួមទាំងផ្សព្វផ្សាយលទ្ធផល និងលើកជាអនុសាសន៍កែតម្រូវ។

៥) គ្រប់ «ខ» ផែនក្នុងកិច្ចព្រមព្រៀងដែលទទួលបានពីការចរចានេះ នឹងមិនត្រូវបានចាត់ទុកថាជាការលះបង់សិទ្ធិបុគ្គលការទាមទាររបស់កម្ពុជា រួមទាំងការទទួលស្គាល់នូវរាល់ច្បាប់អន្តរជាតិ និងសិទ្ធិក្នុងការប្តឹងតាមផ្លូវច្បាប់តវ៉ាប្រឆាំងនឹងប្រទេសថៃនោះឡើយ។

ប្រសិនបើគណៈប្រតិភូកម្ពុជាមានបំណងចង់លើកឡើងនូវ«ខ»ផែនណាមួយផ្សេងទៀតពីនេះ គណៈប្រតិភូអាចដាក់បញ្ចូលនូវច្បាប់សិទ្ធិមនុស្សបុអនុសញ្ញាពាក់ព័ន្ធនានា ជា «ខ» ផែនជាចំខាតដែលមិនអាចធ្វើសម្បទានបាន។

និយាយឱ្យស្មោះត្រង់ ខ្ញុំគិតថាយោធាថៃមិនចង់បានបែបនេះទេ។ ខ្ញុំប្រាកដក្នុងចិត្តថាយោធាថៃមើលឃើញប្រទេសកម្ពុជាគឺជាប្រទេសមួយដែលងាយឈ្លានពាន។ អំពើឈ្លានពានរបស់ប្រទេសថៃនេះ ប្រហែលជាមិនគ្រាន់តែដណ្តើមកាន់កាប់ទឹកដីប្រទេសកម្ពុជាតែប៉ុណ្ណោះទេ ប៉ុន្តែក្នុងគោលដៅបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធប្រទេសកម្ពុជាទៀតផង។



ប្រាសាទស្តុកកក់ធំ១ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ភាគីថៃដោះលែងវីរកងទ័ពកម្ពុជា៖ ចំណុចពិចារណាបីសំខាន់ៗ សម្រាប់កម្ពុជា

ឆាំង យុ



*វីរកងទ័ពកម្ពុជា១៨រូប ដែលថៃចាប់ខ្លួនបន្ទាប់ពីមានបទឈប់បាញ់មួយថ្ងៃគឺនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥ ត្រូវបានដោះលែងឱ្យវិលត្រឡប់មកប្រទេសកម្ពុជាវិញ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។ (មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ចំណុចពិចារណាបីសំខាន់ៗដែលគួរតែអមជាមួយនឹងដំណឹងដ៏រីករាយនៃការដោះលែងវីរកងទ័ពកម្ពុជាដែលបានឃុំខ្លួនដោយភាគីថៃ។

**ទីមួយ៖** នេះគឺជាជំហានឆ្ពោះទៅមុខដ៏សំខាន់មួយក្នុងការលើកកម្ពស់សន្តិភាពរវាងប្រទេសទាំងពីរ ប៉ុន្តែកម្ពុជាគួរតែមានការប្រុងប្រយ័ត្នដោយមិនត្រូវផ្តល់ការកោតសរសើរខ្លាំងហួសហេតុពេកទៅលើរដ្ឋាភិបាលថៃ ចំពោះការបំពេញកាតព្វកិច្ចដែលខ្លួនបានបង្អែបង្អង់អស់រយៈពេលយ៉ាងយូរនោះឡើយ។

**ទីពីរ៖** កម្ពុជាគួរមានការប្រុងប្រយ័ត្នដោយមិនត្រូវសន្មតថាបទឈប់បាញ់នាពេលបច្ចុប្បន្នអាចក្លាយទៅជាសន្តិភាពពិតប្រាកដបានភ្លាមៗនោះទេ។ រដ្ឋាភិបាលថៃបច្ចុប្បន្ន ហាក់ដូចជាគ្មានឆន្ទៈ ឬគ្មានសមត្ថភាពក្នុងការប្រើប្រាស់ភាពជាអ្នកដឹកនាំដែលចាំបាច់ដើម្បីសម្រេចបាននូវសន្តិភាពឡើយ ដូច្នេះកម្ពុជាប្រហែលជាត្រូវរង់ចាំដល់រដ្ឋាភិបាលថៃអាណត្តិក្រោយឡើងកាន់អំណាចបន្ទាប់ពីការបោះឆ្នោតខែកុម្ភៈខាងមុខ។

**ចុងក្រោយ៖** កម្ពុជាមិនគួរភ្លេចឡើយថា កាលៈទេសៈដែលនៅជុំវិញជម្លោះនេះ បានឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីការឈ្លានពានដោយខុសច្បាប់មកលើកម្ពុជា ហើយវាចាំបាច់ត្រូវតែមានការគិតគូរទូទាត់សំណងឱ្យបានត្រឹមត្រូវ និងយុត្តិធម៌ចំពោះរាល់ការខូចខាតទាំងឡាយដែលបង្កឡើងដោយជម្លោះនេះ។

# សិស្សានុសិស្សមកពីវិទ្យាល័យ ឈីនលាន ហាន់ជ័យ ធ្វើទស្សនកិច្ចសិក្សា

## នៅមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តកំពង់ចាម

***សាំង ចាន់ធូ និង លី វេទីត***



សិស្សវិទ្យាល័យ ឈីនលាន ហាន់ជ័យ ធ្វើទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តកំពង់ចាម នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៦ សិស្សានុសិស្សមកពីវិទ្យាល័យ ឈីនលាន ហាន់ជ័យ ស្រុកកំពង់សៀមចំនួន១០នាក់បានមកធ្វើទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តកំពង់ចាម។ ក្នុងដំណើរទស្សនកិច្ចសិក្សានេះ សិស្សានុសិស្សទាំងអស់ ទទួលបានកម្មវិធីសិក្សា រួមមាន៖ ទី១) បទបង្ហាញអំពីពិព័រណ៍ប្រវត្តិមេដឹកនាំក្នុងរបបខ្មែរក្រហម, ការជម្លៀសប្រជាជនដោយបង្ខំ, និងការកាត់ទោសមេដឹកនាំខ្មែរក្រហម; ទី២) ការអានសៀវភៅ និងឯកសារនៅបណ្ណាល័យខ្មែរក្រហម និងទី៣) កិច្ចពិភាក្សា និងស្វែងយល់ពីកិច្ចការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តកំពង់ចាម។

ជាកិច្ចចាប់ផ្តើម បុគ្គលិកប្រចាំការនៅការិយាល័យមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តកំពង់ចាម ឈ្មោះ ទូច វណ្ណេត បានធ្វើកិច្ចស្វាគមន៍ និងធ្វើបទបង្ហាញទៅកាន់សិស្សានុសិស្សទាំងអស់ស្តីពីពិព័រណ៍អចិន្ត្រៃយ៍ដែលបង្ហាញអំពីប្រវត្តិមេដឹកនាំខ្មែរក្រហម, ព្រឹត្តិការណ៍ការជម្លៀសប្រជាជនដោយបង្ខំ, ការបង្ខំប្រជាជនឱ្យធ្វើការជាទម្ងន់នៅការដ្ឋានលើកទំនប់ប្រឡាយ, និងការដួលរលំរបបខ្មែរក្រហមនៅដើមឆ្នាំ១៩៧៩។ បន្ទាប់មកទៀត សិស្សទាំងអស់ត្រូវចូលទៅកាន់បណ្ណាល័យខ្មែរក្រហម និងបន្ទប់បណ្ណសារ

ខ្មែរក្រហម ដើម្បីស្វែងយល់អំពីប្រភពធនធានសៀវភៅ និងឯកសារអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ សិស្សានុសិស្សបានបន្តការទស្សនាពិព័រណ៍ស្តីពី «ក្តីសង្ឃឹមកម្ពុជា»។ ក្រោយពីសិស្សានុសិស្សទាំងអស់បានបញ្ចប់ការទស្សនាផ្ទាំងពិព័រណ៍, លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តកំពង់ចាម បានធ្វើបទបង្ហាញអំពីកិច្ចការងារមួយចំនួន ដែលកិច្ចការទាំងនោះរួមមានវេទិកាថ្នាក់រៀន ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប-តេយ្យ, ដំណើរទស្សនកិច្ចតាមរយៈរថភ្លើង, កិច្ចការងាររបស់អ្នកស្ម័គ្រចិត្តកម្ពុជា ក្នុងការចុះជួបសួរសុខទុក្ខអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងការសហការជាមួយអង្គការសង្គមស៊ីវិល, រដ្ឋបាលខេត្ត ស្រុកឃុំ និងវិទ្យាល័យនានា នៅក្នុងខេត្តកំពង់ចាម។

ជាកិច្ចបញ្ចប់នៃដំណើរទស្សនកិច្ចនេះ, សិស្សានុសិស្សដែលបានចូលរួមបានបង្ហាញចំណាប់អារម្មណ៍របស់ខ្លួន ដូចខាងក្រោម៖

**រឆាម ភារៈ** រៀនថ្នាក់ទី១២ បានបង្ហាញចំណាប់អារម្មណ៍របស់ខ្លួនថា៖ «នៅពេលដែលខ្ញុំបានចូលរួមទស្សនកិច្ចសិក្សាថ្ងៃនេះ ខ្ញុំបានឃើញរូបភាព និងយល់ដឹងអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម។ អ្វីដែលខ្ញុំបានយល់ដឹងបន្ថែមទៀតនោះគឺការអានឯកសារ និងបទសម្ភាសន៍ទាក់ទងអ្នករស់រានមានជីវិតពីរបបខ្មែរ ចេញពីកិច្ចការងារស្រាវជ្រាវរបស់អ្នកស្ម័គ្រចិត្ត ដែលជាយុវជនយុវនារីជំនាន់ក្រោយដូចរូបខ្ញុំដែរ»។

**ខេ ពិសី** រៀនថ្នាក់ទី១១ លើកឡើងអំពីទស្សនយល់ឃើញរបស់ខ្លួនថា៖ «នៅពេលដែលខ្ញុំសម្លឹងរូបថតរបស់ប្រជាជននៅជំនាន់មុន ដែលបានឆ្លងកាត់ការឈឺចាប់ក្នុងសម័យសង្គ្រាម, របបប្រល័យពូជសាសន៍ខ្មែរក្រហម និងជីវិតជាជនភៀសខ្លួន, ខ្ញុំមានចិត្តអាណិតអាសូរជាខ្លាំង។ ផ្ទៃមុខរបស់គាត់ បង្កប់ទៅដោយរឿងរ៉ាវនៃការស៊ូទ្រាំ និងការខិតខំប្រឹងប្រែងបន្តទៅមុខទៀត។ អ្វីដែលខ្ញុំកាន់តែសម្លឹង កាន់តែគិត និងកាន់តែអាណិតនោះ គឺខ្ញុំនៅឃើញទឹកមុខនៃទុក្ខលំបាក និងការស៊ូទ្រាំរបស់ប្រជាជនរស់នៅតាមជំរំជនភៀសខ្លួន ដោយសារតែសង្គ្រាមនាពេលនេះ។ ទុក្ខលំបាក និងការស៊ូទ្រាំរបស់ប្រជាជនដែលរងផលប៉ះពាល់ពីសង្គ្រាម បានផ្តល់មេរៀនដល់ខ្ញុំ និងយើងទាំងអស់គ្នានៃ សាមគ្គីភាព និងសន្តិភាព ហើយក៏ជាការក្រើនរំឭកដល់យើងអំពីទំនួលខុសត្រូវក្នុងការចូលរួមអភិវឌ្ឍន៍ និងការការពារប្រទេសជាតិយើង»។





សិស្សវិទ្យាល័យ ឈីនលាន ហាន់ជ័យ ធ្វើទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តកំពង់ចាម នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្អូនខ្ញុំឈ្មោះ សារ៉េត បានបាត់ខ្លួនពេលអង្គការបញ្ជូនទៅធ្វើព្រលានយន្តហោះខេត្តកំពង់ឆ្នាំង

ឌី ស៊ីថា

នៅឆ្នាំ១៩៧៨ គង់ សារឿនបានទៅដេកពេទ្យអ្នកលឿង។ សារ៉េត ជាប្អូនប្រុសភ្លោះជាមួយ គង់ សារឿនបានផ្ញើសំបុត្រតាមមិត្តភក្តិគង់សារឿនមកថា «ខ្ញុំត្រូវអង្គការបញ្ជូនទៅធ្វើព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង មិនបាច់ចាំផ្លូវទេ»។ សារ៉េតបានបាត់ខ្លួនតាំងពីពេលនោះរហូតមកដល់សព្វថ្ងៃ។ ខាងក្រោមនេះគឺជាសាច់រឿងដែល គង់ សារឿន បានរៀបរាប់៖



គង់ សារឿន នៅភូមិឈូកស ឃុំឈើទាល ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង នៅឆ្នាំ២០០៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ គង់ សារឿន ភេទប្រុស អាយុ៥១ឆ្នាំ (២០០៥) កើតនៅក្នុងភូមិឈើទាលខាងត្បូង ឃុំឈើទាល ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ បច្ចុប្បន្នរស់នៅភូមិឈូកស ឃុំឈើទាល ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ ឪពុកខ្ញុំឈ្មោះ គង់ សិន (ស្លាប់) និងម្ដាយឈ្មោះសួសយ៉ែនសព្វថ្ងៃអាយុ៧៩ឆ្នាំ។ ខ្ញុំមានបងប្អូនចំនួន១០នាក់។ គង់ សារ៉េតជាកូនភ្លោះជាមួយខ្ញុំ ប៉ុន្តែខ្ញុំកើតមុន។ សារ៉េតជាកូនទី៥នៅក្នុងគ្រួសារ។

មុនរបបខ្មែរក្រហម សារ៉េតរៀននៅសាលាវត្តឈើទាលស្ថិតនៅក្នុងឃុំឈើទាល ស្រុកស្វាយជ្រំត្រឹមថ្នាក់ទី៧ចាស់។ សារ៉េត បានឈប់រៀនដោយសារមានរដ្ឋប្រហារនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ក្រោយពីឈប់រៀនក៏បានចូលធ្វើបដិវត្តន៍។ សារ៉េត ចូលធ្វើបដិវត្តន៍ដំបូង បងប្អូនឪពុកម្ដាយមានការព្រួយបារម្ភខ្លាំងណាស់ខ្លាចមានគ្រោះថ្នាក់។

នៅឆ្នាំ១៩៧២ សារ៉េត បានធ្វើជានីរសារ។ នៅឆ្នាំ១៩៧៣ សារ៉េតចល័តទៅកងទ័ពស្រុកស្វាយជ្រំ ដល់ទ័ពតំបន់ខ្វះកម្លាំងក៏ដក សារ៉េត ទៅកងទ័ពតំបន់វិញ។ កាលនោះ គណៈតំបន់ឈ្មោះ តាសូរ។

កាលពីកុមារភាពខ្ញុំរៀនបានត្រឹមថ្នាក់ទី២ ខ្ញុំរៀនភាសាបារាំងបាន៣ឆ្នាំ បន្ទាប់មកខ្ញុំបួសនៅវត្តបាន៥ឆ្នាំ។ ខ្ញុំបានចូលបដិវត្តន៍ឆ្នាំដែលអង្គការរំលាយពុទ្ធសាសនា។ ខ្ញុំសឹកអង្គការចាត់តាំងឱ្យចូលពាណិជ្ជកម្មភូមិភាគ។ ប្រធានពាណិជ្ជកម្មភូមិភាគ ឈ្មោះសារុន នៅស្រុករមាសហែក ខេត្តស្វាយរៀង។

នៅឆ្នាំ១៩៧៥ខ្ញុំចូលធ្វើការងារខាងពាណិជ្ជកម្មភូមិភាគបូព៌ា។ សារ៉េតធ្វើជាកងទ័ពតំបន់២៣ ខេត្តស្វាយរៀង។ ខ្ញុំធ្វើការងារនៅពាណិជ្ជកម្មភូមិភាគមិនសូវបានមកលេងផ្ទះទេ ជួនកាល៦ខែទើបមកលេងផ្ទះម្ដង។ គ្រួសារខ្ញុំហូបចុកមិនគ្រប់គ្រាន់ទេ ប៉ុន្តែផ្ទះប្រជាជនដែលគ្មានកូនទៅចូលរួមបដិវត្តន៍កាន់តែពិបាកខ្លាំង។ នៅស្វាយរៀងខ្ញុំជាមួយសារ៉េត បានជួបគ្នាញឹកញាប់ព្រោះកន្លែងខ្ញុំសម្បូររបស់ហូប។

នៅឆ្នាំ១៩៧៧ ខ្ញុំនៅអ្នកលឿងបាន៣ខែ។ នៅពាក់កណ្ដាលឆ្នាំ១៩៧៧ ខាងនិរតីមកចាប់សោភឹម ព្រោះកូនចៅតាសោភឹម អង្គការតាមចាប់បានខ្លះហើយ។ អង្គការតាមចាប់សោភឹមនិង

ប្រកាសថាសោភឹមក្បត់។ នៅក្នុងក្រុមរបស់ខ្ញុំអង្គការសម្លាប់ទាំងអស់ នៅសល់តែខ្ញុំម្នាក់ដែលបានត្រឡប់មកផ្ទះវិញ។ អង្គការនិយាយថាបក្ខពួករបស់សោភឹមត្រូវតែធ្វើបាប។ កម្មាភិបាលទាំងអស់អង្គការសម្លាប់ដោយប្រើវិធីចាប់មួយហើយឱ្យទៅចាប់ពីរ ចាប់ពីរហើយឱ្យទៅចាប់បួន ចាប់បួនហើយឱ្យទៅតាមចាប់ទាំងអស់។ អង្គការចាប់យកទៅសម្លាប់បណ្ដែតទឹកតាមទន្លេអ្នកលឿងអស់រាប់ម៉ឺនរាប់សែននាក់ ឱ្យតែជាប់ខ្សែធ្វើការងារជាមន្ត្រីរាជការពីសង្គមចាស់។

នៅឆ្នាំ១៩៧៨ ខ្ញុំបានទៅដេកពេទ្យនៅអ្នកលឿង ហើយសារ៉េតបានផ្ដាំតាមមិត្តភក្ដិខ្ញុំថា គាត់(សារ៉េត)ទៅកំពង់ឆ្នាំង អង្គការឱ្យទៅធ្វើព្រលានយន្តហោះ ដូច្នេះកុំរង់ចាំផ្លូវគាត់។ សារ៉េត បាត់ដំណឹងរហូតតាំងពីឆ្នាំ១៩៧៨។

អង្គការបានចាប់សោភឹម ហើយបានបញ្ជូនអ្នកពាក់ព័ន្ធជាមួយសោភឹមឱ្យមកនៅតាមសហករណ៍វិញ។ ស្ថានភាពកាន់តែតឹងប្រជាជនច្រើនធ្វើការងារមិនហ៊ានឈប់ខ្លាចអង្គការយកទៅសម្លាប់។ កម្មាភិបាលនិរតីចូលមក ប្រជាជនដែលធ្លាប់ធ្វើកម្មាភិបាលថ្នាក់ក្រោមត្រូវយកទៅសម្លាប់ចោលដោយសម្ងាត់។ ពេលនោះមានឈ្លបតាមដាន ប្រជាជនភូមិភាគបូព៌ាគ្មានចន្លោះ។ អង្គការប្រាប់ថាខ្ញុំជាប់និន្នាការជាមួយ សោភឹម ទើបអង្គការឱ្យមកនៅសហករណ៍ព្រៃកាត ឥឡូវមានឈ្មោះថាឈូកស។ ខ្ញុំមកនៅសហករណ៍ហូបបាយរួម។ អង្គការឱ្យខ្ញុំឡើងត្នោត២៥ដើមក្នុងមួយថ្ងៃ។

នៅចុងឆ្នាំ១៩៧៨ ខ្ញុំតវ៉ាជាមួយអង្គការព្រោះឡើងត្នោតហត់ពេក។ ពេលបានទឹកត្នោតច្រើន ខ្ញុំបានសុំទៅហូបបាយនៅកន្លែងធ្វើស្ករ។ បើគិតសរុបទឹកត្នោតបានទៅដល់៥ធុងត្រូវកូរស្ករភ្លាមព្រោះខ្លាចទុកយូរខូច។ កាលណាខូចស្ករអង្គការថាខ្ជះខ្ជាយ។ ថ្ងៃមួយប្រធានសហករណ៍រាយការណ៍ថាក្រុមខ្ញុំទាំង១២នាក់នោះមិនព្រមហូបបាយរួម ទើបអង្គការមកចាប់ទាំងខ្ញុំដែរ។ បងប្អូនខ្ញុំបានលួចបាយយកមកឱ្យខ្ញុំហូបបានតែ២ថ្ងៃ ប្រធានរោងបាយរាយការណ៍ឱ្យកម្មាភិបាលនិរតីទៀត។ អង្គការបានយកកាំភ្លើង១២ដើមមកឱ្យក្រុមខ្ញុំទាំង១២នាក់រួចហើយបញ្ជូនទៅប្រយុទ្ធនៅសមរភូមិ។ ពេលនោះបងជីដូនមួយខ្ញុំនៅសហករណ៍សុំកម្មាភិបាលមកពីនិរតីថាទុកខ្ញុំអប់រំសិន ប៉ុន្តែអង្គការនៅតែមិនព្រម។ បងជីដូនមួយខ្ញុំឈ្មោះ មាស ឌុន ធ្វើការឡើងត្នោតជាមួយគ្នា ហើយប្រធានសហករណ៍ឈ្មោះ គួច សាអ៊ុន។ អង្គការបម្រុងបញ្ជូនខ្ញុំឱ្យទៅស្លាប់ ប៉ុន្តែភ្លាមៗនោះ មានយន្តហោះកងទ័ពវៀតណាមហោះមកទម្លាក់គ្រាប់បែកនៅខាងលិចស្វាយរៀង។ អង្គការរត់ភៀសខ្លួនអស់ទើបខ្ញុំបានរួចខ្លួន។

បន្ទាប់ពីខ្ញុំឆ្លងកាត់របបខ្មែរក្រហមរួចមក ខ្ញុំពិតជាមានការសោកស្ដាយដែលរបបនោះគឺជារបបផ្ដាច់ការ និងបានសម្លាប់ប្រជាជនយ៉ាងសាហាវឃោរឃៅ។ ក្រោយពេលរបបខ្មែរក្រហមដួលរលំទៅ ខ្ញុំបានបាត់ប្អូនប្រុសម្នាក់ឈ្មោះ សារ៉េត អតីតជាទាហាន។ ខ្ញុំពិតជាមានអារម្មណ៍សោកស្ដាយខ្លាំងណាស់នៅពេលប្រទេសជាតិមានសន្តិភាពហើយមិនបានជួបជុំបងប្អូន។



មិត្តនារីនៅអង្គភាពសិល្បៈ នៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

*រូបក្របមុខ៖*

*សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ និងព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សព្វព្រះរាជហឫទ័យ ព្រះរាជានុញ្ញាតឱ្យលោក ឆាំង យុ ប្រធានព្រះរាជបណ្ណាល័យ ហ្វូងម៉ែ និងជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ចូលក្រាបថ្វាយបង្គំគាល់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*រូបក្របក្រោយ៖*

*លោក ធីម រីអេសឺ នៅប្រាសាទព្រះវិហារ ក្នុងឆ្នាំ២០២៤។ លោក ធីម គឺជាជំនួយការជាន់ខ្ពស់របស់សមាជិកសភាលោក ភីតធី វែលឆ៍ ដែលធ្លាប់បានបំពេញការងារជូនសមាជិកព្រឹទ្ធសភាលោក ផាទ្រីក លាហ៊ី អស់រយៈកាល៣៧ឆ្នាំ។ លោក ធីម ត្រូវបានកត់សម្គាល់ថា គឺជា «បុគ្គលិកដ៏មានឥទ្ធិពលបំផុតម្នាក់ នៅក្នុងសភាដែលគ្រប់គ្រងគោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិក និងជំនួយបរទេសរបស់សហរដ្ឋអាមេរិក»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣*

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chaktomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org



A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 313, January 2026

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.